# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៧ ខែកញ្ញា លេខ ៩

ព.ស. ២៤៩៨ – គ.ស. ១៩៥៥

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*


— សេចក្ដីបរិសុទ្ធិនៅឯណា .......... ព្រះទេពសត្ថា កិម - ទូ .... ៦៤៣

— ប្រស្នាធម៌ ៩១ .............. ឃុនបណ្ណានុរក្ស ប៊ូ - ប៊ូ .... ៦៥២

— រឿងធម្មទ្ធជបណ្ឌិត ............ លោក គាំ - ឌុំ .......... ៦៥៧

— បញ្ញាសជាតក ភាគទី ៤ .......... បណ្ឌិតមហា ឈឹម - ស៊ុម .... ៦៦៨


*ផ្នែកអក្សរសាស្ត្រ*


— និទានសុភាសិត ................ ព្រះមហា ម៉ៅ - ខាន់ ...... ៦៧៧

— រឿងសៅរសោយ (តមក) ......... ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម .. ៦៨៣

— រឿងសាមកុក (តមក) .......... ឧកញ៉ា នូ - កន ......... ៦៩៣

— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) ... លោក ផេង - ជ្រីវ ........ ៧០១

— រឿងបល្ល័ង្កទិព្យ (តមក) .......... លោក រ៉ាយ - ប៊ុក ........ ៧០៩


*កំណត់ទិនប្បវត្តិការណ៍*


— ពិធីសម្ពោធបើកសាលាបាលីរង
វត្តព្រះព្រហ្មរ័ត្នខេត្តសៀមរាប .... ព្រះគ្រូអនុគុណ កែ អឿន ... ៧១៦



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២១០រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique

## TABLE DES MATIÈRES

### PARTIE RELIGIEUSE:


| | | Page |
|---|---|---|
| — Parisuddhi . . . . . . . . . | *Vên.* TEM-TO . . . . . . . | 643 |
| — Prasna Dharma . . . . . . . | *M.* BOU-PO . . . . . . . | 652 |
| — Dhammaddhajapandit . . . . | *M.* KAM-DOUM . . . . . | 657 |
| — Pannasajataka-vol. 4 . . . . | *M.* CHHIM-SOUM . . . . | 668 |


### PARTIE LITTERAIRE:


| | | |
|---|---|---|
| — Nidanasubhasita . . . . . . | *Vên.* MAO-KHANN . . . | 677 |
| — Le « SAU - SOY » ou l'influence saturnienne (*suite*) . . . . . | *Vên.* PEUNG-PAM. . . . . | 683 |
| — Histoire de SAMKOK (suite) . . | *Oknha* NOU-KAN . . . . . | 693 |
| — Le souffle du désert (suite) . | *M.* PHENG-CHRIV . . . | 701 |
| — Les trente deux récits du TRONE (suite) . . . . . . . | *M.* RAY-BUC . . . . . . | 709 |


### NOTES ET CHRONIQUES:


| | | |
|---|---|---|
| — Inauguration de l'Ecole Elémentaire de Pali de Vat Brah Prom Rat . . . . . . . | *Vên.* KER-OEURN . . . . . | 716 |


Prix d'abonnement annuel (comprenant 12 numéros) 210$00

# សេចក្តីបរិសុទ្ធនៅឯណា?

## ព្រះទេពសត្ថា កិម-គួ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ
រៀបរៀង

---

សេចក្តីបរិសុទ្ធិជាគូនឹងសេចក្តីមិនបរិសុទ្ធិ ។ សេចក្តីបរិសុទ្ធិគឺអ្វី? សេចក្តីបរិសុទ្ធិ គឺការស្អាតកាយ, ស្អាតវាចា, ស្អាតចិត្ត មិនសៅហ្មងដោយអំពើអាក្រក់ណាមួយដែលគួរឲ្យអ្នកផងតិះដៀលបាន ។ សេចក្តីមិនបរិសុទ្ធិគឺអ្វី? សេចក្តីមិនបរិសុទ្ធិមានដំណើរផ្ទុយគ្នានឹងសេចក្តីបរិសុទ្ធិ ដូចបាននិយាយមកហើយនេះ ។

មនុស្សប្រភេទណាក៏ដោយ ទោះជាន់ខ្ពស់ក្តី ជាន់កណ្តាលក្តី ជាន់ទាបក្តី ជាអ្នកចេះលៃលករៀបចំទុកដាក់កាយឲ្យសមរម្យទៅតាមឋានៈរបស់ខ្លួន មិនប្រព្រឹត្តប្រឡែសប្រែស, ជាអ្នកអនុលោមតាមច្បាប់សម្រាប់ផ្លូវលោកនឹងច្បាប់សម្រាប់ផ្លូវធម៌ ទាំងកន្លែងចំពោះមុខទាំងកន្លែងកំបាំងមុខ មិនប្រើកម្លាំងកាយរំលោភឲ្យប្រព្រឹត្តទៅហួសហេតុហួសទំនង មានការប្រហារជីវិតសត្វ នឹងការលួចលាក់ឆក់ដណ្តើមរឹបជាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយអយុត្តិធម៌ជាដើម, ជាអ្នកមានឫកពាសុភាពរាបសាល្អ ទាំងមានចរិយាធម៌នឹងអបចាយនធម៌ចំពោះអ្នកដទៃមិនរើសមុខ យ៉ាងនេះជាដើមហៅថា **កាយបរិសុទ្ធិ** បរិសុទ្ធិដោយកាយ ។

មនុស្សណាមួយកាលបើបញ្ចេញវាចានិយាយពីអ្វី វាចានោះឯងមិនដែលបៀតបៀន ឲ្យកើតសេចក្តីរង្កៀសដល់អ្នកដទៃ ច្រើននិយាយតែពាក្យណាដែលនាំឲ្យមានប្រយោជន៍, ជាវាចាសុភាពបសាពីរោះ មិនទ្រគោះបោះបោក ប្រមាថមើលងាយអ្នកដទៃ, ជាសំដីគួរគេជ្រះថ្លា គួរគេចង់ស្តាប់ វាងផុតពីវចីទុច្ចរិតទាំង ៤ យ៉ាង មិនឲ្យប៉ះពាល់ខូចសិទ្ធិអ្នកដទៃ យ៉ាងនេះជាដើមហៅថា វាចាបរិសុទ្ធិ បរិសុទ្ធិស្អាតដោយវាចា ។

មនុស្សណាមួយ បានសង្រួមប្រុងប្រយ័ត្នសំអាតចិត្តរបស់ខ្លួនឲ្យបរិសុទ្ធ ឲ្យតាំងនៅក្នុងកុសលធម៌ ប្រាសចាកមនោទុច្ចរិតទាំង ៣ យ៉ាង មិនបណ្តោយឲ្យចិត្តក្រេវក្រោធលោភលន់ ឈ្នានីស ច្រណែននិន្ទាគេ យ៉ាងនេះជាដើម ហៅថា ចិត្តបរិសុទ្ធិ បរិសុទ្ធិស្អាតដោយចិត្ត ។

អ្នកដែលបានកើតមកមានជីវិតរស់នៅក្នុងលោកនេះ មានសញ្ញាតិជាមនុស្សនីមួយៗ គប្បីញុំាងកាយ វាចា ចិត្ត ឲ្យស្ងប់រៀបរយល្អទៅតាមច្បាប់លោកនិងច្បាប់ធម៌ដែលមានកំរិតទុកមក ពុំគួរបើកអំណាចបណ្តោយឲ្យកាយ វាចា ចិត្ត ប្រព្រឹត្តពាយងាយតាំងនៅខាងក្រៅច្បាប់ឡើយ ព្រោះថាការដែលបានទទួលសុខភាព, វឌ្ឍនភាពនិងជោគជ័យគ្រប់ជំពូករបស់សត្វនីមួយៗ រមែងកើតអំពីកាយ វាចា ចិត្ត ដ៏បរិសុទ្ធល្អ, ឯការបានទទួលទុក្ខទោសគ្រោះថ្នាក់អពមង្គលគ្រប់ជំពូក ក៏រមែងកើតមកអំពីកាយ វាចា ចិត្ត មិនបរិសុទ្ធល្អដែរ ព្រោះកាយ វាចា ចិត្ត ទាំង ៣ នេះទុកដូចជាទ្វារសម្រាប់បើកឱកាសឲ្យសុខនិងទុក្ខហូរចូលមក ឬថាជាប្រធានជាខាងមុខក្រសួងជាអ្នកបង្កហេតុឲ្យកើតសុខនិងទុក្ខក៏បាន ។

ព្រោះហេតុនោះ សេចក្តីបរិសុទ្ធិនិងសេចក្តីមិនបរិសុទ្ធិទាំងពីរនេះ ដែលកើតឡើងហើយរមែងឲ្យផលដល់បុគ្គលអ្នកធ្វើចំពោះខ្លួនឯង បើនិយាយតាមសាមញ្ញវោហារថា អ្នកណាធ្វើក៏ជារបស់អ្នកនោះ ឥតមានអ្នកណាធ្វើឲ្យអ្នកណាបរិសុទ្ធឬសៅហ្មងបានឡើយ ។ ប៉ែកខាងលទ្ធិព្រាហ្មណ៍មានសេចក្តីប្រកាន់ថា អំពើបាបណាមួយដែលបុគ្គលធ្វើហើយ គេអាចលាងជំរះបណ្តេញឬបទ្យាត់ចោលបានដោយធ្វើពិធីមានងូតទឹកជាដើម គឺក្នុងពេលដែលកំពុងងូតទឹកជំរះមន្ទិលកាយ បាបនោះឯងក៏ជ្រះស្អាតអណ្តែតរសាត់ទៅតាមខ្សែទឹកជាមួយនឹងមន្ទិលកាយដែរ ។ មានលទ្ធិដទៃខ្លះទៀតប្រកាន់ថា អំពើបាបណាមួយទោះបីធ្ងន់ក្តី ស្រាលក្តី ដែលបុគ្គលធ្វើហើយ គេអាចទៅលន់តួអង្វរករសូមខមាទោសចំពោះព្រះម្ចាស់សួគ៌ ដើម្បីឲ្យព្រះម្ចាស់សួគ៌នោះ ប្រោសប្រាណត្រាប្រណីលើកទោសកំហុសរបស់ខ្លួនចោលចេញបាន ដូចគ្នានឹងព្រះមហាក្សត្រម្ចាស់ផែនដីទ្រង់ប្រោសប្រាណលើកទោសព្រះរាជទានដល់អ្នកធ្វើខុស ឲ្យផុតចាកព្រះរាជអាជ្ញាដែរ យ៉ាងនេះជាដើម ។

ចំណែកខាងព្រះពុទ្ធសាសនា មានសេចក្តីផ្ទុយគ្នានឹងលទ្ធិទាំងនោះថា អំពើបាបដែលបុគ្គលធ្វើដោយខ្លួនឯង រមែងសៅហ្មងដោយខ្លួនឯង, មិនធ្វើបាបដោយខ្លួនឯង រមែងបរិសុទ្ធដោយខ្លួនឯង ។ សេចក្តីបរិសុទ្ធិនិងសេចក្តីសៅហ្មង រមែងកើតចំពោះខ្លួនអ្នកធ្វើតែម្យ៉ាងប៉ុណ្ណោះ មិនមែនកើតអំពីហេតុដទៃឡើយ ។ បុគ្គលដែលសៅហ្មងព្រោះអកុសលកម្ម, ដែលបរិសុទ្ធចាកសេចក្តីសៅហ្មង ព្រោះកុសលកម្មប្រកបដោយប្រាជ្ញា

ដែលយល់ត្រូវ ៗ ជនណាពិចារណាឃើញច្បាស់ដោយប្រាជ្ញាថា ការប្រព្រឹត្តធ្វើអកុសលកម្មគឺអំពើជាអកុសលផ្សេងៗ មានសម្លាប់សត្វនិងលួចលាក់ឆក់ដណ្តើមកំហែង ប្លន់ប្រវ័ញ្ចយកទ្រព្យសម្បត្តិរបស់គេដោយអយុត្តិធម៌ជាដើម អំពើទាំងនេះសុទ្ធតែជាកម្មមានទោសជាផ្លូវអបាយ មិនប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ ហើយក៏លះបង់គឺមិនធ្វើអកុសលកម្មនោះតទៅទៀត ជននោះឈ្មោះថាជាអ្នកបរិសុទ្ធស្អាត សូម្បីជាអ្នកមានសេចក្តីសៅហ្មងជិតដាមជាប់មកអំពីពេលមុនខ្លះ ព្រោះអកុសលកម្មដែលខ្លួនធ្វើដោយសេចក្តីប្រហែសធ្វេសធោតល្ងង់ខ្លៅ ក៏គង់ត្រឡប់ទៅជាអ្នកបរិសុទ្ធស្អាតដោយសារកុសលកម្ម ដែលខ្លួនធ្វើក្នុងកាលជាខាងក្រោយដោយពិត, សមដូចភាសិតថា:

យោ ច បុព្វេ បមជ្ជិត្វា បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ អព្ភា មុត្តោ វ ចន្ទិមា

អ្នកណាធ្វេសប្រហែសក្នុងកាលពីមុន លុះកាលជាខាងក្រោយមក ក៏ផ្លាស់ប្រែទៅជាមិនធ្វេសប្រហែសវិញ អ្នកនោះឈ្មោះថា ធ្វើលោកនេះឲ្យភ្លឺស្វាងរុងរឿង ដូចជាព្រះចន្ទដែលចេញផុតពីពពក ។

អធិប្បាយបញ្ជាក់ពុទ្ធភាសិតនេះថា ជនណាមួយ កាលពីពេលមុនមក ជាអ្នកមានសេចក្តីធ្វេសប្រហែសវង្វេងជ្រុលធ្វើអំពើអាក្រក់ណាមួយដោយកាយ វាចា ចិត្តដែលអ្នកប្រាជ្ញតែងរិះគន់ថាជាអំពើលាមកកខ្វក់សៅហ្មងមិនស្អាត លុះកាលជាខាងក្រោយមក ក៏ប្រែជាភ្ញាក់គំនិតដឹងខ្លួនថាខុស ហើយលះបង់សេចក្តីធ្វេសប្រហែសវង្វេងដែលធ្លាប់តែប្រព្រឹត្តធ្វើ

អំពើអាក្រក់នោះៗ ចោលចេញ ហើយប្រព្រឹត្តធ្វើតែអំពើល្អ ដោយកាយ វាចា ចិត្ត មានឲ្យទានរក្សាសីលជាដើម ជននោះឯងឈ្មោះថាធ្វើខ្លួនឲ្យមានពន្លឺភ្លឺឲ្យបរិសុទ្ធស្អាត ទាំងកេរ្តិ៍ឈ្មោះរបស់ជននោះសោត ក៏ក្រអូបផ្សាយទៅកាន់ទិសទាំងពួងដោយសេចក្តីរុងរឿងក្នុងលោកនេះ ប្រៀបដូចជាព្រះចន្ទពេញវង់ដែលលៀនឃ្លាតចេញផុតពីមន្ទិល មានពពកជាដើមដូច្នោះឯង ៗ សេចក្តីដែលពណ៌នាមកប៉ុណ្ណោះនេះ ដើម្បីបញ្ជាក់ឲ្យឃើញថា ក្រៅអំពីខ្លួនរបស់ខ្លួនឯង អ្នកណានឹងអាចធ្វើអ្នកណាឲ្យបរិសុទ្ធឬសៅហ្មងនោះពុំបានឡើយ ៗ

មានជនពួកខ្លះក្នុងលោកនេះមានសេចក្តីយល់ថា សេចក្តីបរិសុទ្ធិនឹងសេចក្តីមិនបរិសុទ្ធិសម្រេចមកតែអំពីចិត្ត សូម្បីកុសលក្តី អកុសលក្តី ក៏សម្រេចមកតែអំពីចិត្តដែរ ឬដំណើរទៅកាន់សុគតិក្តី ទៅកាន់ទុគ្គតិក្តី ក៏សម្រេចមកតែអំពីចិត្តដែរ ហេតុនោះ យើងមិនចាំបាច់ធ្វើទេ ដូចជាបុណ្យកុសលអ្វីផ្សេងៗ យើងកុំចាំបាច់ធ្វើ ឬកុំចាំបាច់ហាត់គិតទុកជាមុន នាំឲ្យខាតទ្រព្យ ឬនាំឲ្យរវល់ខាតវេលាទេ ចាំដល់ពេលណាដែលយើងត្រូវការសេចក្តីល្អគឺ បុណ្យ ឬក៏ក្នុងពេលជិតស្លាប់សឹមយើងតាំងចិត្តឲ្យបរិសុទ្ធស្អាតល្អដើម្បីឈោងចាប់យកសុគតិតែម្តង ៗ អ្នកមានគំនិតយល់ដូច្នេះ ប្រហែលជាស្មានថាចិត្តនេះជាធម្មជាតិ ងាយប្រែទៅ ស្រួលហ្វឹកហាត់ស្រួលពត់ដម្រង់ចង់ឲ្យទៅយ៉ាងណាៗ ក៏អាចបំបែរបំបត់ភ្លាមៗ បានយ៉ាងនោះតាមបំណងខ្លួនទេដឹង ! ការយល់ដូច្នេះ មិនត្រូវបែប ខុសទំនង មិនសមហេតុផលសោះឡើយ ៗ តាមពិតនោះ ធម្មជាតិទាំង៣ យ៉ាង គឺ

កាយ វាចា ចិត្តនេះ មានលក្ខណៈពិបាកបង្ហាត់ទូន្មានប្រៀនប្រដៅឲ្យបានបែបបទដោយអាការផ្សេង ៗ គ្នាយ៉ាងនេះ គឺកាយដែលអាចធ្វើអ្វីទៅបានគ្រប់យ៉ាង ដូចជាចេះសរសេរអក្សរល្អក្តី ចេះធ្វើគ្រឿងអលង្ការអំពីមាសនឹងប្រាក់សំរាប់តាក់តែងកាយនៃបុរសនឹងស្ត្រី ឲ្យមានក្បាច់ក្បូរក្បីរល្មិល្អក្តី ចេះគូររូបគំនូរដ៏វិចិត្រល្អក្តីដូច្នេះជាដើម លុះណាតែបានរៀនបានហាត់ឲ្យស្ទាត់ទុកជាមុន ទើបកាយនោះឯងអាចប្រើការឲ្យសម្រេចប្រយោជន៍ទៅបាន ។ ចំណែកខាងវាចាគឺសំដីសោតទៀតក៏ប្រហែលគ្នា ដូចជាចេះនិយាយការអ្វីឲ្យគេស្តាប់ឬក៏ចេះថ្លែងសុន្ទរកថាជាដើម ក្នុងទីប្រជុំជនមិនមានការទាស់ឆ្គងទៅបាន លុះណាតែបានគិតហាត់អានឲ្យស្ទាត់ទុកជាមុនសិនដែរ ទើបវាចានោះឯងជាសំដីពីរោះចាប់ចិត្តដល់អ្នកស្តាប់គួរគេយកតម្រាប់តាម ។ កាយនឹងវាចាទាំងពីរនេះជាធម្មជាតៈមើលឃើញច្បាស់ដោយភ្នែក ស្តាប់ឮច្បាស់ដោយត្រចៀកម៉េចគង់ពិបាកបង្ហាត់ទូន្មានម្ល៉េះទៅហើយ ចំណង់បើចិត្តជាអតិសុខុមជាតល្អិតក្រៃលែង គ្មានរូបពណ៌សណ្ឋានទ្រង់ទ្រាយអ្វីជាគ្រឿងប្រាកដសោះផង សមនឹងពិបាកទូន្មានយ៉ាងណាទៅទៀត, ហេតុនោះការទូន្មានហាត់ចិត្តឲ្យបានបែបបទបរិសុទ្ធស្អាតនោះ មិនមែនជាការងាយទេក្រជាទីបំផុត ព្រោះចិត្តនោះជាធម្មជាតល្អិតឆ្មារហួសវិស័យនឹងប្រដូចមានសន្ទុះលឿនរហ័សក្រៃលែងនឹងរកអ្វីមកប្រៀបឲ្យស្មើពុំបាន ជាធម្មជាតឆាប់ប្រែប្រួល, ឆាប់ញាប់ញ័រ, ឆាប់ឃ្វេងឃ្វាង, ឆាប់ផ្តេផ្តា ម្តងដូច្នេះ ម្តងដូច្នោះ នឹងចាប់ពត់តម្រង់ឲ្យត្រង់ល្អតាមបំណងរបស់ខ្លួនភ្លាមៗ

នោះ បានដោយក្រពេកណាស់, មិនមែនជាការងាយស្រួលដូចជនពួកខ្លះ ដែលមានសេចក្ដីយល់ឆ្វេងដូចបានពោលមកហើយនោះទេ ។

ម្យ៉ាងទៀត មានជនពួកខ្លះយល់ថា សេចក្ដីបរិសុទ្ធក្នុងជីវិតរបស់មនុស្សម្នាក់ៗដែលកើតមកក្នុងលោកនេះ គឺមកអំពីមានជាតិគោត្រត្រកូលពូជពង្សដ៏ខ្ពង់ខ្ពស់ ឬមកអំពីមានទ្រព្យសម្បត្តិច្រើន ទើបឈ្មោះថាជាសេចក្ដីបរិសុទ្ធស្អាតរបស់មនុស្ស ។ ការយល់ដូច្នេះទុកជាគំនិតយល់ឆ្វេងខុសឆ្ងាយគ្នានឹងសេចក្ដីពិត បើតាមពិតមែននោះ គឺសេចក្ដីបរិសុទ្ធស្អាតនៅត្រង់កាយ វាចា ចិត្ត ដែលមិនប្រព្រឹត្តធ្វើអកុសលកម្មណាមួយ ទើបចាត់ឲ្យឈ្មោះថាជាសេចក្ដីបរិសុទ្ធស្អាតរបស់មនុស្សក្នុងទីនេះបាន មិនមែនបរិសុទ្ធ ព្រោះតែមានជាតិគោត្រត្រកូលពូជពង្សដ៏ខ្ពង់ខ្ពស់នោះទេ មិនមែនបរិសុទ្ធព្រោះតែមានទ្រព្យសម្បត្តិច្រើននោះទេ, សមដូចព្រះពុទ្ធភាសិតថា:

កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា

សត្វទាំងឡាយ រមែងបរិសុទ្ធស្អាតដោយគុណធម៌ ៥ យ៉ាង(១) នេះ គឺ: កម្ម១ វិជ្ជា១ ធម៌១ សីល១ ជីវិតដ៏ឧត្ដម១ មិនមែនបរិសុទ្ធដោយសារគោត្រត្រកូលឬដោយសារទ្រព្យសម្បត្តិទេ ។

គុណធម៌ទាំង ៥ យ៉ាងនេះ ជាសេចក្ដីប្រតិបត្តិដុសខាត់ខាងផ្លូវកាយ

---

១ ធម៌៥យ៉ាងនេះមានសេចក្ដីអធិប្បាយក្នុងគម្ពីរ បរមត្ថមញ្ជុសាដីកាវិសុទ្ធិមគ្គត្រង់សីលនិទ្ទេស ។

ថា ចិត្តរបស់សត្វឲ្យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាង មិនមែនបរិសុទ្ធដោយហេតុដទៃឡើយ ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជនគួរជ្រាបថា បើប្រាថ្នាសេចក្តីបរិសុទ្ធិឲ្យកើតឡើងចំពោះខ្លួន ត្រូវតែខ្លួនយើងប្រតិបត្តិធ្វើបំពេញកិច្ចផ្ទាល់ដោយខ្លួនឯង ឬសេចក្តីសៅហ្មងកើតឡើងដល់ខ្លួនហើយ ត្រូវតែខ្លួនយើងលាងជំរះសំអាតផ្ទាល់ដោយខ្លួនយើង នឹងទៅពឹងពាក់រកអ្នកដទៃឲ្យគេធ្វើជំនួសខ្លួនពុំបានឡើយ, សេចក្តីនេះប្រៀបដូចជនពីរនាក់ ជនម្នាក់បរិភោគអាហារឆ្អែតស្កប់ស្កល់ហើយឃើញជនម្នាក់ទៀតមិនទាន់បរិភោគអាហារសោះ កំពុងមានសេចក្តីស្រេកឃ្លាន ហើយចង់ចែកឆ្អែតរបស់ខ្លួនទៅអ្នកដែលកំពុងឃ្លាននោះឲ្យបានឆ្អែតដូចខ្លួនផង តើជនឆ្អែតនោះអាចបេះរំលែកឆ្អែតចែកឲ្យទៅជនឃ្លាននោះខ្លះផងបានឬទេ? មួយទៀត ប្រៀបដូចជនម្នាក់កំពុងអន្ទះអន្ទែងដោយសេចក្តីស្រេកឃ្លាន បានឃើញជនម្នាក់ដើរចូលមកជិត ហើយចង់ចែកឃ្លានរបស់ខ្លួនឲ្យទៅជនម្នាក់នោះ ឲ្យគេជួយឃ្លានជួសខ្លួនផង តើជនឃ្លាននោះនឹងអាចបេះរំលែកឃ្លានចែកឲ្យទៅជនឯទៀតឲ្យគេជួយឃ្លានខ្លះផងបានឬទេ? តាមពិត ជនទាំងពីរនាក់គឺជនឆ្អែតនិងជនឃ្លាន នឹងបេះរំលែកឆ្អែតនិងឃ្លានឲ្យដល់គ្នានិងគ្នាទៅវិញទៅមក ពុំបានសោះឡើយមានឧបមាយ៉ាងណា; ឯសេចក្តីបរិសុទ្ធិនិងសេចក្តីមិនបរិសុទ្ធិនេះ រមែងកើតឡើងអំពីខ្លួនរបស់ខ្លួនឯង អ្នកណាមួយ នឹងអាចបេះរំលែកសេចក្តីបរិសុទ្ធិនិងសេចក្តីមិនបរិសុទ្ធិ ឲ្យដល់គ្នានិងគ្នាទៅវិញទៅមក ពុំបានសោះឡើយ ក៏មានឧបមេយ្យដូច្នោះឯង ។

ផលល្អនិងផលអាក្រក់ ដែលលេចចេញមកពីសេចក្តីបរិសុទ្ធិនិងសេចក្តីមិនបរិសុទ្ធិនៃកាយវាចាចិត្ត អាចបង្ហាញឲ្យឃើញជាក់ស្តែងក្នុងបច្ចុប្បន្ននេះដែលត្រូវទទួលសុខនិងទុក្ខផ្សេងៗ គ្នានោះ មិនចាំបាច់ទាញតួយ៉ាងមកចង្អុលប្រាប់ក្នុងទីនេះទេ សូមពិចារណាពិនិត្យសង្កេតមើល ដោយប្រាជ្ញាដ៏ជ្រាលជ្រៅនៅជុំវិញខ្លួន ក៏គង់ឃើញបានដោយមិនលំបាក ។

ហេតុនោះ ពុទ្ធសាសនិកជាអ្នកចង់បានសេចក្តីសុខនិងសេចក្តីចំរើនឲ្យកើតមានដល់ខ្លួនគ្រប់វេលានោះ ត្រូវតែតាំងសតិគឺស្មារតីឲ្យយាមល្បាតប្រចាំទ្វារកាយ វាចា ចិត្តជានិច្ច ដើម្បីទប់ពាំងអកុសលផ្សេងៗ មានអភិជ្ឈានិងទោមនស្សជាដើម កុំឲ្យចូលមកបៀតបៀនបាន; បើពុំដូច្នោះទេ មុខជានឹងត្រូវទទួលទុក្ខទោសគ្រោះថ្នាក់ណាមួយ តាមគួរដល់យថាកម្ម ទាំងក្នុងបច្ចុប្បន្ននិងបរលោក ព្រោះតែសេចក្តីមិនបរិសុទ្ធិនៃកាយ វាចា ចិត្តនោះឯងជាហេតុ ។

ពណ៌នាអំពីសេចក្តីបរិសុទ្ធិ ជាគូនឹងសេចក្តីមិនបរិសុទ្ធិ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។

---

# ប្រស្នាធម៌ ៦១

## ឃុនបណ្ណាគុរក្យ ប៊ូ-ប៉ូ រៀបរៀង

១ — សំនួរ: មានព្រះពុទ្ធភាសិត ១ បទថា "អត្តា ហិ អត្តនោ នាថោ ខ្លួនជាទីពឹងរបស់ខ្លួន" បើដូច្នោះ យើងកុំចាំបាច់យកព្រះរតនត្រ័យជាទីពឹងទៅឬអ្វី?

ចម្លើយ — មិនដូច្នោះទេ ព្រោះយើងត្រូវការធ្វើខ្លួនយើងឲ្យជាទីពឹងរបស់ខ្លួន ទើបយើងត្រូវតែយកព្រះរតនត្រ័យជាទីពឹង ដ្បិតថាខ្លួនយើងដែលនឹងយកជាទីពឹងរបស់ខ្លួនបាននោះ ត្រូវអាស្រ័យគុណធម៌សេចក្ដីល្អរបស់ខ្លួន ៗ ឯគុណធម៌សេចក្ដីល្អនោះ មានគោលជាច្រើនយ៉ាងណាស់ ប៉ុន្តែ បើយើងបានយកព្រះរតនត្រ័យជាទីពឹងទុកជាឫសគល់ហើយ គុណធម៌សេចក្ដីល្អដទៃ ៗ ក៏នឹងកើតឡើងតាមមកផង ទាល់តែក្លាយទៅជាអ្នកមានខ្លួនជាទីពឹងរបស់ខ្លួនបាន, ដោយមានហេតុផលយ៉ាងខ្លីប៉ុណ្ណោះ បានជាការដែលយើងយកព្រះរតនត្រ័យជាទីពឹង ឈ្មោះថាជាការធ្វើខ្លួនយើងឲ្យជាទីពឹងរបស់ខ្លួនបានដោយល្អ ៗ

២ — សំនួរ: មនុស្សដែលតាំងខ្លួននៅក្នុងរវាងចន្លោះកណ្ដាលបុណ្យ នឹងបាប គឺថាបុណ្យក៏មិនធ្វើ បាបក៏មិនធ្វើ លុះដល់គេស្លាប់ទៅហើយ តើគេនឹងបានទទួលសោយផលនៃការនៅក្នុងរវាងចន្លោះកណ្ដាលបុណ្យ នឹងបាប ឬយ៉ាងណា?

ចម្លើយ — មនុស្សដែលតាំងខ្លួននៅក្នុងរវាងចន្លោះកណ្ដាលបុណ្យ នឹងបាបដូច្នោះ គួរនឹងមានតែពួកកូនក្មេងដែលស្លាប់តាំងពីតូច ៗ នៅ

មិនទាន់ដឹងក្តី បើគេរស់នៅរហូតដល់ធំដឹងក្តីហើយ មិនមានអ្នកណាអាចនឹងតាំងខ្លួននៅកន្លែងចន្លោះកណ្តាលបុណ្យនឹងបាប អស់មួយជីវិតបានឡើយ ដ្បិតមនុស្សគ្រប់រូបច្រើនតែធ្វើទាំងបុណ្យទាំងបាបលាយឡំគ្នា ប៉ុន្តែតិចឬច្រើនប៉ុណ្ណោះ ៗ ម្យ៉ាងទៀត បើអ្នកណាវៀរចាកបាបបានហើយ អ្នកនោះក៏ឈ្មោះថាបានធ្វើបុណ្យ ដូចជាយើងមិនសម្លាប់សត្វជាដើម ក៏ឈ្មោះថាជាមនុស្សមានសីល ហៅថាសីលមយ-បុញ្ញកិរិយាវត្ថុ, ក្រៅពីនេះ នៅមានផ្លូវឲ្យកើតបុណ្យដទៃៗទៀតដល់៩ផ្លូវ ព្រោះហេតុនោះ កាលបើគេមិនធ្វើបាបដោយ កាយ-វាចា ហើយក៏ឈ្មោះថាគេបានធ្វើបុណ្យនៅក្នុងខ្លួន ៗ ប៉ុន្តែមានជនខ្លះមិនធ្វើបាបដោយផ្លូវកាយវាចាក៏ពិត តែផ្លូវចិត្តគង់មានអាក្រក់ ដូចជាឈ្មោះ(ក)ប៉ុនប៉ងនឹងសម្លាប់ឈ្មោះ(ខ) ប៉ុន្តែ មិនបានឱកាសនឹងសម្លាប់រហូតដល់អស់មួយជីវិត ៗ ការដែលឈ្មោះ(ក)សម្លាប់ឈ្មោះ(ខ)មិនបាននោះក៏ឈ្មោះថាមិនបានធ្វើបាប កាលបើគេមិនបានធ្វើបាបដូច្នេះ នឹងឲ្យឈ្មោះថាគេបានធ្វើបុណ្យផងដែរឬទេ? ត្រូវឆ្លើយថា ឈ្មោះ(ក)មិនបានសម្លាប់ឈ្មោះ(ខ)នោះក៏គ្រាន់តែផុតពីបាបផ្លូវកាយប៉ុណ្ណោះ ចំណែកចិត្តជាទុច្ចរិតឈ្មោះថាមនោទុច្ចរិត ព្រោះមានគំនិតព្យាបាទប៉ងនឹងសម្លាប់ឈ្មោះ (ខ), កាលបើចិត្តប្រកបដោយសេចក្តីអាក្រក់ដូច្នេះហើយ ឈ្មោះ(ក) នឹងបានរួចខ្លួនពីបាបម្តេចបាន ជាមនុស្សកណ្តាលម្តេចកើត ៗ ចំណែកកូនក្មេងដែលស្លាប់តាំងពីនៅតូចៗមិនទាន់ដឹងក្តីនោះ ទើបឈ្មោះថានៅកន្លែងចន្លោះកណ្តាលបុណ្យនឹងបាប ព្រោះវាមិនទាន់ចេះធ្វើបុណ្យឬធ្វើបាប

នៅជាទុកាសកម្មចាស់ដែលខ្លួនធ្លាប់ធ្វើទុកមកពីជាតិមុននោះ នឹងនាំបដិសន្ធិទៅទៀតមិនបេះអស់ឡើយ ។

៣– សំនួរៈ ចុះព្រះអរហន្ត ដែលឈ្មោះថាបណ្តេតបុណ្យនឹងបាបចេញបានហើយនោះ គេនឹងថាត់ថាលោកនៅក្នុងចន្លោះកណ្តាលបុណ្យនឹងបាបបានឬទេ ?

ចម្លើយ– មិនបានទេ ។ ព្រោះពាក្យថានៅក្នុងចន្លោះកណ្តាលបុណ្យនឹងបាបនោះជាពាក្យចង្អុលឲ្យឃើញថា អាចនឹងធ្វើបុណ្យឬធ្វើបាបទៀតក៏បាន ។ ឯព្រះអរហន្តផុតចាកបុណ្យនឹងបាបទាំង ២ យ៉ាងដាច់ស្រឡះពិតមែន បានជាលោកបានឈ្មោះថាលះបង់បុណ្យនឹងបាបផងបានឈ្មោះថាបណ្តេតបុណ្យនឹងបាបចេញផង មិនមែនលោកនៅក្នុងចន្លោះកណ្តាលនៃបុណ្យនឹងបាបទេ ។

៤– សំនួរៈ ចុះបើព្រះអរហន្តលះបង់បុណ្យនឹងបាបបានហើយក៏ត្រូវតែឲ្យឈ្មោះថាលោកមិនធ្វើបុណ្យនឹងបាបមែនឬទេ ?

ចម្លើយ– មែនណាស់ហើយ ។ ព្រោះព្រះអរហន្តលោកមិនធ្វើបុណ្យនឹងបាបសោះ ។

៥– សំនួរៈ បើដូច្នោះ ការវៀរចាកបាបរបស់ព្រះអរហន្តនោះមិនរាប់បញ្ចូលក្នុងការធ្វើបុណ្យផងទេឬ ?

ចម្លើយ– មិនរាប់បញ្ចូលផងទេ ។ ព្រោះបើមានបាប (សេចក្តីអាក្រក់) ត្រូវតែមានបុណ្យ (របស់ដែលជុសលាងជម្រះសេចក្តីអាក្រក់ចេញ) ដូចជាវេលាមានភេគ ក៏ត្រូវតែមានថ្នាំកែ ថ្នាំត្រូវតែមានទុក

សម្រាប់ការពារកេត បំបាត់កេតប៉ុណ្ណោះ បើគេមិនធ្លាប់មានកេតសោះ ធ្វើម៉េចគេនឹងដឹងពាក្យថាថ្នាំបាន ។ បុណ្យនឹងបាបក៏ដូច្នោះដែរ ជាគូប្រាប្រាមគ្នាដោយត្រង់ ដ្បិតថាបើនៅមានបាបដរាបណា សេចក្ដីត្រូវការបុណ្យក៏នៅតែមានដរាបនោះ ប៉ុន្តែ ព្រះអរហន្តលះបង់បាបបានដាច់ខាត ហើយលោកមិនត្រូវនៅជាប់ជំពាក់នឹងបុណ្យទៀតទេ ឬលោកមិនត្រូវធ្វើបុណ្យ ដើម្បីដុសលាងជម្រះបាបតទៅទៀតឡើយ ដោយហេតុនេះព្រះអរហន្ត ទើបឈ្មោះថាផុតចាកបុណ្យនឹងបាបទាំង ២ យ៉ាងដាច់ស្រឡះហើយ ។ ឯការធ្វើរបស់ព្រះអរហន្ត គ្រាន់តែជាកិរិយាប៉ុណ្ណោះ មិនរាប់ថាជាការធ្វើបុណ្យឬបាបទេ ព្រោះលោកមិនជាប់ជំពាក់ដោយការធ្វើសេចក្ដីអាក្រក់ ឬ កំចាត់បង់សេចក្ដីអាក្រក់ សឹងខុសពីបុថុជ្ជនអ្នកលះបង់សេចក្ដីអាក្រក់មិនទាន់បានដាច់ស្រឡះ បានជាបុថុជ្ជនត្រូវតែធ្វើបុណ្យដើម្បីកៃខែដុសលាងជម្រះសេចក្ដីអាក្រក់ចេញ ដូចបាន អធិប្បាយមកនេះ ។

៦– សំនួរៈ ខន្ធ ៥ គឺរូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ដែលព្រះយោគាវចរត្រូវដឹងឲ្យត្រៃលែង, ត្រូវតែកំណត់ដឹង, មិនត្រូវលះបង់, មិនត្រូវចំរើន, មិនត្រូវធ្វើឲ្យជាក់ច្បាស់ នោះតើមានអត្ថាធិប្បាយដូចម្ដេច ?

ចម្លើយ– អធិប្បាយថា ខន្ធ ៥ ជាទុក្ខ ។ របស់ណាជាទុក្ខ របស់នោះត្រូវតែកំណត់ដឹង មិនត្រូវលះបង់ទេ ព្រោះការលះបង់នោះ ត្រូវលះបង់ហេតុនៃទុក្ខគឺតណ្ហា មិនត្រូវលះបង់តួទុក្ខគឺខន្ធ ៥ ដែលជាផលទេ ។

បើទុកជាអ្នកណាខំប្រឹងលះបង់ខន្ធ ៥ ឲ្យទាល់តែដល់ស្លាប់ខ្លួនផង អ្នកនោះ
ក៏នៅតែលះបង់ទុក្ខមិនបានដាច់ស្រឡះដែរ ប្រៀបដូចកំដៅនឹងភ្លើង,
កំដៅជាផលរបស់ភ្លើង យើងមិនអាចនឹងលត់កំដៅដែលជាផលបានទេ
បើយើងមិនចង់ឲ្យក្តៅ យើងត្រូវតែលត់ហេតុគឺភ្លើងចេញ កំដៅទើបបាត់
សូន្យអស់ទៅ ។ ឯទុក្ខនោះយើងមិនត្រូវធ្វើឲ្យជាក់ច្បាស់ទេ ព្រោះមិន
មែនជានិរោធ ព្រមទាំងមិនត្រូវចំរើនដែរ ព្រោះមិនមែនជាមគ្គ ។

ពាក្យដែលថាខន្ធ ៥ ជាទុក្ខក្នុងអរិយសច្ច នឹងថាជាទុក្ខត្រូវតែ
កំណត់ដឹងនោះ មានគោលអាងក្នុងធម្មចក្កប្បវត្តនសូត្រថា "សង្ខិត្តេន
បញ្ចុបាទានក្ខន្ធា ទុក្ខា ដោយខ្លី ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ" នឹង
ពាក្យថា "តំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យំ ... អរិយសច្ច គឺទុក្ខនេះ
ត្រូវតែកំណត់ដឹង" ។ សូម្បីបាលីដែលជាព្រះពុទ្ធភាសិតក្នុងទីដទៃ
ដូចក្នុងសឡាយតនវិភង្គសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសក ក៏បង្អុល
ប្រាប់យ៉ាងច្បាស់លាស់ថា "ភិក្ខុទាំងឡាយ ! ធម៌ដែលត្រូវកំណត់ដឹង
ដោយបញ្ញាដ៏ក្រៃលែង តើដូចម្តេច? គួរឆ្លើយថា "ឧបាទានក្ខន្ធទាំង ៥ គឺ
រូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ធម៌ទាំងនេះត្រូវកំណត់
ដឹងដោយបញ្ញាដ៏ក្រៃលែង ។

---

# រឿងធម្មទ្ធជបណ្ឌិត

ក្នុងគម្ពីរខុទ្ទកនិកាយ ទុកនិបាត

## លោក គាំ-ឌុំ

លេខាធិការការិយាល័យសារមន្ទីរអាល់បែរសារូ

ប្រែនិងរៀបរៀង

---

កន្លងកាលដែលកន្លងទៅហើយ នៅក្រុងពារាណសី មានព្រះរាជាមួយព្រះអង្គព្រះនាម យសបាណី ទ្រង់សោយរាជ្យប្រកបដោយធម៌ ។ ព្រះរាជានោះ មានសេនាបតីម្នាក់ឈ្មោះកាឡកៈ (ជាអ្នកជំរះក្តី), កាលនោះព្រះពោធិសត្វព្រះនាម ធម្មទ្ធជៈ ធ្វើជាបុរោហិត, មានខ្ទន់ប្រកេសអ្នកស្អិតស្អាងព្រះកេសាម្នាក់ ឈ្មោះ ឆត្តបាណី ។

ឯកាឡកសេនាបតី ជាអ្នកកាត់ក្តីស៊ីសំណូកហាក់ដូចជាស៊ីសាច់ខ្នងនៃព្រស្តផងដទៃ លុះបានសំណូកហើយទើបរក់សរវៃកាត់ក្តី ធ្វើជនដែលពុំមែនជាម្ចាស់របស់ឲ្យបានជាម្ចាស់វិញ គឺធ្វើអ្នកចាញ់ឲ្យឈ្នះវិញ ។

ថ្ងៃមួយ មានបុរសម្នាក់ដែលសេនាបតីនោះកាត់ក្តីឲ្យចាញ់គេហើយ កំពុងតែផ្គងដៃឡើងពោលកន្ទក់កន្ទេញដើរចេញមកអំពីវិនិច្ឆយដ្ឋាន បានប្រទះនឹងព្រះពោធិសត្វកំពុងតែដើរទៅគាល់បម្រើព្រះរាជា បុរសនោះក៏ម្នីម្នាចូលទៅលុតជង្គង់ក្រាបទៀបបាទានៃព្រះពោធិសត្វ ហើយនិយាយជំរាបថា "ឱលោកម្ចាស់អើយ ! មនុស្សប្រហែលយ៉ាងលោកមកប្រៀនប្រដៅនូវអាថិធម៌ដល់ព្រះរាជាយ៉ាងនេះហើយ កាឡកសេនាបតីនៅតែហ៊ានស៊ីសំណូកសូកអន្ទរកាត់ក្តីពុំសុចរិតយុត្តិធម៌ ធ្វើអ្នកក្តីដែលពុំមែនជាម្ចាស់

ឲ្យជាម្ចាស់របស់វិញបាន" រួចហើយក៏ថ្លែងរៀបរាប់ប្រាប់អំពីដំណើរដែល
ខ្លួនបាញ់នោះសត្វគ្រប់ដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វកើតមាន
សេចក្តីអាសូរករុណាណាស់ ក៏និយាយទៅនឹងបុរសនោះថា "បើដូច្នោះ
ចូរអ្នកតាមយើងមកចុះ យើងនឹងជំរះកាត់ក្តីឲ្យអ្នក" ហើយក៏នាំបុរសនោះ
ទៅឯសាលាវិនិច្ឆ័យ រើជំរះក្តីនោះ ធ្វើអ្នកជាម្ចាស់ឲ្យបានជាម្ចាស់របស់វិញ
ដោយយុត្តិធម៌ ។ ឯពួកមហាជនដែលមកប្រជុំគ្នាចាំមើលកុះករ ក៏ស្រែក
ឲ្យពរសព្ទសាធុការ, សូរសព្ទលាន់ឮទ្រហឹងអឹងកងរំពងដល់ព្រះរាជា
ទ្រង់ត្រាស់សួរថា វីអមាត្យ ចុះសំឡេងអ្វីហ្នឹង? ។ ពួកអមាត្យក្រាបបង្គំទូល
ថា សូមទ្រង់ព្រះមេត្តាប្រោស ធម្មទ្ធជបណ្ឌិតជំរះក្តីដែលកាឡកសេនាបតី
កាត់ដោយពុំសុចរិតយុត្តិធម៌ រើជំរះកាត់ឲ្យបានជាសុចរិតយុត្តិធម៌ឡើងវិញ
សូរសព្ទនោះមិញជាសព្ទសាធុការពរអស់ពួកមហាជនក្នុងទីនោះឯង ។

ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ ក៏ត្រាស់ឲ្យហៅព្រះពោធិសត្វ
មក ទ្រង់មានព្រះរាជឱង្ការថា 'តាំងពីថ្ងៃនេះទៅ ចូរអ្នកមកធ្វើជាចៅក្រម
វិនិច្ឆ័យកាត់ក្តីវិញចុះ យើងនឹងបានឮសំឡេងសព្ទសាធុការដែលជាសុខ
ស្រួលដល់ត្រចៀកផង ឯសេចក្តីចំរើនក៏នឹងមានដល់មនុស្សលោកផង"
ទើបទ្រង់លួងលោមអង្វរព្រះពោធិសត្វ ដែលជាអ្នកពុំមានប្រាថ្នានឹងធ្វើ
ការនុះសោះឲ្យទទួលព្រមមកអង្គុយក្នុងវិនិច្ឆយដ្ឋានសម្រាប់កាត់ក្តី ដោយ
សេចក្តីអាណិតអាសូរអ្នកក្តី ។ តាំងពីថ្ងៃនោះតទៅ ព្រះពោធិសត្វ
តែងទៅអង្គុយកាត់ក្តីធ្វើជនជាម្ចាស់ ឲ្យបានជាម្ចាស់វិញ ដោយសុចរិត
យុត្តិធម៌ (អ្នកក្តីបានសេចក្តីត្រេកអរ សុខចិត្តទាំងសងខាង) ។

ឯកាឡុកសេនាបតី តាំងពីថ្ងៃនោះទៅក៏លែងបានលាភសក្ការៈ ឥតមានឧរ.ណា គេកប់កេសោះ ម្ល៉ោះហើយក៏កើតមានចិត្តទោមនស្សព្រួយព្យាទើបចូលទៅក្រាបបង្គំទូលញុះញង់ព្រះរាជា ឲ្យយកទោសព្រះពោធិសត្វថា បពិត្រព្រះមហារាជ, សូមទ្រង់ព្រះមេត្តាប្រោស ធម្មទ្ធជបណ្ឌិតជាមនុស្សអាក្រក់មានចិត្តក្បត់ប៉ុនប៉ងប្រាថ្នាយករាជសម្បត្តិ របស់ព្រះអង្គគប់គ្រង ។ ព្រះរាជាទ្រង់ពុំជឿតាមបានហាមឃាត់សេនាបតីថា អ្នកកុំនិយាយយ៉ាងហ្នឹងទៀតឡើយ ។ ឯកាឡុកសេនាបតីក៏ច្បៀតរកឧបាយក្រាបបង្គំទូលតទៅទៀតថា សូមទ្រង់ព្រះមេត្តាប្រោស បើព្រះអង្គពុំទ្រង់ជឿតាមពាក្យទូលព្រះបង្គំទូលតាមពិតទេ សូមព្រះករុណាម្ចាស់ជីវិតទ្រង់ចាំទតមើលតាមបង្អួចកន្លែងវេលាដែលធម្មទ្ធជបណ្ឌិត ដើរមកចុះមុខជាទីងបានឃើញប្រាកដថា ធម្មទ្ធជបណ្ឌិតជាអ្នកធ្វើឲ្យអ្នកនគរទាំងអស់នៅក្នុងកណ្ដាប់ដៃខ្លួន ។ លុះព្រះរាជាទ្រង់ទតទៅឃើញពួកបរិសទ្យដែលមានច្រើនក្ដីទាំងប៉ុន្មានបានតាមហោមរោមធម្មទ្ធជបណ្ឌិតនោះហើយក៏ទ្រង់ជឿស្លុងហ្មោះអស់ពីព្រះទ័យ ដោយទ្រង់សំគាល់ថាជាបរិសទ្យទាំងនោះជាបំណុះចុះចូលរបស់ធម្មទ្ធជបណ្ឌិតពិតមែន, ទើបទ្រង់ត្រាស់សួរទៅកាឡុកសេនាបតីថា អើ! មែនហើយសេនាបតី បើយ៉ាងនេះតើយើងនឹងធ្វើដូចម្ដេចទៅហ្ន៎ ។

សេនាបតី— សូមទ្រង់ព្រះមេត្តាប្រោស យើងត្រូវតែសម្លាប់គាត់ចោលទៅទើបគួរ ។

ព្រះរាជា – ចុះយើងនឹងសម្លាប់ដូចម្ដេចបាន បើគាត់ពុំមានទោសធ្ងន់ជាឧឡារិកអធិកអធម្មសមគួរនឹងសម្លាប់សោះ ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស, ងាយទេ, មានឧបាយកលមួយ គឺយើងនឹងលើកយកអសយ្ហកម្ម (ការងារដែលគេមិនអាចធ្វើកើត) បង្គាប់ឲ្យគាត់ធ្វើ កាលបើធ្វើមិនកើតឲ្យយើងទេ យើងនឹងបានសម្លាប់គាត់ព្រោះទោសនោះ ។

ព្រះរាជា – អើ! សេនាបតី ចុះយើងនឹងឲ្យគាត់ធ្វើអសយ្ហកម្មដូចម្ដេចទៅ? ។

សេនាបតី – បពិត្រព្រះមហារាជ ធម្មតាបុប្ផាឧទ្យានដែលគេដាំក្នុងទីសារភូមិ លុះតែបានថែរក្សាដោយល្អអស់បីបួនឆ្នាំ ទើបមានផ្លែផ្កាបាន សូមព្រះអង្គត្រាស់ឲ្យហៅធម្មទ្ធជបណ្ឌិតនោះមក ហើយទ្រង់មានព្រះបន្ទូលថា នែអ្នកបណ្ឌិត យើងធ្លាប់បានទៅក្រសាលលេងក្នុងឧទ្យានចាស់មកជាយូរហើយ ឥឡូវនេះយើងត្រូវការនឹងក្រសាលលេងក្នុងឧទ្យានថ្មីវិញ វេលាថ្ងៃស្អែកនេះហើយ យើងនឹងទៅក្រសាលឧទ្យាននោះ បើដូច្នេះ ចូរអ្នកទៅតាក់តែងកសាងធ្វើឧទ្យាននោះឲ្យយើងជាឆាប់ឲ្យទាន់ក្នុងវេលាថ្ងៃស្អែកនេះ, កាលបើព្រះអង្គទ្រង់បង្គាប់ឲ្យធ្វើយ៉ាងនេះហើយ គាត់មុខជាធ្វើពុំកើតឲ្យទាន់កាលបានឡើយ ម្ល៉ោះហើយយើងនឹងសម្លាប់គាត់ ព្រោះទោសនោះបានដោយស្រួល ។

ព្រះរាជាក៏ត្រាស់ឲ្យហៅព្រះពោធិសត្វមក ហើយ ទ្រង់មានព្រះរាជឧង្ការបង្គាប់ថា នែអ្នកបណ្ឌិត យើងធ្លាប់ទៅក្រសាលលេងក្នុងឧទ្យាន

ចាស់មកជាយូរណាស់ហើយ ឥឡូវនេះយើងត្រូវការទឹងក្រសាលលេងកុងខ្មៅឡានថ្មីវិញ ថ្ងៃស្អែកនេះហើយយើងនឹងទៅក្រសាលខ្មៅឡាននោះ ប្អូនអ្នកទៅតាក់តែងកសាងធ្វើខ្មៅឡាននោះឲ្យយើងជាដាច់ ឲ្យទាន់ក្នុងវេលាថ្ងៃស្អែកនេះ បើអ្នកធ្វើពុំកើតទាន់កាលវេលាទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

ព្រះពោធិសត្វយល់ច្បាស់ថា "ការណ៍នេះប្រាកដជាកាឡកសេនាបតីដែលពុំបានសំណូកឈ្នានីសដល់អញ ហើយក្រាបទូលញុះញង់ព្រះពជាឲ្យសម្លាប់អញដោយពិត" ទើបក្រាបបង្គំទូលស្នងថា "សូមទ្រង់ព្រះមេត្តាប្រោសព្រះមហាពជ បើទូលព្រះបង្គំអាចនឹងធ្វើបាន, ថ្ងៃស្អែកនេះគង់នឹងបានដឹងការណ៍" លុះក្រាបបង្គំទូលដូច្នេះរួចហើយ ក៏ក្រាបបង្គំលាព្រះពជាទៅផ្ទះបរិភោគភោជនដ៏បរិសុទ្ធ ហើយចូលទៅដេកលើដំណេករំពឹងគិតរកឧបាយនឹងធ្វើខ្មៅឡាន ។

ខណៈនោះឯងក្តៅទៅដល់ព្រះឥន្ទ្រ ៗ ពិចារណាដឹងព្រះចិត្តនៃព្រះពោធិសត្វហើយក៏រហ័សរវៃចុះមក ចូលទៅកាន់ល្វែងសិរី ស្ថិតនៅឯអាកាស ហើយសួរទៅព្រះពោធិសត្វថា នែអ្នកជាបណ្ឌិត ចុះអ្នកគិតពីរឿងអ្វីហ្នឹង? ។

ពោធិសត្វ — ចុះអ្នកជាអ្វីមកសួរខ្ញុំ? ។

ព្រះឥន្ទ្រ — ខ្ញុំជាព្រះឥន្ទ្រ ណាអ្នក ។

ព្រះពោធិសត្វដឹងថាជាព្រះឥន្ទ្រហើយ ក៏ឆ្លើយប្រាប់ជាប្រញាប់ទៅវិញថា ព្រះពជាប្រើខ្ញុំឲ្យទៅតាក់តែងកសាងធ្វើខ្មៅឡានថ្មីថ្វាយឲ្យទាន់

នឹងយាងទៅក្រសាលក្នុងថ្ងៃស្អែកនេះ ខ្ញុំពុំដឹងធ្វើដូចម្ដេចនឹងធ្វើឧទ្យាន នោះឲ្យកើតទាន់បាន បានជាខ្ញុំពិតគិតក្នុងការនេះ ។

ព្រះឥន្ទ្រ – នែអ្នកបណ្ឌិត អ្នកកុំព្រួយបារម្ភអ្វីឡើយ ចាំយើងនឹងនិម្មិតឧទ្យានថ្មីប្រហែលដូចជាព្រៃនន្ទវ័ននឹងចិត្តលតាវ័នឲ្យអ្នកបាន ចុះអ្នកត្រូវការឲ្យយើងនិម្មិតធ្វើក្នុងទីណា? ។ ព្រះពោធិសត្វប្រាប់ទីកន្លែងឲ្យព្រះឥន្ទ្រនិម្មិតធ្វើឧទ្យាន, ព្រះឥន្ទ្រនិម្មិតបានស្រេចហើយក៏ត្រឡប់ទៅកាន់ទេវនគរវិញ ។ លុះព្រឹកឡើងព្រះពោធិសត្វបានឃើញឧទ្យានជាក់ច្បាស់ហើយក៏ម្នាទៅក្រាបបង្គំទូលព្រះរាជាថា សូមទ្រង់ព្រះមេត្តាប្រោសមហារាជ ឧទ្យានទូលព្រះបង្គំបានធ្វើថ្វាយព្រះអង្គរួចជាស្រេចហើយ សូមព្រះករុណាម្ចាស់ជីវិតទ្រង់យាងទៅក្រសាលចុះ ។ ព្រះរាជាបានជ្រាបហើយទ្រង់ក៏យាងទៅជាមួយនឹងសេនាបតី បានឃើញឧទ្យាននោះសឹងតែប្រដាប់ដោយព្រឹក្សលតាជាតិគ្រប់ពណ៌ ដំដេរដាសដោយផ្កាផ្លែត្រឹមត្រែដោយកំពែងមានពណ៌ដូចជាថ្មនោសិលាកំពស់ ១៨ ហត្ថ មានទ្វារនឹងប៉មនៅគ្រប់ទិស ព្រះរាជាឃើញហើយទ្រង់ត្រាស់សួរកាឡកសេនាបតីថា ធម្មទ្ធជបណ្ឌិតបានធ្វើឧទ្យានសម្រេចតាមយើងបង្គាប់ហើយ ឥឡូវនេះ តើយើងនឹងធ្វើដូចម្ដេចទៀត? ។

សេនាបតី – សូមទ្រង់ព្រះមេត្តាប្រោស មហារាជ បើគាត់អាចធ្វើឧទ្យានតែមួយយប់ប៉ុណ្ណោះកើតបានហើយ នឹងមិនអាចយករាជសម្បត្តិឯណាបាន យើងត្រូវតែបង្គាប់ឲ្យគាត់ធ្វើអស្ចារ្យកម្មតទៅទៀត ។

ព្រះរាជា – ចុះយើងឲ្យធ្វើដូចម្ដេចទៀត? ។

សេនាបតី — សូមព្រះអង្គទ្រង់បង្គាប់ឲ្យគាត់ជីកធ្វើជាស្រះបោក្ខរណី សីធំហើយដោយកែវ ៧ ពណ៌តទៅទៀតចុះ ។

ព្រះរាជាទ្រង់ទទួលព្រមតាមហើយ ក៏ត្រាស់ហៅព្រះពោធិសត្វមក មានព្រះរាជឧង្ការថា នែអ្នកអាចារ្យ អ្នកបានធ្វើឧទ្យានឲ្យយើងរួចហើយ ត្រូវតែអ្នកធ្វើស្រះបោក្ខរណីជាវិការនៃកែវ ៧ ពណ៌ ឲ្យសមគួរដល់ឧទ្យាននុះតទៅទៀត បើអ្នកពុំអាចនឹងធ្វើបានទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

ព្រះពោធិសត្វ — សូមទ្រង់ព្រះមេត្តាប្រោស បើទូលព្រះបង្គំអាចធ្វើបាន នឹងធ្វើថ្វាយព្រះមហារាជតាមសព្វព្រះរាជហឫទ័យ ។

វេលានោះ ព្រះឥន្ទ្រមកនិម្មិតស្រះបោក្ខរណីមានលំអធំលើសលុប មានកំពង់សំរាប់ចុះទៅ ១០០ មានជ្រុង ១០០០ សរឹងធំដេរដាសដោយផ្កាឈូក ៥ ពណ៌ ហាក់ដូចជាស្រះនន្ទបោក្ខរណី ។ លុះព្រឹកឡើងព្រះពោធិសត្វបានឃើញស្រះបោក្ខរណីនោះជាក់ច្បាស់ហើយ ក៏ចូលទៅក្រាបទូលព្រះរាជាថា សូមទ្រង់ព្រះមេត្តាប្រោស ស្រះបោក្ខរណីទូលព្រះបង្គំបានធ្វើថ្វាយព្រះអង្គរួចស្រេចហើយ ។

ព្រះរាជាបានឃើញហើយ ទ្រង់ត្រាស់សួរទៅកាឡកសេនាបតីទៀតថា នែសេនាបតី ចុះយើងនឹងធ្វើដូចម្តេចទៀត? ។

សេនាបតី — សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ប្រើអ្នកឲ្យធ្វើផ្ទះធំណាក់ឲ្យសមគួរដល់ឧទ្យាននោះតទៅទៀត ។

ព្រះរាជាទ្រង់ត្រាស់បង្គាប់ព្រះពោធិសត្វថា នែអ្នកអាចារ្យ ឥឡូវ

នេះត្រូវអ្នកធ្វើផ្ទះដំណាក់មួយ អំពីក្អកទាំងអស់ឲ្យបានសមរម្យដល់ឧទ្យាន និងស្រះបោក្ខរណីនេះតទៅទៀត បើអ្នកធ្វើពុំកើតឲ្យយើងទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

វេលានោះ ព្រះឥន្ទ្រមកនិម្មិតផ្ទះឲ្យព្រះពោធិសត្វទៀត ។ ព្រះពោធិសត្វបានឃើញផ្ទះនោះប្រាកដហើយ ក៏មកថ្វាយព្រះរាជាៗបានឃើញហើយទ្រង់ត្រាស់សួរទៅកាឡកសេនាបតីថា ឥឡូវនេះយើងនឹងធ្វើដូចម្តេចទៀត សេនាបតី?

សេនាបតី— សូមព្រះមហារាជត្រាស់ប្រើគាត់ឲ្យធ្វើកែវមណីឲ្យសមគួរដល់ផ្ទះនោះទៀតចុះ ។

ព្រះរាជាត្រាស់ហៅព្រះពោធិសត្វមកហើយទ្រង់បង្គាប់ថា នែអ្នកបណ្ឌិត ចូរអ្នកនិម្មិតធ្វើកែវមណី ឲ្យសមគួរដល់ផ្ទះដែលធ្វើអំពីក្អកនេះឲ្យយើងទៀត យើងនឹងបានដើរទៅក្រសាលឧទ្យានម្តងៗ ក្នុងវេលាយប់ដោយសារពន្លឺកែវមណីនោះ បើអ្នកនិម្មិតធ្វើពុំកើតទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

វេលានោះ ព្រះឥន្ទ្រមកនិម្មិតកែវមណីឲ្យព្រះពោធិសត្វទៀត ។ ព្រះពោធិសត្វបានឃើញច្បាស់ប្រាកដហើយ ក៏មកថ្វាយព្រះរាជាៗបានទតទៅឃើញហើយ ទ្រង់ត្រាស់សួរទៅកាឡកសេនាបតីថា នែសេនាបតី ចុះយើងនឹងធ្វើដូចម្តេចទៀត? ។

សេនាបតី— សូមទ្រង់ព្រះមេត្តាប្រោស ធម្មធជព្រាហ្មណ៍នេះជាមានទេវតាធ្វើឲ្យសម្រេចតាមសេចក្តីប្រាថ្នារបស់គាត់ បើដូច្នេះ សូម

ព្រះអង្គប្រើគាត់ឲ្យនិម្មិតធ្វើនូវរបស់ណាដែលទេវតាមិនអាចនឹងនិម្មិតបាន ធម្មតាទេវតាមុខជាមិនអាចនិម្មិតមនុស្ស ដែលប្រកបដោយអង្គ ៤ បានទេ ព្រោះហេតុនោះ សូមព្រះអង្គត្រាស់ប្រើគាត់ឲ្យនិម្មិតធ្វើឧយ្យានបាល (អ្នករក្សាឧទ្យាន) ដែលប្រកបដោយអង្គ ៤ នោះតទៅទៀតចុះ ។

ព្រះរាជាត្រាស់ហៅព្រះពោធិសត្វមកហើយ ទ្រង់មានព្រះរាជឱង្ការបង្គាប់ថា នែអ្នកអាចារ្យ អ្នកបានធ្វើឧទ្យាន ស្រះបោក្ខរណី ប្រាសាទធ្វើអំពីក្អកនឹងកែវមណីជាពន្លឺដល់ឧទ្យានជាដើម នោះសឹងតែបានគ្រប់សព្វហើយ ឥឡូវនេះ ចូរអ្នកនិម្មិតធ្វើឧយ្យានបាលម្នាក់ដែលប្រកបដោយអង្គ ៤ ឲ្យរក្សាឧទ្យានឲ្យយើងតទៅទៀត បើអ្នកនិម្មិតធ្វើពុំកើតទេ យើងនឹងយកទោសអ្នកដល់ជីវិត ។

ព្រះពោធិសត្វក្រាបទូលថា "សូមទ្រង់ព្រះមេត្តាប្រោស បើទូលព្រះបង្គំរកបានថ្ងៃស្អែកនេះគង់នឹងបានប្រាប" រួចហើយក្រាបថ្វាយបង្គំលាទៅផ្ទះបរិភោគភោជនាហារដ៏បរិសុទ្ធហើយក៏ចូលទៅក្នុងដំណេកដេកលក់ទៅ លុះដល់វេលាព្រឹកព្រាងបច្ចូសសម័យភ្ញាក់ឡើងអង្គុយលើទីដំណេកគិតតំបារណាថា "ព្រះឥន្ទ្រជាស្តេចទេវតាសឹងតែបាននិម្មិតរបស់ដែលអាចនឹងនិម្មិតបានសព្វគ្រប់ហើយ ប៉ុន្តែនៅពុំអាចនឹងនិម្មិតឧយ្យានបាលដែលប្រកបដោយអង្គ ៤ បានឡើយ បើយ៉ាងនេះហើយអញនឹងទៅស្លាប់តែម្នាក់ឯងឥតទីពឹងក្នុងព្រៃវិញប្រសើរ ជាងសេចក្តីស្លាប់ក្នុងកណ្តាប់ដៃអ្នកដទៃ" ព្រះពោធិសត្វគិតដូច្នេះហើយពុំមានប្រាប់អ្នកឯណាមួយឲ្យ

ដឹងឡើយ  ចុះអំពីប្រាសាទហើយក៏ចេញទៅតាមទ្វារធំដើរចូលទៅក្នុងព្រៃអង្គុយរំពឹងពិចារណាធម៌របស់សប្បុរសក្រោមដើមឈើមួយ ។

ព្រះឥន្ទ្របានដឹងហេតុនោះហើយក៏ក្លែងភេទជាថ្មើរព្រៃម្នាក់ដើរចូលទៅរកព្រះពោធិសត្វហើយសួរថា "នែព្រាហ្មណ៍ អ្នកជាមនុស្សសុខុមាលជាតិធ្លាប់តែនៅជាសុខ  ពុំដែលឃើញទុក្ខលំបាកក្នុងកាលណាមុនឡើយ ឥឡូវនេះ អ្នកចូលមកអង្គុយនៅក្នុងព្រៃធ្វើអ្វីហ្នឹង?" រួចហើយទើបសួរដោយព្រះគាថាតទៅទៀតថា:

សុខំ ជីវិតរូបោសិ  រដ្ឋា វិវនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ  កបណោ វិយ ឈាយសិ ។

(នែព្រាហ្មណ៍)  អ្នកធ្លាប់តែនៅជាសុខ  ចេញចោលដែន (ដែលមានមនុស្សកុះករ) មកនៅក្នុងព្រៃស្ងាត់តែម្នាក់ឯងដូចជាមនុស្សកំព្រាអង្គុយជញ្ជឹងរំពឹងគិតនៅទៀបគល់ឈើ ក្នុងព្រៃ  តើអ្នកគិតដូចម្ដេចហ្នឹង? ។

ព្រះពោធិសត្វឆ្លើយថា

សុខំ ជីវិតរូបោស្មិ  រដ្ឋា វិវនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ  កបណោ វិយ ឈាយាមិ
សតំ ធម្មំ អនុស្សរន្តិ ។

ខ្ញុំធ្លាប់នៅជាសុខមែន  បានជាចេញចោលដែន (ដែលមានមនុស្សកុះករ) មកនៅក្នុងព្រៃស្ងាត់តែម្នាក់ឯង ដូចជាមនុស្ស

កំព្រា អង្គុយជញ្ជឹងរំពឹងគិតទៀបគល់ឈើក្នុងព្រៃ ខ្ញុំទុករំពឹងដល់ធម៌របស់សប្បុរស(១) ។

ព្រះឥន្ទ្រ – នែព្រាហ្មណ៍ បើគ្រាន់តែហេតុប៉ុណ្ណឹងសោះ ម្តេចក៏អ្នកបំបាច់មកអង្គុយគិតក្នុងទីនេះធ្វើអ្វី? ។

ពោធិសត្វ – ព្រះរាជាប្រើខ្ញុំឲ្យរកឧយ្យានបាលដែលប្រកបដោយអង្គ ៤ ខ្ញុំពុំអាចនឹងរកមនុស្សដែលប្រកបដោយអង្គ ៤ នោះបាន បានជាខ្ញុំគិតថា ប្រយោជន៍អ្វីអញនឹងស្លាប់ក្នុងកណ្តាប់ដៃអ្នកដទៃ អញនឹងចូលទៅនៅក្នុងព្រៃស្លាប់តែម្នាក់ឯងវិញប្រសើរជាង ខ្ញុំគិតដូច្នេះ បានជាខ្ញុំមកអង្គុយក្នុងទីនេះឯង ។

ព្រះឥន្ទ្រ – នែព្រាហ្មណ៍ ខ្ញុំជាព្រះឥន្ទ្រ ជាស្តេចនៃទេវតា ខ្ញុំបាននិម្មិតឧទ្យានជាដើមឲ្យអ្នករួចស្រេចហើយ ខ្ញុំពុំអាចនឹងនិម្មិតឧយ្យានបាលដែលប្រកបដោយអង្គ ៤ បានទេ ប៉ុន្តែខាន់ប្រកេសឈ្មោះឆត្តបាណីអ្នកស្អិតស្អាងព្រះកេសានៃព្រះរាជារបស់អ្នកនោះ គាត់ប្រកបដោយអង្គ ៤ កាលបើអ្នកត្រូវការដោយឧយ្យានបាល ចូរអ្នកទៅនិយាយនឹងខាន់ប្រ-កេសនោះឲ្យគាត់ធ្វើឧយ្យានបាលចុះ មុខជានឹងបានពុំខាន ។ ព្រះឥន្ទ្រឲ្យឱវាទដល់ព្រះពោធិសត្វ លួងលោមកុំឲ្យខ្លាចរួចហើយសក្កទេវរាជក៏ត្រឡប់ទៅកាន់ទេវបុរីវិញ ។ (មានត)

---

១ លោកធម៌ ៨ យ៉ាងគឺ លាភ, ពុំមានលាភ, យស, ពុំមានយស, និន្ទា, សរសើរ, សុខ, ទុក្ខ ហៅថាធម៌របស់សប្បុរស, សប្បុរសនោះបានដល់ព្រះពុទ្ធ បច្ចេកពុទ្ធ និងពុទ្ធសាវក ដែលជាបណ្ឌិត ព្រោះសប្បុរសទាំងនោះទុកជាលោកធម៌ទាំង ៨ នេះគ្របសង្កត់ក៏មិនកម្រើកញាប់ញ័រឡើយ (អដ្ឋកថា) ។

# បញ្ញាសជាតក

## ភាគទី ៤

បណ្ឌិតមហា ឈឹម-ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភិក្ខុបណ្ឌិត ព.ស.២៤៨៦, គ.ស. ១៩៤៣

---

## កនកវណ្ណរាជជាតក ទី ១៦

លោកអាចារ្យ ឥង-សមិទ្ធ វត្តលង្កា

ប្រែពីបាលី

---

ភូតបុព្វំ ភិក្ខវេ កនកបត្តេ នាម នគរេ កនកវណ្ណោ នាម រាជា កនកទេវិយា សទ្ធិំ តស្មិំ រជ្ជំ ការេសិ ។

ម្នាលភិក្ខុទាំងឡាយ, មានរឿងរ៉ាវពីព្រេងមកថា ក្នុងនគរកនកបត្ត មានព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាម កនកវណ្ណ សោយរាជសម្បត្តិក្នុងនគរនោះ ជាមួយនឹងព្រះរាជទេវី ព្រះនាម កនកា ជាឯកអគ្គមហេសី បានជាមហិស្សរាធិបតីក្នុងផែ្ទជម្ពូទ្វីបទាំងមូល ។ ទ្រង់មានបុរោហិតម្នាក់ចេះចប់សព្វសិល្បសាស្ត្រ ។ ថ្ងៃមួយ ក៏ទ្រង់មានព្រះរាជត្រាស់ហៅបុរោហិតនោះមកសួរថា លោកអាចារ្យ, ក្នុងឆ្នាំនេះ តើមាននក្ខត្តឫក្សជាសុខឬជាទុក្ខ ឬក៏កើតកលិយុគពុំដូរកាលបែបណា ? បុរោហិតបានស្តាប់ព្រះរាជឱង្ការ ក៏ក្រាបបង្គំទូលថា បពិត្រព្រះរាជសម្ភារ, ក្នុងឆ្នាំនេះបានសេចក្តីចំរើនច្រើនល្អណាស់, ប៉ុន្តែដល់កន្លង ១០ ឆ្នាំពីឆ្នាំនេះ

ទៅត្រូវរាំងភ្លៀងអស់ចំនួន ១២ ឆ្នាំ សូម្បីតែទឹកមួយដំណក់ក៏ឥតស្រក់មកជាប្រាកដ ។ ព្រះរាជាទ្រង់ស្តុតក្នុងព្រះរាជហឫទ័យភិតភ័យតក្កមា ដូចជាគេបាញ់ដោយសរដែលលាបថ្នាំពិស មានព្រះរាជហឫទ័យផ្អុកផ្អឹះទង្គឹះទុក្ខទោមនស្ស ទ្រង់ព្រះចិន្តាថា "ពួកមហាជនទឹងវិនាសអស់ហើយតើ! ជម្ពូទ្វីបសូន្យហើយតើ! បើម្ដឹងតើអាត្មាអញនឹងគិតធ្វើដូចម្ដេច?" លំដាប់នោះព្រះកូធរ ទ្រង់ឲ្យហៅពួកអាមាត្យទាំងឡាយមកប្រាប់ថា អ្នកពល់គ្នាបូរម្នាទៅឃោសនាប្រាប់ពួកស្ត្រីប្រជាក្នុងសកលជម្ពូទ្វីបថា អស់ពួកអាណាប្រជានុរាស្ត្រទាំងឡាយ ចូរអ្នកខំខ្វល់ខ្វាយភ្ជួររាស់ស្ទូងស្រូវទាំងស្រែប្រាំងស្រែវស្សា ទាំងទីទំនាបទីទួល កុំឲ្យមានសល់ចន្លោះស្រែណាមួយឡើយ ។ កាលបើអាមាត្យទាំងឡាយឃោសនាប្រាប់សព្វគ្រប់ដូច្នោះហើយ តពីនោះមកព្រះរាជាទ្រង់ត្រាស់បង្គាប់ម្ដងទៀតថា អស់ពួកអាមាត្យទាំងឡាយ ចូរដើរទៅសព្វស្រុកតូចធំនិគមជនបទ កំណត់មើលចំនួនស្រូវ របស់មនុស្សក្នុងស្រុកនោះៗ គ្រប់គ្នា ឲ្យដឹងថាស្រុកណាមានស្រូវចំនួនប៉ុន្មាន ។ អាមាត្យទាំងនោះ ក៏ខំចេញទៅពិនិត្យ បានដឹងចំនួនស្រូវហើយទើបត្រឡប់មកកាន់នគរ ក្រាបបង្គំទូលព្រះកូធរជាម្ចាស់ផែនដីវិញ ។ លុះឆ្នាំទី ១០ កន្លងទៅហើយ ក៏រាំងភ្លៀង សូម្បីតែ ១ ដំណក់ក៏គ្មានសោះ ។ ពួកមនុស្សក្នុងនគរទាំងអស់ ក៏កើតទុក្ខព្រួយខ្លោចផ្សា មនុស្សណាដែលមានសេចក្ដីស្រេកឃ្លានខ្លាំង ក៏ស្គាំងស្គមទ្រមស្លាប់ទៅក៏មានជាច្រើន ; មនុស្សខ្លះក៏ចងគ្នាជាពួក ១០០ នាក់ក៏មាន ១០០០ នាក់ក៏មាន ១០,០០០ នាក់ក៏មាន បបួលគ្នាធ្វើចោរកម្ម

លួចប្ញូនទាក់កាប់សម្លាប់គ្នាដេរដាស, កុងដម្ពូទ្វីប ជុំកុំទអសោចស្មុយ ស្ងួតៃតេោប ដូចជាព្រៃស្ពះសានឃានស្ងាត់ ។ លំដាប់នោះ ព្រះមហាក្សត្រទ្រង់ត្រាស់ចំពោះអាមាត្យទាំងឡាយថា ម្នាលអ្នកទាំងឡាយ កុងដម្ពូទ្វីបនេះ មានពួកខ្លែស្រុកខ្លែព្រៃតាក្លែក ខាំហែកសាកអស្រុក ស៊ីជាអាហារ ឥឡូវនេះ បើយើងនាំនាងកុលធីតាទាំងឡាយទៅកាន់ព្រៃ មិនយូរប៉ុន្មានទេ មុខជានឹងស្លាប់ផុតេហាះមិនលែង ។ តពីនោះមក សម្តេចព្រះរាមកជាកនកវណ្ណ ទ្រង់គង់កុងថ្លៃប្រាសាទ ត្រាស់ហៅពួកអាមាត្យមកប្រាប់ថា បើអ្នកទាំងឡាយចង់ទៅនៅទីណា ៗ ចូរនាំបុត្រភរិយាទៅតាមប្រាថ្នាចុះ ។ ពួកអាមាត្យទាំងនោះ ក៏ទូលតបព្រះរាជាវិញថា បពិត្រព្រះរាជសម្ភារ, យើងខ្ញុំទាំងអស់គ្នា ពុំព្រមទៅណាចោលព្រះអង្គទេ, ស៊ូតែស្លាប់ក្រោមព្រះបាទព្រះអង្គហើយ ។ លំដាប់នោះព្រះរាជា ទ្រង់ព្រះរាជទានស្រូវអង្ករដល់ពួកមហាជននឹងពួកអាមាត្យ ពល់ៗថ្ងៃ ដកបតែស្រូវនោះនៅសល់បន្តិចបន្តួច ទ្រង់កំបន្ទុយ បែរជាព្រះរាជទានត្រឹមតែគោជនដល់កូនអ្នកនគរនឹងកូនអាមាត្យអស់៤ខែទៀត ៗ ដល់ពេលក្រោយ ទ្រង់ទុកត្រាន់តែសោយជាមួយនឹងព្រះរាជបុត្រព្រះរាជទេពី បានត្រឹមមួយខែ ទ្រង់សំចៃទុកត្រាន់តែព្រះរាជបុត្រ១ព្រះអង្គប៉ុណ្ណោះ ។

ខណៈដែលព្រះរាជានៅសល់អង្ករតែមួយនាឡិ ព្រះរាជទេពីបានចំអិនទុកពុំទាន់បានសោយ ដូនជាមានព្រះបច្ចេកពុទ្ធ ១ អង្គគង់លើភ្នំគន្ធមាទន៍ មានអានុភាពធំ ដល់ត្រៃយនៃប្រាជ្ញាញាណ បានប្រមើលមើល

នូវសត្វលោកដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងផុតចក្ខុមនុស្សធម្មតាបានជ្រាបថា ពួកសត្វលោកនេះប្រមាទហើយតើហ្ន៎? សត្វលោកនេះប្រាកដជាមិនដែលឲ្យទាន រក្សាសីល ចំរើនមេត្តាភាវនាសោះ, មិនដែលបូជាចំពោះព្រះពុទ្ធព្រះធម៌ព្រះសង្ឃឡើយ, មិនដែលចិញ្ចឹមមាតាបិតា គោរពកោតក្រែងដល់ចាស់ព្រឹទ្ធាចារ្យ មិត្តសំឡាញ់ឡើយ, ពួកសត្វលោកនេះពេញជាប្រមាទមែន, បើតែម្ទេះៗមុខជាកេតាញ្យាធិក័យបរ្ណែ កើតជាច្រើនឡើងទៀតមិនខាន; ទើបព្រះបច្ចេកពុទ្ធនោះរំពឹងគិតតទៅទៀតថា អ្នកណាហ្ន៎! ដែលអាត្មាអញគួរចេញទៅសង្គ្រោះបាន? ឃើញមានតែព្រះបាទកនកវណ្ណរាជដែលជាពុទ្ធង្កុរបណ្ឌិតពុទ្ធវង្ស ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គក្នុងអនាគតកាល, បើដូច្នោះ គួរតែអាត្មាអញទៅសង្គ្រោះដល់ព្រះរាជានោះចុះ ៗ ទើបព្រះបច្ចេកពុទ្ធនោះហោះឡើងលើអាកាសវេហាស៍, ព្រះរាជានៅក្នុងទីណា, ក៏ឆ្ពោះព្រះកគ្រួសំដៅទៅទីនោះ ៗ អាមាត្យទាំងឡាយបានឃើញព្រះបច្ចេកពុទ្ធ ហោះឆ្ពោះទៅត្រង់ដូច្នោះ ក៏ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ, នុះហ្ន៎ ប្រហែលជាយក្ស ហោះមកចំពាស៊ីយើងទាំងឡាយហើយដឹង? ព្រះរាជាទ្រង់ទតឃើញព្រះបច្ចេកពុទ្ធ ក៏ត្រាស់ព្រះរាជឧង្ការថា ម្នាលអ្នកទាំងឡាយ, មិនមែនយក្សទេ, ព្រះបច្ចេកពុទ្ធទេតើ ៗ លំដាប់នោះ ព្រះបច្ចេកពុទ្ធចុះពាកអាកាស មកគង់ក្នុងទីចំពោះព្រះភក្ត្រព្រះរាជានោះ ៗ ព្រះមហាក្សត្របានឃើញព្រះបច្ចេកពុទ្ធ មានបាត្រទទេដូច្នោះ ទើបទ្រង់ព្រះចិន្តាថា "លោកម្ចាស់អង្គនេះប្រាកដជាត្រូវការបង្ហាន់បិណ្ឌបាត, ចុះបើអាត្មា

អញធ្លាក់ខ្លួនទៅជាមនុស្សកំសត់ទុគ៌តដល់ម្ល៉េះ នឹងប្រែគេទានដូចម្ដេចបាន" ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានច្រើនតែប្រាក់មាសកែវមុក្តា នឹងសំពត់ប៉ុណ្ណោះទេ, ចំណែកខាងអង្ករ សូម្បីតែមួយនាឡិក៏គ្មានដែរ ។ ព្រះបច្ចេកពុទ្ធក៏គង់នៅស្ងៀម ។ ព្រះរាជាលុះឃើញព្រះបច្ចេកពុទ្ធស្ងៀមដូច្នោះ ក៏ទ្រង់ត្រាស់យ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចំរើន, ទក្ខិណេយ្យបុគ្គល រកបានដោយកម្រពណាស់" ទើបទ្រង់ត្រាស់ហៅពួកមហាជនមកសួរថា អ្នករាល់គ្នាមានបាយខ្លះដែរឬ? ។ ព្រះនាងគនការាជទេពីទ្រង់មានព្រះរាជសវនីយ៍ទូលថា បពិត្រព្រះករុណា, ខ្ញុំម្ចាស់បានចំអិនបាយចំនួនអង្ករមួយនាឡិដែរ ទុកបំរុងតែព្រះរាជកុមារ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនាងទេវីដូច្នោះហើយ ក៏ទ្រង់យកព្រះស្ងោយចំណែកព្រះអង្គមក ទ្រង់ព្រះចិន្តាថា "បើប្រសិនណាជាអញបរិភោគអាហារទៅ ក៏មិនរស់នៅយូរប៉ុន្មានដែរ, ដូច្នោះគួរតែអាត្មាអញឲ្យទាន ព្រោះការឲ្យទានព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់សរសើរជាទីបំផុត" ហើយត្រាស់ជាបទព្រះគាថាថា

វិជ្ជុលតា យថា កាយោ តថា ភោគោ អសារកោ
អសារកស្ស ភោគស្ស សារមាទាយ បណ្ឌិតោ ។

ម្នាលអ្នកទាំងឡាយអើយ, រូបកាយយើងនេះឥតខ្លឹមសារទេ, ក្ដឹមតែដូចជាផ្លេកបន្ទោរដូច្នោះឯង, អ្នកមានប្រាជ្ញាត្រូវកាន់យកប្រយោជន៍ដែលមានខ្លឹមសារ អំពីភោគសម្បទដែលជារបស់ឥតខ្លឹមសារនោះ ។

លុះទ្រង់ត្រាស់ដូច្នេះហើយ ទើបព្រះកដាទ្រង់កាន់យកភាជន៍មាសដែលដាក់ពេញដោយបាយ ទ្រង់មានព្រះរាជហឫទ័យព្រះសរីរវយវៈផ្សព្វផ្សាយដោយបីតិ ចូលទៅកាន់សំណាក់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំទៀបព្រះបាទាទ្រង់ត្រាស់យ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះអង្គសង្គ្រោះដល់ខ្ញុំព្រះអង្គផងចុះ បង្អាន់បិណ្ឌបាតនេះ ទោះតិចក្តី ច្រើនក្តី ថោកទាបក្តី ថ្លៃថ្នាក្តី ដែលខ្ញុំព្រះអង្គប្រគេនដោយសទ្ធាជាសោមនស្ស សូមព្រះអង្គទទួលយកទាំងអស់ កុំទើសទាល់" ហើយទ្រង់ត្រាស់ជាបទព្រះគាថាថា

ឥមិនា ភត្តទានេន ន មយ្ហំ ឧបទ្ទវំ
តេន សព្វភវេ ហោតិ ពុទ្ធោ ហោមិ អនាគតេ
សំសារេ សំសរន្តោបិ មា មយ្ហំ វិកលត្តតា ។

ដោយចំណែកផលនៃភត្តទាននេះ សូមកុំឱ្យខ្ញុំមានឧបទ្រពចង្រៃអ្វីឡើយ, ដោយចំណែកផលនៃភត្តទាននេះ សូមឱ្យខ្ញុំបានសមប្រកបដោយសម្បត្តិគ្រប់ប្រការ ក្នុងភពទាំងពួង, ដោយចំណែកផលនៃភត្តទាននេះ សូមឱ្យខ្ញុំបានត្រាស់ជាព្រះពុទ្ធក្នុងកាលអនាគត, បើខ្ញុំនៅអន្ទោលទៅក្នុងសង្សារវដ្ត ក៏សូមកុំឱ្យខ្ញុំមានសេចក្តីខ្វះខាតដូច្នេះទៀតឡើយ ។

ព្រះបច្ចេកពុទ្ធទទួលភត្តហើយ ក៏អនុមោទនាជាបទព្រះគាថាថា

ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ
សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បណ្ណរសោ យថា ។

សេចក្តីប្រាថ្នា ដែលអ្នកប្រាថ្នាហើយយ៉ាងណា ក៏សូមឲ្យសម្រេចដល់អ្នកឆាប់រួសរាន់ទាន់ចិត្ត សូមដម្រិះត្រូវទាំងឡាយទាំងពួង ពេញដល់អ្នកដូចជាព្រះចន្ទរះច្បាស់ក្នុងថ្ងៃ ១៥ កើត ។

ព្រះបច្ចេកពុទ្ធអនុមោទនាដូច្នេះហើយ ទើបសំដែងសរសើរផលបុណ្យតទៅទៀតថា បុណ្យមានតំណួចតូចប៉ុនគ្រាប់ល្ង ដែលបុគ្គលធ្វើដោយចិត្តផងញាណសម្បយុត្ត រមែងសម្រេចផលប៉ុនភ្នំព្រះសុមេរុ, ពុំនោះសោតទេ ដូចជាពូជជ្រៃពូជអ្វីៗ ដែលដុះលូតលាស់ចំរើនឡើងជានិច្ចដូច្នោះឯង, ទានដែលបុគ្គលឲ្យហើយចំពោះទក្ខិណេយ្យបុគ្គលទាំងឡាយ ពុំដែលមានសេចក្តីអន្តរាយឡើយ, ទានដែលបុគ្គលមានចិត្តជ្រះថ្លាប្រកបដោយសទ្ធាឲ្យហើយ ទោះបីអាក្រក់ក្តី ល្អក្តី ក៏សប្បុរសទាំងឡាយតែងសរសើរ, លុះតែទានដែលបុគ្គលឲ្យដោយវៀរចាកសទ្ធា ទើបជាទានមិនសូវមានផលច្រើន ។

ព្រះបច្ចេកពុទ្ធ សំដែងសរសើរផលដូច្នេះរួចហើយ ក៏ហោះតាមអាកាសទៅភ្នំគន្ធមាទន៍វិញ ។ លោកឆាន់ចង្ហាន់នោះរួចស្រេច ក៏មហាមេឃបង្អុរភ្លៀងធ្លាក់មកក្នុងខណៈនោះ ដោយអានិសង្សទានរបស់ព្រះរាជានោះឯង ។ លំដាប់នោះ ពួកមហាជនឃើញមហាមេឃបង្អុរមកដូច្នោះ ក៏ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជសម្ភារ, គួរអស្ចារ្យណាស់ព្រះអង្គ! មហាមេឃបង្អុរភ្លៀងផ្គរកើតប្រាកដក្នុងថ្ងៃនេះ ក៏ប្រាកដជាដោយសារតេជះទានរបស់ព្រះអង្គនោះឯង ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ត្រាស់ថា មហាមេឃបណ្តាលឡើងដោយ

សារតែអានុភាពព្រះបច្ចេកពុទ្ធទេតើ ។ អាមាត្យទាំងឡាយក៏ក្រាបបង្គំទទួលព្រះរាជឱង្ការថា ពិតមែនព្រះអង្គ, មហាមេឃបង្អុររៀងធ្លាក់ក្នុងជម្ពូទ្វីបនេះដោយសារអានុភាពព្រះបច្ចេកពុទ្ធហ្នឹងឯង ។

មុខគួរឲ្យអស្ចារ្យ មុនដំបូងមហាមេឃបង្អុររៀងជំរះវត្ថុមិនស្អាត បង្ហូរទម្លាក់ទៅក្នុងមហាសមុទ្រ, តពីនោះមកបង្អុរផ្កាទិព្វ, តពីនោះបង្អុរធ្លាក់សុទ្ធតែបង្អែម, ពួកមនុស្សដើរណើមគ្នាបរិភោគគ្រប់គ្នា, តពីនោះបង្អុរសុទ្ធតែអង្ករអស់ប្រាំពីរថ្ងៃ, បង្អុរស្រូវអស់ប្រាំពីរថ្ងៃ, បង្អុរសំពត់ស្បៀកអស់ប្រាំពីរថ្ងៃ, បង្អុរប្រាក់អស់ប្រាំពីរថ្ងៃ, បង្អុរមាសអស់ប្រាំពីរថ្ងៃ, បង្អុរកែវប្រាំពីរប្រការអស់ប្រាំពីរថ្ងៃ, កនកនគរក៏ចំរើនរុងរឿងល្អដូចជាទេវលោកក្នុងកាលនោះឯង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ សម្តេចព្រះបរមសាស្តាចារ្យ កាលទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា

សទ្ធាបុព្វង្គមំ ទានំ អបិ កិញ្ចិ បិយេ កតំ
បសន្នា តីសុ កាលេសុ លភន្តិ តិវិធំ សុខំ
មានុស្សេសុ ផលំ ទេតិ សគ្គេសុ ច បរមំ សុខំ
តតោ ច និព្វានសុខំ សព្វទានេន លភតីតិ

ការឲ្យទាន មានសទ្ធាជាប្រធាន, ទោះបីវត្ថុបន្តិចបន្តួច ដែលបុគ្គលឲ្យហើយចំពោះបុគ្គលជាទីស្រឡាញ់ ហើយបុគ្គលនោះមានសេចក្តីជ្រះថ្លាក្នុងកាលទាំង ៣ រមែងបានសេចក្តី

សុខ ៣ ប្រការ គឺសេចក្ដីសុខក្នុងមនុស្សលោក សេចក្ដីសុខក្នុងទេវលោក សេចក្ដីសុខក្នុងព្រះនិព្វាន ។

អង្គសម្ដេចព្រះទ្រង់ញាណ ទ្រង់នាំធម៌ទេសនាមកសំដែងហើយ ទ្រង់ប្រកាសសច្ចធម៌ ៤ ប្រការចប់សព្វគ្រប់ហើយ ទើបទ្រង់ប្រជុំជាតកថា ព្រះរាជកុមារក្នុងកាលនោះ បែរវិលវិញមក បានជារាហុលកុមារ, អាមាត្យក្នុងកាលនោះ គឺសារីបុត្តជាធម្មទេសនាបតី, បុរោហិតក្នុងកាលនោះ គឺមោគ្គល្លាន, ព្រះនាងកនករាជទេវីក្នុងកាលនោះ គឺនាងយសោធរា, ព្រះបាទកនករាជក្នុងកាលនោះ គឺតួអង្គអញតថាគត ជាលោកនាថហ្នឹងឯង ។ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះចុះ ។

ចប់ កនកវណ្ណរាជជាតក ទី ១៦

## ផ្នែកអក្សរសាស្ត្រ

# និទានសុភាសិត

## ការប្រដៅមនុស្ស

### រឿងសតំបហារ (ការវាយ ១០០ រំពាត់)

ព្រះមហា ម៉ៅ-ខាន់ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

ការប្រដៅមនុស្ស ជួនកាលប្រើត្រឹមតែវាចាមួយយ៉ាង ក៏នៅមិនទាន់ឲ្យសម្រេចប្រយោជន៍បានសព្វគ្រប់ ព្រោះអ្នកស្តាប់មិនទាន់ជ្រួតជ្រាបដូចបទរៀនពិតៗ របស់ជីវិតដែលធ្លាប់បានប្រទះមកដោយខ្លួនឯង ។ ចង្អុលឲ្យឃើញងាយៗ ដូចប្រដៅក្មេងថា "កុំយកដៃទៅលូកភ្លើងលេង តែលូក ភ្លើងនឹងរលាកដៃ" ។ ដោយការពន្យល់តែត្រឹមប៉ុណ្ណោះ ក្មេងដែលមិនធ្លាប់បានស្គាល់ពិសរបស់ភ្លើងមកអំពីមុន ក៏មិនអាចជឿជាក់នូវពាក្យប្រដៅនោះបានទេ លុះតែកាលណាត្រូវភ្លើងរលាកដៃ ស្គាល់ពិសរបស់ភ្លើងដោយខ្លួនឯងហើយ ទើបឃើញពិតតាមពាក្យរបស់ចាស់ទុំប្រដៅ ។

ការសិក្សាផ្លូវលោក ដែលមានការល្បងពិសោធដោយរបស់ពិត ដូចការល្បងវិទ្យាសាស្ត្រ ក៏ដើម្បីលទ្ធផល គឺសេចក្តីយល់ចូលចិត្តច្បាស់លាស់ ។

ខាងផ្លូវព្រះពុទ្ធសាសនា ក៏រឹតតែឃើញទម្រង់ក្នុងរឿងនេះបាន

ដោយល្អណាស់ទៅទៀត ព្រោះព្រះសម្មាសម្ពុទ្ធ ដែលជាកំពូលអ្នកប្រដៅ ទ្រង់តែងប្រដៅឲ្យសមហេតុសមផល គួរដល់ចរិតអធ្យាស្រ័យនៃអ្នកស្តាប់, អ្នកស្តាប់ធ្លាប់ចូលចិត្តរឿងអ្វីស្និទ្ធស្នំមកហើយ ក៏ទ្រង់លើករឿងនោះឡើងជាតួយ៉ាងប្រៀបធៀប ដូចទ្រង់ប្រដៅអំពីរឿងប្រារព្ធសេចក្តីព្យាយាមដល់អ្នកដែលធ្លាប់ដេញពិណមកពីដើមថា បើព្យាយាមខ្លាំងហួសពេក ឬព្យាយាមធូរហួសពេកទៅ ក៏ដូចគ្នានឹងខ្សែពិណ ដែលគេរឹតឲ្យតឹងហួសពេក នឹងដាច់, បើធូរហួសពេក មិនឮ; ការប្រារព្ធសេចក្តីព្យាយាមក៏គប្បីឲ្យប្រព្រឹត្តទៅតែល្មមប្រមាណ កុំឲ្យខ្លាំងហួស ទាល់តែធ្វើកាយឲ្យលំបាកក្តៅក្រហាយ កុំឲ្យធូរថយហួស ទាល់តែកាយទៅជាខ្ជិលច្រអូសប្ទុទ្រមែន់ បើប្រព្រឹត្តឲ្យល្មមប្រមាណហើយ ក៏ដូចខ្សែពិណដែលរឹតតែយ៉ាងល្មមមិនឲ្យតឹងហួស មិនឲ្យធូរហួស ទើបដេញឮពីរោះ ។

ភិក្ខុកំឡោះមួយរូប លង់គំនិតស្រឡាញ់រូបឆោមរបស់នាងសិរិមា ដែលល្អស្រស់ រហូតដល់លែងឆាន់ចង្ហាន់លែងសឹង ។ លុះនាងសិរិមាអនិច្ចកម្មដោយរោគបច្ចុប្បន្ន ព្រះដ៏មានព្រះភាគ ត្រាស់សូមឲ្យស្តេចផែនដីដំកល់សពនាងទុកសិន ទាល់តែហើមរលួយកុំអាលឲ្យដុត ហើយឲ្យប៉ារ៉ស្តូប្រកាសប្រាប់មហាជនថា បើអ្នកណាត្រូវការចង់បានរូបនាងសិរិមា ឲ្យអ្នកនោះយកទ្រព្យប៉ុណ្ណោះប៉ុណ្ណោះមកចុះ ផ្តើមដាក់តម្លៃយ៉ាងថ្លៃបំផុត ហើយសម្រេចបន្ថយចុះមកយ៉ាងថោកបំផុត ទាល់តែថា បើអ្នកណាត្រូវការក៏នឹងឲ្យទទេ ។ ដោយឥតឲ្យគិតតម្លៃសោះ

សូម្បីដូចនោះ ក៏ពុំមានអ្នកណាត្រូវការ ផ្ទុយគ្នាស្រឡះអំពីកាលដែលនាងសិរិមាមានជីវិតរស់នៅ ។ ព្រះអង្គទ្រង់នាំភិក្ខុកំឡោះនោះទៅផងដែរ ដើម្បីឲ្យមើលសពនាងសិរិមាដែលកំពុងតែហើមរលួយ មានដង្កូវ មានទឹករងៃហៀរហូរ ។ នេះជាបទរៀនពិត ៗ ដែលធ្វើឲ្យភិក្ខុនោះឃើញសេចក្តីអសោចិ៍គួរខ្ពើម ឃើញសេចក្តីមិនទៀងទាត់ចំពោះរបស់ដែលខ្លួនធ្លាប់សំគាល់ថាល្អស្រស់នោះ ទាល់តែជាហេតុឲ្យភិក្ខុនោះមានស្មារតី លែងវង្វេងលង់គំនិតដូចកាលពីមុនទៀត ។

និទានដែលខ្ញុំនាំមកពោលតទៅនេះ គឺដើម្បីឲ្យឃើញសេចក្តីសំខាន់នៃការប្រដៅ ដោយបទរៀនពិតៗ ដូចពោលហើយនេះដែរ ។

ក្នុងអតីតកាល មានអ្នកប្រាជ្ញម្នាក់នៅក្នុងក្រុងដេរេជ្ជ ជាអ្នកជំនាញខាងក្បួនកាព្យ ឮដំណឹងថា ព្រះចៅកាសី ទ្រង់សព្វព្រះរាជហឫទ័យណាស់ក្នុងកាព្យឃ្លោង ក៏ធ្វើដំណើរទៅកាន់ក្រុងកាសី ដើម្បីចូលគាល់ លុះទៅដល់ទ្វារព្រះរាជវាំង អ្នកចាំទ្វារក៏ហាមឃាត់មិនឲ្យចូលសោះ អ្នកកាព្យនោះ ក៏ទទួចអង្វរដោយពាក្យស្រទន់ផ្អែមល្ហែមផ្សេង ៗ ទីបំផុតទាល់តែឆ្មាំទ្វារពោលថា "បើអ្នកត្រូវការចូល លុះតែឲ្យអ្វីជារង្វាន់ដល់យើងសិន, បើមិនដូចនោះ អ្នកនឹងខានបានចូលជាដាច់ខាត" ។ អ្នកកាព្យបានឮដូច្នោះ ទើបតបថា "ពេលនេះ តែមួយសេន ខ្ញុំក៏គ្មានដែរ, ប៉ុន្តែណ្ហើយចុះ កាលបើខ្ញុំចូលទៅហើយបានរង្វាន់អ្វីអំពីស្តេច សូមខ្ញុំបែងចែករង្វាន់នោះឲ្យអ្នកពាក់កណ្តាល" ។ ឆ្មាំទ្វារបានស្តាប់មានសេចក្តីត្រេកអរ ទើបអនុញ្ញាតឲ្យអ្នកកាព្យនោះចូលទៅ ។ អំពើ

ដូចនោះ សឲ្យឃើញថា ឆ្មាំទ្វារជាអ្នកមិនទៀងត្រង់ចំពោះមុខងាររបស់ខ្លួន ។

អ្នកកាព្យ លុះចូលទៅដល់ទ្វារជាន់ក្នុង ក៏ត្រូវឆ្មាំទ្វារជាន់នោះហាមឃាត់ទុកទៀត ទាល់តែចុះសន្យាថា នឹងចែករបស់ដែលបានអំពីស្ដេចឲ្យគេពាក់កណ្ដាល ទើបបានអនុញ្ញាតឲ្យចូលទ្វារនោះទៅដល់ព្រះរាជាបាន ។ លុះចូលទៅដល់ ថ្វាយបង្គំហើយក៏ពោលសំលោកពាក្យកាព្យដ៏ពីរោះតាប់ចិត្ត ញុំាងព្រះរាជហឫទ័យព្រះរាជាឲ្យរីករាយ យ៉ាងអស្ចារ្យ ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យចំពោះអ្នកកាព្យនោះ ទ្រង់ធ្វើសេចក្ដីគោរគោរព ហើយត្រាស់ហៅមន្ត្រីមក ឲ្យព្រះរាជទានដំរីមួយជារង្វាន់ដល់អ្នកកាព្យដែលឈ្លាសវៃនោះ ។ អ្នកកាព្យបានស្ដាប់ព្រះរាជឱង្ការ ទើបក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ! ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានដំរីជាច្រើនលើកមកហើយ, ដូច្នេះ ពេលនេះ ដំរីឃើញថាមិនជាប្រយោជន៍ដល់ទូលព្រះបង្គំជាខ្ញុំប៉ុន្មាន, ទូលព្រះបង្គំជាខ្ញុំ ទូលសូមព្រះរាជទានរបស់ឯទៀតក្រៅពីដំរីវិញ" ។

ព្រះរាជាទ្រង់តបថា "អើអ្នកប្រាជ្ញ ! លោកត្រូវការចង់បានរបស់អ្វីក៏ចូរថាមកចុះ បើយើងអាចឲ្យបាន យើងនឹងឲ្យ" ។ អ្នកកាព្យក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ! បើព្រះអង្គទ្រង់ព្រះមេត្តាប្រោសព្រះរាជទានរង្វាន់ហើយ សូមទ្រង់ព្រះមេត្តាប្រោសឲ្យវាយទូលព្រះបង្គំជាខ្ញុំឲ្យទាល់តែគ្រប់ ១០០ រំពាត់ជារង្វាន់ចុះ, ទូលព្រះបង្គំជាខ្ញុំ ពុំប្រាថ្នារបស់អ្វីដែលព្រះអង្គមិនអាចព្រះរាជទានបាននោះទេ" ។ ព្រះរាជាមិនទ្រង់

ជាបំណាំរបស់គេ ក៏ទ្រង់លំបាកក្នុងព្រះរាជហឫទ័យយ៉ាងខ្លាំង ទើបត្រាស់តបថា "លោកមហាកាព្យ! លោកចូរឈប់និយាយរឿងរ៉ាយដោយរំពាត់ទៅ បើលោកត្រូវការមាសប្រាក់កែវកងឯណា ក៏ចូរប្រាប់មកចុះ យើងនឹងរកជូនឲ្យបានគ្រប់យ៉ាង" ។ អ្នកកាព្យក្រាបទូលថា "ព្រះសម្មតិទេព! បើទ្រង់ព្រះមេត្តាប្រោសញ៉ាំងសេចក្ដីប្រាថ្នារបស់អ្នកកាព្យទាំងឡាយឲ្យពេញបរិបូណ៌ហើយ ក៏សូមទ្រង់ព្រះរាជទានរង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ ដោយការវាយឲ្យទាល់តែគ្រប់ ១០០ ចុះ, បើមិនដូចនោះទូលព្រះបង្គំជាខ្ញុំនឹងសូមថ្វាយបង្គំលា សូមសំរេសួស្ដីបវរមានដល់ព្រះអង្គចុះ" ។ កាលព្រះរាជា មិនទ្រង់ឃើញផ្លូវដទៃ ដើម្បីញ៉ាំងសេចក្ដីប្រាថ្នារបស់អ្នកកាព្យឲ្យពេញបាន ទើបត្រាស់បង្គាប់ឲ្យនាយតម្រួត ចាត់ការដាក់ព្រះរាជអាជ្ញា ។ លុះតម្រួតរៀបចំនឹងវាយ អ្នកកាព្យក៏ប្រាប់ថា "ឈប់បន្តិចមួយរំពេចសិនចុះលោក! នាយទ្វារពីរនាក់ ជាអ្នកត្រូវបានទទួលចំណែកនៃរង្វាន់នេះ ព្រោះខ្ញុំបានចុះសន្យានឹងគេទុកថា រង្វាន់ឯណាដែលខ្ញុំបានអំពីព្រះរាជានោះ ពាក់កណ្ដាលនឹងឲ្យដល់ឆ្មាំទ្វារទី ១, ពាក់កណ្ដាលទៀតនឹងឲ្យដល់ឆ្មាំទ្វារទីពីរ, បើពុំដូចនោះទេ នឹងមិនបានចូលមកគាល់ឡើយ ហេតុនេះ សូមបានសេចក្ដីសង្គ្រោះចែករង្វាន់ គឺការវាយខាងក្រោយនេះ ឲ្យដល់នាយទ្វារទាំងពីរនាក់នោះ ម្នាក់ពាក់កណ្ដាលចុះ ដើម្បីកុំឲ្យខ្ញុំដែលបានប្ដេជ្ញាហើយ នឹងខូចសច្ចៈ" ។

ដោយការអង្វរកររបស់អ្នកកាព្យនោះ នាយទ្វារទាំងពីរនាក់ ក៏ត្រូវ

គេនាំខ្លួនយកមកក្នុងទីបំពោះព្រះភក្រ្តព្រះរាជា ហើយវាយខ្លួនម្នាក់ ៩០ យ៉ាងធ្ងន់ៗ... ។

ព្រោះសេចក្ដីឃោរឃៅនៃអ្នកកាព្យនោះ ព្រះរាជាទីងមន្រ្តីមាន សេចក្ដីស្ញើចក្នុងចិត្តយ៉ាងខ្លាំង ក៏តាំងបន្ថែមសេចក្ដីរាប់អានចំពោះអ្នក កាព្យនោះយ៉ាងសន្ធឹក ។

នេះគឺជាបទរៀនពិតៗ ដែលអ្នកកាព្យនោះប្រដៅមនុស្សលោក ប៉ុន្តែកាលបើយកមកប្រៀបធៀបនឹងការប្រដៅ ដោយវិធីដូចគ្នា នៃ ព្រះពុទ្ធជាម្ចាស់វិញនឹងឃើញបានថា ព្រះអង្គមិនមែនដល់ទៅដាក់បទ រៀនដែលជាហេតុឲ្យបុគ្គលត្រូវរងអាជ្ញាដ៏ធ្ងន់យ៉ាងនោះទេ; ការទូន្មាន មនុស្សឲ្យបានល្អ របស់ព្រះអង្គនោះ គឺប្រើវិធីមិនឲ្យមានរបេសស្នាកស្នាម ដែលជាគ្រឿងសង្កេតមួយយ៉ាង រវាងការប្រដៅរបស់បុថុជ្ជន នឹងរបស់ ព្រះអរិយៈ ។

ចប់

# រឿងសៅរ៍សោយ

(សិរិសោរជាតក)

## ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រស្លឹករឹត

(តមក)

---

## បទពុំនោល

ពេលនោះស្រីស្រស់ធីតា នៅរួមរ៉ាសនា នឹងមហាក្សត្រាសិរសៅរ៍ ។
លុះលន់ដល់ទ្រង់គភ៌ទៅ ទើបរឿនស្រីពៅ ក្រាបជ្រាបដល់ទៅមាតា ។
ក្រាបក្រាមនាងទោមនស្សា ទើបត្មៀតយាត្រា ទៅទីធីតាជាត្រើយ ។
នាងសោកអមោក្ខតស្បើយ ធីតាម៉ែអើយ ម្ដេចឡើយមកមានស្វាមី ។
ទុរគតកំសត់អប្រិយ នេះគួរបុត្រី មានក្ដីខ្មាសពស្ត្រទាំងឡាយ ។
ថោកខ្លួនទាំងកូនទាំងម្ដាយ នេះគឺកម្មកាយ នៃម្ដាយនឹងកូនពុំខាន ។
ពីមុនម្ដាយគន់គិតស្មាន ថាកូនកល្យាណ នឹងបានប្ដីងប្ដានឥតបី ។
គិតគ្រេរថាមេមានប្ដី មានបុណ្យបារមី សិរីប្រសើរស្មើគ្នា ។
ម្ដាយឯងនឹងបែងទ្រព្យា រេហ៍ពលយោធា ឲ្យជាសម្បត្តិរតន៍ស្រី ។
នឹងបានប្ដីងប្ដានសិរី សោះខ្មាសសេនីយ មន្ត្រីការីទាំងឡាយ ។
តែនេះស្រីស្រស់ធោមធាយ គ្មានគិតចិត្តម្ដាយ នាងក្លាយជាមនុស្ស
ខុសក្រិត្យ ។
នាងធ្វើអំពើតាមចិត្ត ទៅផ្អែកផ្ដេកផ្ដិត រួមស្និទ្ធនឹងមនុស្សអស់ផ្លូវ ។

ពុំខានអំណាចម៉ែឪ ធ្វើឲ្យអាស្រូវ ម៉ែត្រូវរងគ្រោះខ្មាសគេ ។
នាងសោកអាមោក្ខសែនទ្វេ ប្រក្លាមនាងរេ វិលទៅលំនៅអាត្មា ។
ឯរ័តន៍សុទត្តកញ្ញា គ្រប់ទសមាសា ធីតាក៏ប្រសូតបុត្រ ។
ឱរសស្រួចស្រស់បំផុត លក្ខណៈបរិសុទ្ធ ចំហុតដូចជាអយ្យកោ ។
ល្អល្អះត្រចះសោភា ដូចជាទេព គួរតែស្នេហាពេកក្រៃ ។
ជ្រាបដល់កិន្នរត្តក្សត្រថ្លៃ ធ្វើឲ្យភូវន័យ រឹងក្រៃប្រឡាតក្រោធា ។
ស្ដេចទ្រង់គិតក្នុងទ័យា ខ្មាសអស់មនុស្សម្នា ប្រជានុរាស្ត្រទាសផង ។
គិតថា “យើះ! អាដកទង ទ្រនង់យង់យួង រំលងគន្លងអញអុ! ។
ពុំខានអំណាចបារមី ហ៊ានរួមប្ដី កូនស្រីសំឡាញ់អញឯង ។
បំពោតឥតកោតឥតក្រែង ឫកហាំបំផែង សំញែងហាក់ឯងចំណាប់ ។
ឲ្យនៅតទៅនាំអាប់ អញត្រូវទៅចាប់ មកកាប់សម្លាប់វាៗ” ។
ស្ដេចអត់សង្កត់ព្រះទ័យ ថ្ងៃមួយដៀសង្ស័យ រំពៃក្នុងចិត្តគិតថា ។
“សុទត្តរ័តន៍ធីតា ប្រសូតបុត្រា ជាតិជាយូរយារហើយហោង ។
អញសោកចង់ទតឃើញម្ដង ឱរសនោះហោង រូបប្រាណសណ្ឋាន
ម្ដេចទៅ” ។
គិតស្រេចសម្ដេចចមពៅ ប្រើស្នំដែលនៅ ឲ្យទៅយកពៅមកណា ។
សុំផងត្រសងយាត្រា ចូលទូលធីតា កញ្ញាសុទត្តរ័តន៍ស្រី ។
“បតិត្រាវរមិត្តក្សត្រី ដ្បិតព្រះនរបតី ចក្រីប្រើខ្ញុំទាំងអស់ ។
ឲ្យមកនាំយកឱរស ទៅថ្វាយទ្រង់យស ចំពោះនឹងទតបានម្ដង” ។
កាលនោះស្រីស្រស់ច្បាស់ច្បង ស្ដាប់ស័ព្ទហើយហោង ទួនល្អឹកឥត

ឃាត់ឡើយណា ។

នាងបែរមកផ្តែផ្តាំថា "នាងនាំបុត្រា កុមារឧត្តមខ្ញុំទៅ ។
ថ្វាយថ្វាត់មហាក្សត្រចមពៅ កុំទុកយូរនៅ នាងត្រូវឆាប់យកមកខ្ញី" ។
គ្រាហ្នោះទើបអស់ទាសី ទទួលសវនីយ ឃ្លាតខ្ញីលាលាកចាកឋាន ។
ចេញចាកដំណាក់មកឋាន បីបុត្រកល្យាណ ប្រែប្រាណតោះឋាន
រាំងជ័យ ។

លុះដល់ចូលគាល់ក្សូវន័យ នាំបុត្រវៃ ៗ ឃ្លាតខ្ញីថ្វាយថ្វាត់ក្សត្រា ។
ទសពលទតយល់ទត្តា ល្អត្តកាយា បក្រាស្នេហាឥតបី ។
ស្តេចត្រាស់ជម្រាស់ទៅខ្ញី "ហៃពៅពិសី ចូរមករកតាណាពៅ" ។
ត្រាស់ហ្នោះទ្រង់ស្ទុះសំដៅ ត្រកងព្រះពៅ មកឱបក្រសោបបមបី ។
រូបរឹតបុម្ពិតសិរសី ហើយទើបនរបតី បក្រីជម្រាស់ត្រាស់ថា ។
"ពៅវ៉ើយ! ចូរស្បើយទុក្ខា នៅទេះហើយណា ជីតារក្សាពិទ័ត្ថ ។
ជីតានឹងប្រើសេវ័ក ទៅនាំម្តាយអ្នក មកនៅលំនៅបុរី ។
តែថាបិតាអ្នកខ្ញី តាស្អប់ឥតបី មេត្រីប្រណីពុំបាន ។
នឹងចាប់សម្លាប់ពុំខាន ចូរពៅស្នោះស្នាន កុំក្រោធប្រឡោតនឹងតា" ។
ត្រាស់ស្រេចសម្តេចក្សត្រា មានព្រះរាជា ឧង្ការឲ្យជាងប្រញាប់ ។
ធ្វើអស់របស់ប្រដាប់ មាសប្រាក់សម្រាប់ ស្រេចស្រាប់រន្ទាលប្រាលផ្អៅ ។
ក្សត្រក្សាន្តប្រទានទៅពៅ ស្រេចស្តេចគេចហៅ ឲ្យស្នំមេនំទាំងឡាយ ។
នាំពៅយកទៅថ្វាត់ថ្វាយ ទើរតាមឆាយ ជាម្តាយឯនាយប្រញាប់ ។
ហើយទ្រង់ឲ្យជាងផងចាប់ សាងអាងមាសឆាប់ ប្រដាប់សម្រាប់នត្តា ។

ស្រង់ទឹកក្រសាលអាត្មា   ស្រេចថ្វាត់ក្សត្រា   ចក្រាឲ្យទៅចៅខ្ញី ។
ស្តេចផ្តាំឲ្យស្នំតាសី   បំរើក្សត្រី   ឃាតខ្ញីមើលប្តីស្រីរ័តន៍ ។
បើមោះឃើញខុសក្លាំងក្លាត់   ចូរចោមឡោមព័ទ្ធ ទៅចាប់សម្លាប់ជាម្តង ។
អញឯងទឹងតែងពលផង   នាំកូនអញហោង វិលផ្គងមកនៅកំងណា ។
អស់ស្នំប្រណាម្យក្សត្រា   បីរាជនត្តា   យាត្រាដំរង់ត្រង់ទៅ ។
លុះដល់មណ្ឌលស្រីពៅ   ពុំអង់រង់នៅ   ចូលទៅថ្វាយបុត្ររ័តន៍ថ្លៃ ។
ទេវីម្នាម្នីលូកដៃ   ទទួលបុត្រថ្លៃ   ថ្នមថ្នាក់លើកដាក់លើភ្លៅ ។
ថើបបុត្រវិស្សុតពាលពៅ   ក្រសោបឱបទៅ   បំបៅផ្ចាប់នៅឱក ។
ឯក្រុមស្រីស្នំនោះណា   បំរើធីតា   នៅនាដំណាក់នោះនៃ ។
ឱហាគសង្វាតរវៃ   រកទោសជៀស្តដ័យ   ឥតបីឃើញអ្វីខុសឡើយ ។
ទើបស្នំជំនុំគ្នាហើយ   គិតថា "វុំអើយ ! យើងស្នំទាំងក្រុមនេះខ្ញី ។
ស្វែងទោសបុរសកាឡី   ពុំបានសេចក្តី   បានអ្វីទៅទូលរាជា ។
ប្នោះភ្លូវយើងត្រូវមាយា   ធ្វើជាឈ្មោះគ្នា   និន្ទាពូដជៅសន្តាន ។
គាត់សោះតនឹងក្រោធពុំខាន   ពួកយើងនឹងបាន   ចាប់ទោសកំហុស
គាត់ហោង" ។
គិតប្លោះទើបអស់ស្នំផង   ដេរគ្នាអឹងកង   ដៀនដងដៀមដាមក្សត្រា ។
រាដេរតាមតែទឹងថា "អាដែងឯងណា   កំព្រាព្រាត់ញាតិឃ្លាតផៅ ។
មិនមានទីឋានលំនៅ   ពូជផងហ្វងសៅ   កំឡោះដូចជាក្អែក្អា ។
បានតែសូមគេភោគ្គា   រួបរស់ដីរ៉   ដោយសារអ្នកផ្សារទេនៃ ។
ដើរលុងតែក្នុងព្រឹក្សព្រៃ   ទើបតែបែរវៃ   ឃាតខ្ញីចូលមកស្រុកអាយ ។

បានសុខស្រណុកសប្បាយ ប៉ុកពាលមាល្បាយ ឥតបើនឹងធ្វើការអ្វី ៗ
ដូចជ្រូកដេកស្លុកនៅដី ក្បែរស្នូកចំណី ឃ្លាតខ្លីចាំឆីប៉ុណ្ណោះ ៗ
អញឯងឥតត្រៃក្រឯងសោះ អាដែនឯងស្មោះ ប្រអូសដេកចាំតែស៊ី ៗ
ឥតស្គាល់មណ្ឌលទិសទី ឥតបេះរកស៊ី កាប់ឆ្កាធ្វើការអ្វីទេ ៗ
ស៊ីដេកស៊ីដេកផ្ទុកគេ អាខ្វាសគេទេ បូរគ្នេរពិនិត្យគិតគន់” ៗ
ព្រះបោះទ្រង់យសហួសធន់ ទ្រង់ក្ដុកទុក្ខជូន ស្រពន់អួលអន់ចុក ៗ
ភ្ងាំងភ្ងក់ស្រក់ទឹកនេត្រា ទ្រង់ទប់ចិន្ដា យាត្រាគេចវេះជៀសខ្វី ៗ
ទើបស្ដេចវិលគេចស្រដី ប្រាយប្រាប់មហេសី ថា “ហៃប្អូនស្រីពុំងា ៗ
ខ្លួនបងបានវេទនា ព្រាសព្រាត់ឃ្លាតឃ្លា ជើខ្លួនឯងស្ងួនថ្ងើមថ្ងៃ ៗ
បងបានសុខសាន្ដសព្វថ្ងៃ ឥឡូវនេះនៃ មកជន់ទុក្ខជួនកន្ទង ៗ
ឥឡូវនេះកូវខ្លួនបង ខានបានស្នេហ៍ស្នង ស្នេហ៍ស្និទ្ធនឹងមិត្តពិសី ៗ
បូរម៉ឺមនាងកុំទុក្ខថ្វី បងលាក្សាប្រិយ ដោយក្ដីអាល័យក្រៃណា ៗ
បូរពៅនាងនៅរក្សា បិញ្ចឹមបុត្រា . នៅត្រាបងឃ្លាឃ្លាតទៅ ៗ
ដ្បិតបងបានងហ្វងសៅ ពីមុនណាពៅ ពុំសូវក្ដួលក្ដៅឡើយណា ៗ
ពេលនេះទុក្ខហួសបើថា ដែលបងនេះណា ពុំធ្លាប់ប្រសព្វមកឡើយ ៗ
បងលាពុំងាសិនហើយ នៅចុះប្អូនអើយ ឲ្យបានសុខសាន្ដណាពៅ ៗ
„ដ្បិតបងមិនអាចនិត្យនៅ ចិត្តអួលក្ដួលក្ដៅ ទុក្ខជន់លើសលន់សព្វដង ៗ
វរមិត្ត ! បើឥតពីបង បូរស្ងួននួនល្អង មានប្ដីជាថ្មីចុះណា ៗ
ដ្បិតបងមួហ្មងចិន្ដា ខ្វាសមេត្តា ជៀលថាដេដ្ឋកាឡ្វី” ៗ
កាលណោះវររ័តន៍ក្សត្រី ស្ដាប់ស័ព្ទស្វាមី ស្រដីប្រាយប្រាប់ប្ដោះឯង ៗ

នាងអួលក្តៅក្តួលកណ្តែន ទ្រន់សោកកន្សែង ថ្វាថ្វៃនទូលថា

“ម្ចាស់អើយ ៗ

ហេតុម្តេចស្តេចគេចកន្តើយ ចោលខ្ញុំម្ចាស់ហើយ ពុំគិតអាណិតបុត្រា ៗ

ពុំគួរស្តេចយកព់តា ពួកព់ទាសា ធ្វើជាអារម្មណ៍ធំឡើយ ៗ

បើថាដេដ្ឋាកន្តើយ ពុំគិតខ្ញុំហើយ គួរគិតអាណិតបុត្រថ្លៃ” ៗ

ស្តេចផ្ទៀងស្តាប់នាងហើយនៃ បានក្សាន្តព្រះទ័យ ប្រណីតអាណិត

បុត្រា ៗ

គិតគួរអាសូរដីតា ពុំចេញចរចា ក្សត្រាស្ងៀមស្ងាត់និត្យនៅ ៗ

ទាសីកាឡីឃោរឃៅ យល់ស្តេចគេចនៅ ពុំក្រោធពិរោធតិចឡើយ ៗ

គិតថា “វ៉ឺ! គ្នាយើងអើយ ដៀលតិះម៉ូះហើយ គាត់ធ្វើយពុំខឹងដល់តិច ៗ

ឥឡូវយើងត្រូវធ្វើកិច្ច កំណល់កលល្បិច ចាប់ទោសគាត់នោះទៀត

ណា ៗ

មក! មក! យើងយកបុត្រា បង្អត់ក្រយា ឲ្យផ្អុំស្រែកយំទៅនៃ ៗ

ហើយនាំគ្នាចាំរំពៃ ពួនមើលគាត់វៃ ក្រែងខុសកំហុសដូចម្តេច ៗ

យើងនឹងរិលរឹងរំពេច ទូលដល់សម្តេច ឲ្យស្តេចជ្រាបសេចក្តីហោង” ៗ

គិតស្រេចក៏គេចជាមួន នាំគ្នាត្រសង ត្រកងបីអង្គបុត្រា ៗ

យកទៅដាក់នៅឯកា បង្អត់ក្រយា ហើយពួនឃ្លាំចាំនៅ ៗ

ទារសស្រស់ស្រាលពាលពៅ ផ្ទុំលក់យូរទៅ ភ្ញាក់ប្រាណបានដឹងឡើងខ្ញុំ ៗ

ឃ្លានស្រែកឱ្យរពេកឥតបី សេះសោះអស់ក្តី ក្សត្រថ្លៃយាសយែក

ស្រែកយំ ៗ

រីឯពួកមេស្រីស្នំ ក៏ខំសំងំ ពុំធ្វើជំនួសសោះឡើយ ។
កាលណោះក្សត្រក្សាន្តត្រាណត្រើយ ឮបុត្រយំហើយ ទៅថ្នមបីបម
ត្រកង ។
លួងលោមប្រលោមសាសង មិនឲ្យមានហ្មង នឹងបុត្រពិស្សុតសោភា ។
បីត្រង់ជម្រង់ទៅនា អាងមាសសោភា ដាក់បុត្រពិស្សុតឲ្យស្រង់ ។
កុមារក្រសាលតាមចង់ សប្បាយអស់អង្គ នៅក្នុងអាងមាសនោះណា ។
ទះទឹកក្អេបទឹកក្រយា ត្រជាក់អាត្មា លោតលេងកញ្ចេងសប្បាយ ។
ស្រាកស្រាន្តកំសាន្តព្រះកាយ ទឹកខ្ចាតខ្ចាត់ខ្ចាយ ស្រោចស្រង់ដល់
អង្គចក្រី ។
ពួកស្នំមេនំអប្រិយ យល់កប់នរបតី ទទឹកអស់អង្គកាយា ។
ក៏ក្រួតនាំហេតុនោះណា ទូលដល់ក្សត្រា បិតាថា "ខ្ញុំគ្រប់ប្រាណ ។
យល់អ្នកអបលក្ខណ៍សាមាន្យ ពុំកោតក្សត្រក្សាន្ត ឈ្លានពានហ៊ានផ្ទួត
គគ្គា ។
នៅក្នុងអាងមាសសោភា សម្រាប់រាជា ម្ដេចក៏ពុំកោតជៀសជ័យ ។
សូមទ្រង់ជ្រាបក្នុងព្រះទ័យ ខ្ញុំម្ចាស់នេះនៃ ទូលចំពិតពុំមុសា ។
កិច្ចវត្តបមក្សត្របិតា ជ្រាបភាពហ្នោះណា ក្រេវក្រោធក្រឡេតឥតបី ។
ស្ដេចទ្រង់ឧក្ការថា "វ៉ុ! អស់មុខមន្ត្រី ពេជ្ឈឃាដក៏អាមាត្យគ្រប់ប្រាណ ។
ចូរផ្ដុំជួបជុំឆាប់ថ្កាន នាំគ្នាគ្រប់ប្រាណ ឃាត់ខ្ញីចាប់ប្ដីធីតា ។
ចងខ្ញីកុំបីមេត្តា នាំយកមកកា៎ ឃុំខាំងដាក់ឃ្នាងច្រវាក់ ។
ហើយគោងខោកថងវាយដាក់ តាមបុណ្យតាមសក្តិ អាជ្ញាអញប្រើទៅខ្ញី ។

អញឯងនឹងតែងសេនីយ ទៅនាំបុត្រី វិលខ្មីមកកាំងវិញហោង" ។
អាមាត្យនុហាតត្រិសង នាំគ្នាជាមួង ឆ្ពោះទៅលំនៅយោវម៉ាន ។
លុះដល់មណ្ឌលទីឋាន និមិលកល្យាណ សុខត្តវរត័ន៍កញ្ញា ។
ទើបចូលទៅទូលនាងថា "បតិត្រធីតា ក្សត្រាទ្រង់ប្រើយើងខ្ញុំ ។
ឲ្យមកចាប់យកស្វាមី សូមវត្តក្សត្រី ជាបច្ចាស់ក្នុងព្រះទ័យា" ។
កល្យាណពុំបានដឹងថា ស្វាមីជាយា ពជាយកទោសព្រោះអ្វី ។
ពុំទាន់បានសួរសេចក្តី ពេជ្ឈឃាដក៍ឃាតខ្មី ប្រញីចាប់ប្ដីកល្យាណ ។
ក្ដូវកិតញ៉ាវអគ្គប្រាណ ភ័យក្រៃប្រមាណ ពុំហ៊ានស្រដីអ្វីឡើយ ។
និមិលកល្យាណត្រាណត្រើយ យល់អស់ហ្នោះហើយ នាងក្តាមទៅតាម
យ៉ាងឆាប់ ។
និមិលបន្ទូលប្រញាប់ ថា "អ្នកមកចាប់ តើព្រោះកំហុសម្តេចហោង ។
ទើបមកចាប់យកជាម្តង អម្ចាស់បច្ចាស់បង យកទោសពីព្រោះខុសអ្វី" ។
អ្នកចាប់ប្រញាប់ទូលខ្មី ថា "សូមក្សត្រី ប្រណីសន្ដោសទោសា ។
យើងខ្ញុំធ្វើតាមអាជ្ញា ក្សត្រថ្ងៃបិតា បញ្ជាយើងខ្ញុំគប់ប្រាណ ។
ឲ្យមកចាប់យកទៅថ្កាន យើងខ្ញុំពុំបាន ដឹងជានថាព្រោះអ្វីឡើយ" ។
បានជាប្រសកាពអស់ហើយ កល្យាណត្រាណត្រើយ ចូលទៅលំនៅ
អាត្មា ។
យកព្រះឱរសស្នេហា ខ្មីឃ្មាតយាត្រា ត្រាប់ត្រង់ដំរង់ពុរី ។
ទឹងទៅគាល់ហ្វាចក្រី បមកពនរបតី ក្សត្រថ្ងៃបិតាព្រះនាង ។
លុះដល់បានយល់ហើយក្លាង នោះទើបព្រះនាង ក្រាបកបទៀបបាទ
ក្សត្រក្សាន្ត ។

អន់អួលខ្សឹកខ្សួលសន្ទាន លន់ពន់ប្រមាណ កល្យាណប្រះប្រាណ
កន្ទ្រេន ។
សោយសោកអមោក្ខកណ្ដែង ជីតាថ្វាថ្លែង ថែងថង់ទូលអង្គបិតា ។
" កាលមុនស្ដេចពុំមេត្តា ដោយហេតុហោក ទៀងទាយទំនាយទូលខ្ញុំ ។
ថាកូននឹងមានស្វាមី កំសត់អប្រិយ ឥតពូជឥតពង្សវង្សផៅ ។
ទើបព្រះអម្ចាស់ចមទៅ ពុំទ្រង់សៅដៅ បណ្ដេញខ្ញុំចេញជាម្ដង ។
ឥឡូវនេះត្រូវកន្ទង ខ្ញុំមានផ្ដង បំបួនដូចក្បួនហោរពិត ។
សូមទានប្រោសប្រាណដល់ចិត្ត មេត្តាអាណិត ករុណាខ្ញុំជាបុត្រី ។
ដំណើរអំពីស្វាមី មានទោសខុសអ្វី ទើបប្រើអាជ្ញាទៅចាប់ ។
ចងយកនាំមកប្រញាប់ ពុំទ្រង់ត្រាស់ប្រាប់ នូវទោសកំហុស
ឡើយណា ។
ខ្ញុំម្ចាស់សូមព្រះបិតា សន្ដោសទោសា ករុណាមេត្តាស្វាមី ។
បើទ្រង់ពុំចង់ប្រណី នោះសូមនរបតី សំឡាប់ទាំង ៣ ទៅហោង ។
ទាំងកូនទាំងខ្លួនខ្ញុំផង ព្រមគ្នាជាម្ដង សោះរេងទុក្ខៈទោសវេទនា ។
មិនរង់កម្មកង់វេរ ម្នាក់ឯងកំព្រា ខ្ញុំការងតឹងចង្អៀត ។
បើកូននឹងមានប្ដីទៀត នោះនឹងបង្វៀត ពូជពង្សព្រះវង្សក្សត្រា ។
ហាក់ដូចស្រីខូចលក្ខណា ម្នះសូមបិតា មេត្តាករុណាកូនផង " ។
សុទ្ធិវតីច្បាស់ច្បង មាតានោះហោង នាងក៏អង្វរស្វាមី ។
" ខ្ញុំម្ចាស់សូមព្រះចក្រី អាសូរប្រណី បុត្រីពិសីត្រាណត្រើយ ។
បើថាពុំអាសូរឡើយ ខ្ញុំម្ចាស់ច្បាស់ហើយ លាស្លាប់ទៅចាប់ជាតិថ្មី " ។

កិច្ចវត្តបមក្សត្របុរី ស្ដាប់ស័ព្ទមហេសី ទីនស្រីបុត្រីវរមិត្រ ៗ
ទ្រង់បានស្រោកស្រោទក្នុងចិត្ត ទ្រង់គិតអាណិត ទើបត្រាស់ដកស់ទៅថា ៗ
" ហឺយ ៗ! មករ៉ឺយ! សេនា ចូរឃាតយាត្រា ទៅដោះអ្នកទោសនោះនៃ ៗ
នាំវាមកនាក់ងដ័យ ប្រញាប់ឆាប់ៃវ កុំបីកន្ដើយឡើយហោង" ៗ
អាមាត្យឲ្យហាតត្រិសង នាំគ្នាជាមួង វិលទៅដោះនូវក្សត្រក្សាន្ត ៗ
ដោះស្រេចនាំស្ដេចមកប្ថាន ដល់មណ្ឌលឋាន ប្រញប្រាណបង្គំចមទៅ ៗ
បមក្សត្រព្រះបាទសិរីសៅរ៍ ទ្រង់គង់សៀមនៅ ពិតពុំបង្គំស្ដេចឡើយ ៗ
ស្ដេចទតយល់ហេតុហ្នេះហើយ ពុំអង់លង់ឡើយ កំក្រោធពិរោធខ្លាំងក្លា ៗ
បន្ទូលតិះដៀលទៅថា "មឹងឯងនេះណា ជាតិជាមនុស្សខ្សត់អត់ប្បាប់ ៗ
ឃើញថាអាត្មាទីងស្លាប់ អញទីងឲ្យកាប់ ឥឡូវពុំនៅយូរឡើយ ៗ
មឹងខុសជាប់ទោសហ្នេះហើយ មេចគេបកន្ដើយ ដាក់ដៃពុំថ្វាយបង្គំ ៗ
ឬថាជាការគួរសម ទើបមឹងរឹងដំ - អកពុំសំពះអញឡើយ" ៗ

## បទមណ្ឌូកគតិ

កាលអើយកាលណោះ សិរីសៅរ៍ព្ទោះកន្ដើយ
"បពិត្រក្សត្រអើយ ខ្ញុំទូលបង្គំនេះណា ៗ
នឹងក្រាបប្រណម្យ បង្គំបរមក្សត្រា
មិនគួរទេណា ព្រោះថាអាត្មាគុនអាថ៌ ៗ
មានទោសខុសធ្ងន់ ត្រោះដល់ជីពជនសូន្យស្លាប់
ពុំសមពុំគាប់ នឹងក្រាបថ្វាយថ្វាត់ក្សត្រក្សាន្ត ៗ
គួរតែសេនីយ អាមាត្យមន្ត្រីគ្រប់ប្រាណ (មានត)

# កណ្ឌទី ២២

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នករាល់វ័ឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯចូឆូកាលលើកទ័ពទៅតាំងកណ្ដាលយប់នោះ ក៏ដេញទាហានចូលវាយស្រុកស៊ៀវផាយបាន រួចលើកទៅវាយយកស្រុកឈីជីវទៀត ឯប៊ុតុក, ប៊ុហង, កាន់យ៉ុង ដែលឡៅពីឲ្យនៅរក្សាស្រុកនោះក៏គិតគ្នាថា "ទ័ពចូឆូលើកមកគ្រានេះធំពន្លឹកណាស់ មុខជាយើងតទល់មិនបានទេ" គិតហើយក៏នាំគ្នារត់ចេញពីស្រុកនោះទៅ នៅតែតាន់តេងទាល់ប្រកទឹង រកផ្លូវរត់ទៅពុំរួច ក៏បើកទ្វារស្រុកចេញទៅទទួលចូឆូដើម្បីឲ្យបានសេចក្ដីគាប់ប្រសើរ ៗ ចូឆូឃើញដូច្នោះក៏មានចិត្តត្រេកអរលើកទាហានចូលទៅ ទើបដាក់កំហិតហាមថា "កុំឲ្យនរណាធ្វើអន្តរាយដល់ប្រជាជនដែលនៅក្នុងស្រុកឲ្យបានសេចក្ដីទុក្ខក្ដៅឡើយ" ហើយប្រឹក្សានឹងសេនាទាហានទាំងពួងថា "យើងនឹងលើកកងទ័ពទៅវាយយកស្រុកហៃហ្វៀទៀត តើអ្នកទាំងឡាយនឹងយល់ឃើញដូចម្ដេច? ។

ស៊ិនហុកឆ្លើយថា ខ្ញុំបាទពុំដំណឹងថា ឡាំពីឲ្យគួនអ៊ូនៅរក្សាត្រ-សារក្នុងស្រុកហៃហ្វី ដែលលោកនឹងលើកទ័ពទៅពាយនោះគួរណាស់ បើបង្អង់ហើយ អ៊ូនសៀវគង់នឹងលើកទ័ពមកជួយ ហើយនឹងនាំយកគ្រប់គ្រងឡាំពីទៅបាន ។ ចូចូតបថា គួនអ៊ូនោះមានថ្វីដៃខ្លាំងពូកែណាស់ ហើយឈ្លាសវៃក្នុងការសឹកសង្គ្រាម យើងចង់បានខ្លួនគួនអ៊ូមកចិញ្ចឹមទុកជាសេនាឯកតទៅ ឥឡូវនេះយើងនឹងប្រើបំរើឲ្យទៅនិយាយបញ្ចុះបញ្ចូលគួនអ៊ូទើបបាន ។ គុយកៃឆ្លើយថា ឯចិត្តគួនអ៊ូនោះទៀងត្រង់នឹងឡាំពីណាស់ ដែលនឹងប្រើបំរើទៅនិយាយបញ្ចុះបញ្ចូលនោះ ខ្ញុំបាទយល់ថាគួនអ៊ូមុខជាមិនចុះចិត្តផងទេ បើនរណាដែលទៅបញ្ចុះបញ្ចូលនោះ គង់តែគួនអ៊ូសម្លាប់ចោល ។

តៀវលៀវឆ្លើយថា ខ្ញុំបាទនឹងគួនអ៊ូធ្លាប់ស្គាល់ពប់អានគ្នាមក គ្រានេះ ខ្ញុំសុំយកអាសាទៅនិយាយបញ្ចុះបញ្ចូលគួនអ៊ូឲ្យបាន ។ ឆៀយ៉ុកថា ដែលតៀវលៀវនឹងទទួលយកអាសាទៅបញ្ចុះបញ្ចូលគួនអ៊ូនោះមុខជាគួនអ៊ូមិនមកទេ ខ្ញុំបាទសូមយកអាសាទៅបញ្ឆោតឲ្យគួនអ៊ូចេញពីស្រុកហៃហ្វី ហើយបើឃើញគួនអ៊ូអស់ដម្រិះគិតវេលាណា សឹមឲ្យតៀវលៀវទៅនិយាយបញ្ចុះបញ្ចូលជាក្រោយទើបបាន ។

ចូចូក៏សួរឆៀយ៉ុកថា អ្នកនឹងគិតទៅបញ្ឆោតដូចម្តេចខ្លះ? ។ ឆៀយ៉ុកឆ្លើយថា លោកចាប់ទាហានឡាំពីទុកបានជាច្រើន ត្រូវឲ្យបំណាច់រង្វាន់ឲ្យពេញចិត្ត ហើយបង្គាប់ឲ្យធ្វើតាមពាក្យយើង គឺលែងខ្លួនឲ្យវិលចូលទៅក្នុងស្រុកវិញ ហើយប្រាប់ថាខ្លួនរត់ទាំងនោះសុទ្ធតែរត់រួច

មក បើយើងទឹងធ្វើការសង្គ្រាមវេលាណា ក៏ឲ្យពួកចាំធ្វើកលសឹកខាងក្នុង ហើយឲ្យចាត់ទាហានទៅច្បាំងបញ្ឆោត បើគួនអ៊ូដេញចេញមកដល់ក្រៅស្រុកហើយ ត្រូវឲ្យទាហានដែលពួនបង្កប់ទាំងសងខាងផ្លូវនោះព័ទ្ធទុកឲ្យជាប់ រួចសឹមប្រើអ្នកមានដម្រេះប្រាជ្ញាទៅនិយាយបញ្ចុះបញ្ចូល ឃើញថាគួនអ៊ូទឹងព្រមចំណុះយើងដោយងាយ ។ ចូចូយល់ត្រូវដូចគំនិតខ្លួន ក៏ឲ្យហៅរកទាហានទៀតដែលចាប់ទុកបានប្រហែល ៤០ នាក់នោះមកដល់ចូចូ ក៏ឲ្យបំណាច់រង្វាន់គ្រប់គ្នាជាច្រើន រួចបង្គាប់បញ្ជាតាមពាក្យជៀយ៉ុកថាគ្រប់ប្រការ ។ ទាហានទាំងនោះក៏ចូលទៅរកគួនអ៊ូក្នុងស្រុកហែហ្វី ហើយប្រាប់គួនអ៊ូថា យើងខ្ញុំទាំងអស់គ្នាបានរួចមកពីកងកងទ័ពចូចូ ។ គួនអ៊ូឮហើយក៏គ្មានចិត្តគិតសង្ស័យ យកទាហានទាំងនោះប្រើប្រាស់តាមត្រូវការ ។

លុះពេលយប់យាម ៣ ចូចូប្រើហែហូទុនលើកទាហាន ៥ ពាន់ជាកងពួនបង្កប់ ហើយបង្គាប់ស៊ុយឡុងទឹងទៅជួយថា បើគួនអ៊ូដេញហែហូទុនចេញមក ឲ្យអ្នកឯងពល់គ្នាលើកទាហានចាំស្កាត់គួនអ៊ូទុកកុំឲ្យវិលទៅក្រោយបាន ត្រូវឲ្យតច្បាំងការពារឲ្យល្មមតែកំឡាំងទាំងសងខាងហើយកុំធ្វើគួនអ៊ូឲ្យមានសេចក្ដីអន្តរាយឡើយ ។ ទាហានទាំង ៣ នាយទទួលបង្គាប់ហើយក៏លើកទ័ពតម្រង់ទៅស្រុកហែហ្វីទាំងយប់នោះ ។ ចូចូក៏លើកទាហានតាមទៅតាំងនៅពីចម្ងាយ ហែហូទុនក៏លើកទាហានចូលទៅជិតកំពែងស្រុកហែហ្វី ។ គួនអ៊ូក្រឡេកឃើញកងទ័ពមកតាំងនៅផ្ទាប់កំពែងដូច្នោះ ក៏សម្ងំមិនបានចេញតតាំងគ្រាន់តែប្រើទាហានឲ្យឡើង

រក្សាសែនបន្ទាយជុំវិញ ។ ហែហូទុនមិនឃើញគួនអ៊ូចេញមកច្បាំង ក៏ប្រើកូនទាហានទៅស្រែកជេរគួនអ៊ូជាពាក្យទ្រគោះអសុរសុរផ្សេងៗ ។ គួនអ៊ូឮដូច្នោះក៏ខឹងខ្លាំងណាស់ ទើបប្រមូលទាហានបាន ៣ ពាន់ បើកទ្វារស្រុកចេញតច្បាំងនឹងហែហូទុនបាន ១០ ក្បួន ។ ហែហូទុនក្លែងធ្វើជាចាញ់សេះថយរត់ គួនអ៊ូមិនដឹងកលឧបាយក៏បំផាយសេះដេញតាមទៅចម្ងាយប្រហែល ២.០០០ សិន ( ៨ គ.ម. ) គួនអ៊ូក៏ត្រឡប់ចិត្តគិតឃើញថា មុខជាទាហានចូចូនឹងលើកចូលទៅក្នុងស្រុកហែហ្វី, ក៏នាំទាហានត្រឡប់ទៅក្រោយវិញ ។ ទទួលឮសំឡេងផាវពីសងខាងផ្លូវ គួនអ៊ូក្រឡេកមើលទៅឃើញខៅជូនឹងស៊ីឡុង លើកទាហានចេញមកស្ទាក់ពីមុខទាំងខាងមុខទាំងខាងស្ដាំ ។ គួនអ៊ូក៏បរសេះចូលតយុទ្ធជាពន្ទឹក, ខៅជូនឹងស៊ីឡុងក៏ទទួលតទល់ទាំងសងខាង គួនអ៊ូគេចត្រឡប់ដំរង់ចូលទៅក្នុងស្រុក ប្រទះនឹងហែហូទុនលើកទាហានមកស្ទាក់ពីមុខ ស៊ីឡុងនឹងខៅជូ ក៏ដេញជិតពីក្រោយ គួនអ៊ូងាកមកឃើញ ក៏ពតទាំងមុខទាំងក្រោយរិលជុំវិញខ្លួន ព្រួញធ្នូបាញ់ប្រមះបំពោះទៅលើខ្លួនគួនអ៊ូៗ ក៏យកដាវការពារព្រួញមិនឲ្យរត់ចូលដល់ខ្លួនបាន នឹងងាកទៅចូលស្រុកក៏មិនរួច ងាកគេចទៅខាងឆ្វេងខាងស្ដាំក៏មិនបាន ទាហានចូចូចេះតែព្រួតថែមចូលមកទៀតជុំវិញខ្លួន គិតតែច្បាំងតគ្នានៅទីនោះតាំងពីព្រលឹមរហូតដល់ព្រលប់ គួនអ៊ូអស់កំឡាំងណាស់ ក៏នាំទាហានពាន់ទំលាយកងទ័ពចូចូរត់ទៅដល់ដើមភ្នំ ១ ក៏ឡើងទៅឈប់សម្រាកនៅលើភ្នំនោះ ។ ហែហូទុន, ស៊ីឡុង, ខៅជូ ក៏លើកទាហានដេញតាមទៅសំដៅដល់

ដើមក្ន ហើយកយទាហានឡោមព័ទ្ធជុំវិញក្ននោះ ។ ឯទាហានឡាវពី ដែលចូលទៅរកគួនអ៊ូនោះ លុះដល់ពេលព្រលប់មិនបានឃើញគួនអ៊ូ វិលត្រឡប់ចូលទៅស្រុកវិញ ក៏នាំគ្នាបើកទ្វារចេញបំណាងនឹងទទួល ចូចូ ៗ បរិសេះឃើញដូច្នោះ ក៏នាំយកសេចក្តីទៅជំរាបចូចូៗបានដឹង ដូច្នោះហើយ ក៏មានសេចក្តីត្រេកអរណាស់ លើកពលយោធាចូល ទៅក្នុងស្រុកហៃហ៊ី ហើយឲ្យយកភ្លើងដុតស្រុកនោះឆេះឡើង ប្រាថ្នា ដើម្បីនឹងឲ្យគួនអ៊ូតូចចិត្ត ទើបបង្គាប់ពលទាហានដែលស្និទ្ធឲ្យទៅវាំង រក្សាត្រួសាររបស់ឡាវពីទុកឲ្យល្អ ហើយចូចូក៏ត្រឡប់មកលើកទាហាន ណូនចូលទៅហោមព័ទ្ធគួនអ៊ូថែមទៀត ។ គួនអ៊ូឃើញពន្លឺភ្លើងឆេះឡើង កណ្តាលស្រុក ក៏ទឹកតក់ស្លុតរន្ធត់ចិត្តគិតដល់ក្រិយាបុត្រឡាវពី ទើប លើកទាហានចុះមកដល់ដើមក្ន ៗ ទាហានចូចូក៏ពស្ទាក់ពីមុខណែនណាន់ នឹងចេញមកមិនបាន ។ គួនអ៊ូក៏វិលត្រឡប់ឡើងទៅលើក្ន រួចចុះមកវិញ ជាច្រើនសា លុះព្រឹកឡើងគួនអ៊ូក៏ជិះសេះនាំទាហានចុះទៅម្តងទៀត ទទួលក្រឡេកទៅឃើញតៀវលៀវជិះសេះកាន់ទួនឡើងមក គួនអ៊ូក៏ ស្រែកសួរថា អ្នកឯងមកច្បាំងនឹងយើងឬ? ។ តៀវលៀវតបថា " ខ្ញុំមិនមែនមកច្បាំងនឹងអ្នកទេ . ដែលខ្ញុំឡើងមកនេះប្រាថ្នានឹងមកតប ស្នងសងគុណអ្នក " ហើយតៀវលៀវក៏លោតចុះពីលើសេះបោះលំពែង ចេញពីដៃ ចូលទៅគំនាប់គួនអ៊ូៗឃើញដូច្នោះក៏ចុះពីសេះមកគំនាប់ តៀវលៀវវិញ ហើយសួរសាកតៀវលៀវថា ចូចូប្រើអ្នកឯងមកល្បួង លួងលោមយើងឬ? ។ តៀវលៀវតបថា " កាលគ្រាមុនអ្នកបានជួយ

ដោះទុក្ខឲ្យខ្ញុំរួចអាយុជីវិតម្តងហើយ គ្រានេះឃើញថាអ្នកមានទុក្ខជាពន្ទឹកវិញ ខ្ញុំក៏ខំឧស្សាហ៍ឡើងមកជួប ដើម្បីនឹងជួយដោះទុក្ខអ្នកជាផ្លូវកតវេទិតបស្នងសងគុណអ្នក ។ គួនអ៊ូសួរថា បើអ្នកឯងគិតដល់គុណូបការរបស់យើង ហើយឡើងមកជួយជាកំឡាំងយើងៗ ក៏ទទួលអរគុណណាស់ ។ តៀវលៀវថា មិនមែនដូច្នោះទេ ។ គួនអ៊ូថា អ្នកឯងថាមិនមែនមកល្បងលួងលោម ហើយថានឹងមកជួយកម្លាំងក៏មិនមែនទៀត តើដែលឡើងមកនេះដើម្បីប្រយោជន៍អ្វី? ។ តៀវលៀវតបថា ខ្លួនអ្នកនឹងឡាវពី តៀវហ៊ុយមានសេចក្តីស្រឡាញ់គ្នាស្មើអាយុជីវិតទៅវិញទៅមក ឥឡូវឡាវពីនឹងតៀវហ៊ុយបែកនិរាស្តគ្នាទៅហើយ អ្នកក៏មិនដឹងដំណឹងជារស់ឬស្លាប់ កាលពីយប់មិញមហាឧបរាជលើកកងទ័ពទៅវាយយកស្រុកហៃហ្វីបានហើយ បានទាំងចាត់ប្រើទាហានឲ្យទៅពិតក្តិរក្សាគ្រួសារឡាវពី មិនឲ្យនរណាទៅបៀតបៀន ហាមមិនឲ្យធ្វើទុក្ខបុកម្នេញអាណាប្រជានុរាស្ត្រស្រុកឲ្យនៅជាសុខក្សេមក្សាន្ត ខ្ញុំយល់ឃើញថា មហាឧបរាជមានចិត្តមេត្តាចងស្ពានមេត្រីនឹងអ្នកដល់ទីនេះ បានជាខ្ញុំនាំហេតុដូច្នេះមកជំរាបអ្នកឲ្យជ្រាប ។

គួនអ៊ូបានស្តាប់ក៏ខឹងណាស់ និយាយនឹងតៀវលៀវថា ពីដើមអ្នកឯងប្រាប់យើងថា ខ្លួនមិនមែនមកនិយាយល្បងលួងលោមយើងទេ ឥឡូវហេតុម្តេចបានជាខ្លួនមកនិយាយដូច្នេះ បើមិនមែនជាពាក្យល្បងលួងលោមទេ តើសំដីនេះនឹងប្រាថ្នាប្រយោជន៍អ្វី? ឯខ្លួនយើងដែលធ្លាក់មកនៅទីនេះជាទីចាល់ចង្អៀតពិតហើយ តែយើងនឹងងាកមុខទៅចូលនឹង

នរណាក្រៅពីឡៅពីនោះ អ្នកកុំបីសង្ស័យឡើយ ខ្លួនយើងមិនមែនស្រឡាញ់ជីវិតប៉ុន្មានទេ ព្រោះសេចក្ដីស្លាប់ឧបមាដូចគេដេកលក់ ហេតុនេះចូរអ្នកវិលទៅប្រាប់ចូឆូចុះ ថាឲ្យត្រៀមពលទាហានទុកឲ្យព្រមចុះ វេលានេះយើងចុះទៅច្បាំងត្រាតែអស់កម្លាំងស្លាប់កណ្ដាលវៀនវង្គណ៍ ។

តៀវលៀវបានស្ដាប់ក៏អស់សំណើចហើយនិយាយថា ដែលអ្នកមានប្រសាសន៍ដូច្នេះ ទោសនឹងមានដល់ខ្លួនអ្នក ៣ ប្រការ មនុស្សនានានឹងគេហានិន្ទាអ្នកបាន ។ គួនអ៊ូថា ខ្លួនយើងកាន់សេចក្ដីសត្យានុស័ត្យពិតត្រង់ បានបង់ពាក្យទុកមកហើយថា ទោះបីដល់នូវសេចក្ដីស្លាប់ក៏មិនត្រឡប់ចូលទៅនៅនរណាក្រៅពីរូបឡៅពីតែមួយ ដែលអ្នកឯងថាយើងនឹងមានទោស ៣ ប្រការនោះ ដោយហេតុអ្វីខ្លះ? ។ តៀវលៀវឆ្លើយថា "ពីដើមខ្លួនអ្នកនឹងឡៅពីតៀវហ៊ុយបានចូលស្បថស្បាន់រួមចិត្តជីវិតមួយនឹងគ្នាជាបងប្អូន ថាបើនរណាស្លាប់ក៏ត្រូវស្លាប់ជាមួយគ្នា គ្រានេះឡៅពីនឹងតៀវហ៊ុយបែកនិរាសគ្នាទៅហើយ អ្នកក៏មិនបានដឹងជារស់ឬស្លាប់ ឥឡូវទាហានរបស់អ្នកក៏តិចណាស់ ដែលនឹងនាំចុះទៅតតាំងច្បាំងគ្នានោះ បើអ្នកអន្តរាយដល់ជីវិតហើយ ខាងឡៅពីតៀវហ៊ុយគង់ជីវិតរស់នៅ នឹងស្វែងមករកអ្នកប្រាថ្នានឹងជួយអ្នកគិតការតទៅ ឥឡូវបើអ្នកស្លាប់ទៅហើយ ឡៅពី តៀវហ៊ុយក៏នឹងស្លាប់តាមទៅផង នោះពាក្យដែលអ្នកបានសច្ចាស្បថស្បាន់នឹងគ្នា មិនបង់អសារស័ត្យទៅទេឬ, មនុស្សទាំងឡាយបានដឹងក៏នឹងដៀលថា អ្នកគិតខុសព្រោះឥតប្រាជ្ញាប្រការ ១ ។

ប្រការមួយទៀត ឡៅពីទុកចិត្តលើអ្នកថា អ្នកជាមនុស្សល្អបរិសុទ្ធ បានជាប្រគល់ករិយាបុត្រឲ្យអ្នកពិតក្តិរក្សា បើអ្នកធ្វើឲ្យអាត្មាឯងស្លាប់អសារទៅហើយ មាននរណាឡើយនឹងទំនុកបំរុងករិយាបុត្រឡៅពីទាំង២ឲ្យដូចខ្លួន សូម្បីបុត្រករិយាឡៅពីនោះសោតក៏មានរំពឹងតែលើខ្លួនអ្នក ហាក់បីដូចជាដៃជើងសម្រាប់ខ្លួន បើអស់ពីអ្នកទៅហើយ អន្តរាយផ្សេងៗក៏គង់នឹងមាន, ការដែលឡៅពីសន្និដ្ឋានទុកចិត្តអ្នកនោះ ក៏នឹងមិនបង់អសារទៅឬ? ខ្ញុំយល់ឃើញមិនសមគួរ នេះជាខប្រការទី ២ ។

ប្រការទី ៣ ខ្លួនអ្នកល្បីថ្វីដៃខ្លាំងពូកែ ទាំងចេះដឹងទំនៀមទម្លាប់បុរាណមកក៏ច្រើន ហេតុម្តេចអ្នកមិនរក្សាជីវិតរបស់ខ្លួនទុកចាំឡៅពី នឹងបានជួយគ្នាគិតការទំនុកបំរុងផែនដីឲ្យបានសេចក្តីសុខក្សេមក្សាន្តទៅឯមុខ ទោះបីខ្លួនអ្នកមកធ្លាក់លើសេចក្តីព្រួយទុក្ខលំបាកប៉ុន្មាន ក៏ជាគ្រោះកាចពាល់ប្រាណ ឧបមាដូចជាដើរលុយឆ្លងលើគំនរភ្លើងដែលកំពុងឆេះ ពុំនោះសោតឧបមាដូចគេហែលឆ្លងមហាសមុទ្រដ៏ធំជ្រៅពន្ទឹក ត្រូវតែគិតទីករកឧបាយនឹងឆ្លងទៅឲ្យរួចបាន ដើម្បីឲ្យមានកេរ្តិ៍ឈ្មោះថាជាមនុស្សមានប្រាជ្ញាចេះរក្សាជីវិតឲ្យគង់នៅ ទើបពេញត្រូវជាជាតិទាហានមានចិត្តសុចរិតទៀងត្រង់នឹងផែនដី ដែលអ្នកស្រីដីកាន់យកមានេះ ហើយចុះទៅច្បាំងតតាំងនឹងពលទាហានច្បូងដ៏ច្រើនលើសលុប អ្នកត្រូវដឹងថាមានតែបរាជ័យ ទោះបីជីវិតអ្នកមិនស្លាប់គ្រានេះ ក៏នឹងសូន្យឈ្មោះមិនល្បីឮទៅថាជាអ្នកគិតត្រូវនោះឡើយ ខ្ញុំយល់ឃើញដូច្នេះហើយទើបថា អ្នកនឹងមានទោស ៣ ប្រការយ៉ាងនេះ” ។

(មានត)

## ដំណើរតាមខ្យល់ក្នុងកាផ្ដារ:

# លោកផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

### ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

នាយទាហាន សំឡឹងលោកតាកាអ៊ិដមួយស្របក់ រួចបែរទៅមើល អ៊ីស្មាអ៊ីលទីងមុក្តារ ទើបវិលបែរមកចំលោកតាអៃយ៉ាដវិញ ហើយសួរថា

— តើ នៅបណ្ដាអ្នកបំរើលោក មានអ្នកណាឈ្មោះតាឡិបដែរ?

លោកតាកាអ៊ិដមានទឹកមុខរំភើបបន្តិច តែការរំភើបនេះ មានតែ អ៊ីស្មាអ៊ីលទេដែលអាចយល់ ។

— អាដែនដែលនាំលោកមកហ្នឹងហើយ ឈ្មោះតាឡិប ។

ខណៈនោះ តាឡិបដែលឈរក្បែរគៅអ៊ី ខំប្រឹងបៀតខ្លួនទៅខាង ក្រោយសសរប្រុងនឹងថយទៅរកទ្វារ ប៉ុន្តែនាយទាហានសំឡឹងគាត់មិន ដាក់ភ្នែកទឹកស្មានដឹងបំណងរបស់គាត់ ហើយហៅឲ្យចូលមកជិតដោយ អាការគំរាម:

— ចុះអាដែនហ្នឹងទៅធ្វើអីឯផ្ទះស្យៀម ពីម្សិលមិញ?

លោកតាអៃយ៉ាដឆ្លើយថា:

— យើងមិនដឹងទេ ។

ខណៈនោះ នាយទាហានបែរទៅសួរតាឡិបថា:

— ឯងទៅធ្វើអី នៅផ្ទះស្យៀមពីម្សិលមិញ ឆ្លើយ?

តាឡិបបុកពោះ ធ្វើអឹមអៀម ចេះតែមួលក្រពេះក្លក់ចុះឡើងក្នុងដៃរួចលុតជង្គង់ស្រិប ហើយនិយាយថា:

- ខ្ញុំក្បត់ចៅហ្វាយរបស់ខ្ញុំ! ខ្ញុំបានសន្យានឹងលោកស្បៀមថានឹងនាំនាងឡីឡាយកទៅជូនលោក ។

នាយទាហានសួរទៀតថា:

- ចូរនាំខ្ញុំទៅរកនាងឡីឡានោះ!

លោកតាអៃយ៉ាដនិយាយថា:

- លោកតាមខ្ញុំមក ។

ជនទាំងពីរដើរតាមរបៀងក្រាលស្មុំឥដ្ឋក្រមាល រួចបានដល់នៅមុខទ្វារឈើមួយ ចម្រឹងមាស គឺជាកន្លែងនៃក្រមនារីទាំងឡាយ ។

ចម្រៀងស្រួយស្រែះ បើកបទពយទំនុកដដែលៗ យ៉ាងពីរោះគួរឲ្យស្រងោចចិត្ត បើអ្នកណាឮហើយ គេថាគឺនោះជាកន្លែងនិរទុក្ខ ។

លោកតាកាអ៊ុដស្រែកតាមទ្វារ ព្រោះអ្នកចំឡែកមិនត្រូវចូលក្នុងល្វែងក្រុមស្រីក្រមុំរបស់លោកឡើយ លោកស្រែកហៅថា:

- ឡីឡា!

សូរចម្រៀងបាត់ឈឹង គេឮសូរស្បែកជើងឈើដើរលើក្រមាលឥដ្ឋ ឮសូររហូតមកដល់ទុកទ្វារ រួចឃើញនាងឡីឡាចេញមក ។ នាងឈរដោយស្ងួនមួយស្របក់នៅពីខាងមុខនាយទាហានឡូតី ។ ប៉ុន្តែទឹកមុខអ៊ុស្វាអ៊ុលពេញដោយមេត្តា ធ្វើឲ្យនាងមានសេចក្ដីទុកចិត្ត នឹងសេចក្ដីក្លាហានបន្តិចឡើងវិញ ។

លោកអនុសេនីយ៍ឯកសួរថា:

— នាងនេះត្រូវជាអ្វី?

លោកតាអៃយ៉ាដឆ្លើយដោយសំដីយ៉ាងម៉ឺងម៉ាត់ថា:

— នាងឡីឡាជានារីកងកុលសម្ពន្ធនៃលោកតាម៉ាព្រែក អែល-យ៉ាដី ៗ វាមកនៅកងទីនេះ តាំងពីបីខែនៅថ្ងៃមកហើយ ៗ

នាយទាហានតួរគីប្រាប់ថា

— បានហើយ !

រួចនាយទាហានសួរទៀតដោយសំឡេងបំភៅនាងក្រមុំថា:

— តើនាងឯងមានការណ៍ទាក់ទងជាមួយនឹងសៀមបេនអាប់ដាឡ: ដូចម្ដេច?

នាងឡីឡាមើលចំពោះលោកអនុសេនីយ៍ឯក ហើយឆ្លើយដោយសំដីឥតកាន់ថា:

— ខ្ញុំសូមស្បថចំពោះនាមព្រះអាឡស់ គឺឈ្មោះសៀមប្រាថ្នាកំហែងចាប់ខ្លួនខ្ញុំម្ចាស់ ៗ លោកនេះបានរកចាប់ខ្លួនខ្ញុំ តាំងពីកាលដែលខ្ញុំនៅកងកុលសម្ពន្ធរបស់ខ្ញុំឯណោះ ៗ

នាយទាហានឆ្លើយដូចជាដញ្ជឹងមួយសន្ទុះ ៗ ក្រែកលោកលួចមើលអ៊ីស្មាអ៊ីលហើយឃើញកូនលោកតាកាអ៊ីដ ទីងនាងឡីឡាបេះតែសំឡេងគ្នាទៅវិញទៅមក ៗ លោកទឹកថាជំលោះដែលកើតឡើងរវាងជនទាំងពីរ ប្រាកដជាជំលោះពីកាមគុណ ៗ សៀមដែលស្លាប់គឺប្រហែលគ្រាន់តែទទួលបាបគ្រោះអំពីការបំណង់ផងខ្លួនឯងទេដឹង? ប៉ុន្តែ លោក

វគ្គរយោបល់នេះទុកក្នុងចិត្ត ដើម្បីយកទៅដំរាបទៅហ្វាយលោកជាមុនសិន ។

នាយទាហានទទួលគំនាប់លោកតាកាស៊ុជ ហើយនិយាយថា:

— ខ្ញុំអរគុណនឹងលោកពេក ព្រមទាំងសប្បាយចិត្តដោយយកចម្លើយបានត្រឹមត្រូវតាមច្បាប់ នៅក្នុងទីនេះ ។

លោកតាកាស៊ុជនិងកូនប្រុសទាំងពីរ នាំគ្នាជូនដំណើរលោកអនុសេនីយ៍ឯកដល់មាត់ទ្វាររបង រួចលោកតាអែយ៉ាជហៅតាឡុបមក ។ តាឡុបមកដល់ លោកតាអែយ៉ាជស្តីកទៅរកកូនច្បងហើយនិយាយថា:

— ត្រូវតែតាឡុបថយចេញពីទីនេះ!

ក្នុងនៃលាកុដិក ជោរជន់ដោយទឹកនេត្រ ប៉ុន្តែគាត់ដឹងថាទៅហ្វាយនាយដែលធ្វើដូច្នេះ មកពីចង់បញ្ចៀស បង់រាំងទុក្ខធំកុំឲ្យកើតឡើង ។ តាមពិត ជាតិត្បូវតីមិនមែនទោតឡើយ ហើយប្រសិនបើគេមិនត្រូវការឲ្យបញ្ចេញអនុមតិ ដោយហេតុ គង់តែត្រូវធ្វើឲ្យគេសុខចិត្តដើម្បីការពារទូវសេចក្តីសង្ស័យ ។ ករណីនេះ តាឡុបយល់ទាំងអស់ ហើយគាត់ទទួលជង្គង់លោកតាអែយ៉ាជទាំងយំ រួចនិយាយថា:

— សូមឲ្យការស្ម័គ្ររបស់នាយទៅហ្វាយសម្រេចដូចក្តីប៉ុនប៉ង ។ លុះក្រោកឡើងវិញ គាត់ដើរទៅឯក្រោលសេះដើម្បីរៀបចំបង្វើចទោអាវ ។

* * *

នៅទីនោះ ត្រង់ផ្លូវដែលក្នុងរក្រៃគាត់តែងយកស្មៅក្នុងប្រហើរដាក់ឲ្យសត្វស៊ីនឹងត្រង់រង្គាលស្មៅនៅមុខក្រោល ដែលសត្វក្រោកឡើងកាល

ណា គាត់ព្រួសដើងដើរលើកម្រាលថ្មើមថ្ម គាឡិបដូចជាសុតចិត្តរកកម្លាំង ទឹងផ្ញើអ៊ុំពុំកើត ។ គាត់ខានបានឃើញសេះទាំងនោះហើយ គឺជាសត្វ ដែលគាត់ទុកដូចជាមិត្តភក្តិ សម្រាប់គាត់សម្តែងសេចក្តីរីករាយ នឹង សេចក្តីទុក្ខព្រួយ ហើយចូនកាលសត្វ៖ស់នោះសំឡឹងមើលគាត់វិញដូច ជាមនុស្សភាព ។ រូបគាត់យំដូចក្មេងដោយសេចក្តីរលឹក ។

មានដៃមួយមកស្ទាបស្ទាគាត់ដោយមិត្តភាព គឺជាអ៊ីស្មាអ៊ីលដែល និយាយដាក់ត្រចៀកគាត់ថា:

— តាឡិប តាឯងកុំទៅអី ។ ខ្ញុំមិនចង់ឲ្យតាទទួលនូវទម្ងន់នៃ សេចក្តីទុក្ខ, ខ្ញុំទេតើ ដែលត្រូវទទួលខុសត្រូវតែម្នាក់ឯង ។

លាកុដិកងើបមើលអ៊ីស្មាអ៊ីល ហើយនិយាយថា:

— អ្នកទទួលខុសត្រូវ មានតែម្នាក់ឯងទេ គឺចោរទឹងអាក្បត់ដែលចង់ ឆក់យកស្ត្រីជាទីគាប់ចិត្តពីម្ចាស់របស់ខ្ញុំ ឥឡូវគេយកជីវិតប្តូរជួសកំហុស រួចហើយ សូមឲ្យសន្តិសុខនៃព្រះអាឡ្សស់ស្ថិតនៅជាមួយទឹងគេក្នុងកន្លែង សម្រាកដ៏ចិរកាលនេះទៅចុះ ។ បពិត្រចៅហ្វាយ, ខ្ញុំត្រូវតែចេញទៅ, លោកតាជាឪពុកចៅហ្វាយមានប្រសាសន៍ត្រូវណាស់ ។ បើខ្ញុំនៅ សេចក្តីវិនាសទឹងកើតមានដល់អ្នកទាំងអស់ ។ ណ្ហើយ! ចៅហ្វាយ សូមចៅហ្វាយឲ្យតែកាំភ្លើងមួយទឹងអូដ្ឋមួយមកខ្ញុំ បានហើយ ។

អ៊ីស្មាអ៊ីល ចាប់ឧបដៃគគ្រាតរបស់តាឡិប ហើយនិយាយទាំង ទឹកភ្នែកថា:

— តាឡិប នៃតាឡិបសំឡាញ់! តារើសយកអូដ្ឋណាដែលគាប់ចិត្ត

ក្នុងក្រោលចុះ ចំណែកអារុធក៏តារើសយកអាណាថ្មីមួយដែរចុះ ៗ ហើ
យកប្រាក់មួយស្បោងនេះទៅផង ៗ រួចអ៊ីស្មាអ៊ីលហុចប្រាក់មាសមួយ
ស្បោងឲ្យទៅ ព្រោះគេដឹងថា ប្រាក់មួយស្បោងដែលស្រៀមឲ្យពីយប់
មុននេះ តាឡិបទម្លាក់ចោលទៅក្នុងអណ្តូងទឹកហើយ ៗ

ដិណ្ណាណាកុដិកមិនព្រមទទួលយក អ៊ីស្មាអ៊ីលចេះតែដាក់ទាំងបង្ខំទៅ
ក្នុងហោប៉ៅខ្សែក្រវាត់ឲ្យ ទើបគេឱបតាឡិបនឹងទ្រូងហើយឲ្យពរថា:

— សូមព្រះអាឡស់តាមរក្សាតាជានិច្ចកាលកុំបីឃ្លាតឡើយ !

មុនព្រះអាទិត្យអស្តង្គត តាឡិបធ្វើដំណើរចេញទៅ តាមផ្លូវ
កន្តារៈកណ្តាលវាលផុតខ្សាច់ ៗ

*
* *

កាលដែលរឿងហេតុទាំងនេះ កំពុងប្រព្រឹត្តទៅក្នុងផ្ទះអ៊ីស្មាអ៊ីល
លោកអនុសេនីយ៍ឯកអញ្ជើញទៅសុំជួបនឹងវរសេនីយ៍ត្រីរបស់លោក ៗ
លោកមេទ័ពនេះគិតឃើញថា ការល្អត្រូវតែប្រជុំអស់នាយទាហានទាំង
ប៉ុន្មានដើម្បីស្តាប់សេចក្តីពយាការណ៍របស់លោកសក្តិបី ៗ

ពួកនាយទាហានទាំងអស់ក៏នាំគ្នាមកតាមសេចក្តីអញ្ជើញរបស់នាយ
ចៅហ្វាយខ្លួន គឺជាមហាសន្និបាតមួយដែលតាំងឡើងនៅជុំវិញតុមួយ
ក្រាលកម្រាលបៃតង មានកំប៉ុងបារីនឹងកែវស្រាដាក់ពីលើ ដ្បិតថានាយ
ទាហានអស់នេះ ពិតមែនជាអ្នកមានអាវុធលើកឡើងដើម្បីតយុទ្ធនឹងពួក
ទ្មិល ក៏មិនមែនជាជនស្អប់ខ្ពើមសម្បត្តិក្នុងលោកនេះឡើយ ទឹងជាជន
មិនមែនជាមិនត្រូវការនឹងរសជាតិស្រាឡើយ ៗ

លុះជួបជុំគ្នាស្រេចហើយ លោកអនុសេនីយ៍ឯក ត្រូវគេអញ្ជើញឱ្យអធិប្បាយ ។

លោកនេះ បាននិយាយរៀបរាប់ ពីដំណើរយ៉ាងម្ដេចដែលលោកបានយល់ថា ឈ្មោះតាឡិបមានការទាក់ទងគ្នាជាមួយនឹងរស្មីម, យ៉ាងដូចម្ដេចដែលនៅក្នុងផ្ទះលោកតាអៃយ៉ាដ, លោកបានធ្វើឱ្យឃើញច្បាស់នូវការណ៍សមគំនិតគ្នារវាងអ៊ីស្មាអ៊ីលនឹងនាងឡៃឡា នាងនេះហើយជាមូលហេតុ ដើម្បីប្រានឧក្រិដ្ឋទោសនយោបាយ ការបំបែកបំបាក់សម្ពន្ធមិត្រដ៏ស្មោះស្ម័គ្ររបស់តួគី ទៅលើការសងសឹកប៉ែកខាងកាមរាគវិញប្រហែល លោកអនុសេនីយ៍ឯកសម្រេចសេចក្ដីខាងចុងថា: ·

— ហ្នឹងហើយជាយោបល់របស់ខ្ញុំបាទ ។ បើតាមការយល់ដោយច្បាស់លាស់ ខ្ញុំជឿថា អ៊ីស្មាអ៊ីលបេន-អៃយ៉ាដ នឹងអាចឱ្យដំណឹងយ៉ាងជាក់ច្បាស់ដល់យើង អំពីមរណភាពនៃរស្មីម ព្រោះខ្ញុំប្ដូលចិត្តថា គឺគេហ្នឹងហើយត្រូវជាអ្នកមានទោស ។

លុះបានអធិប្បាយចប់សព្វគ្រប់កាលណា លោកអនុសេនីយ៍ឯកអង្គុយចុះ ហើយលើកស្រាពិសាមួយកែវ ។

រហស្សភាពយ៉ាងធ្ងន់សង្កត់ពីលើពួកអ្នកស្ដាប់ទាំងអស់ ព្រោះរឿងនេះ ជាកិច្ចដ៏សុខុមពេក ។

លោកវរសេនីយ៍ត្រិះគិតជញ្ជឹងមួយស្របក់ធំ ព្រោះលោកជាទាហានម្នាក់ដែលមានចរិតមិនខេវខាវ ។ ពួកនាយទាហានទាំងឡាយព្រំចាំយ៉ាងយូរនូវសេចក្ដីសម្រេចដែលលោកត្រូវលើកឡើងកាន់ការណ៍ ។

រឿងនេះប៉ះទៅលើក្រលៀតនៃប្រាជ្ញា ហើយការឈ្លាសវៃនៃជាតិតួរគឺក៏ធ្វើឲ្យមានបាតុកម្មឡើងម្តងទៀត ៗ

លោកវេសន័យ៍ត្របាប់និយាយថា:

– ភេធនកម្មចំពោះលើកូនលោកតាកាអ៊ុជ នឹងអាចបណ្តាលឲ្យកើតមានការចលាចលយ៉ាងធំក្នុងស្រុក ៗ ត្រូវយើងប្រើឧបាយកលយ៉ាងដូច-ម្តេចឲ្យស្រួលទើបគួរ ៗ តើអស់លោកត្រូវគិតដូចម្តេចអំពីរឿងនេះ? ៗ

រួចលោកថ្លែងសេចក្តីព្រាងតាមដែលលោកចូលចិត្ត ដើម្បីរលាស់អ៊ីស្មាអ៊ីលឲ្យខ្ចាតចេញទៅឆ្ងាយ ដោយយករឿងកិត្តិយសខាងចម្បាំងមកប្រើ ប្រាប់ចំពោះនាយទាហានរបស់លោកទាំងអស់ ៗ

*
*   *

ពេលព្រលប់ហើយ ៗ នៅក្នុងបន្ទប់នាងឡីឡា ដែលទាំងពីររបស់អ៊ីស្មាអ៊ីលចាប់ឱបក្រសោបគូសង្សារ ៗ ចុងថនាស្រួចដូចបុប្ផាទើបនឹងក្រពុំទុលពីក្នុងអាវសារូយ៉ាងស្តើង ៗ បបូរមាត់នឹងបបូរមាត់ជក់ជាប់គ្នា ៗ

– ឱ អ្នកបងសំឡាញ់ !

– ឱ កែវព្រលឹងថ្លៃ !

– កុំទៅណាចោលខ្ញុំណា៎បង ៗ ខ្ញុំបានសុខដោយសារតែនៅជិតអ្នកបង ៗ

– បងស្រឡាញ់ប្អូនពេក ទុកស្មើជីវិត ៗ

*
*   *

(មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

រឿងព្រេងគេណ្ឌា

## លោកសមិន មុត្យនជមៈតែង
## លោករ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

## និទាននៃរូបទេពនិម្មិតទី ៩

មានកាលមួយថ្ងៃ ព្រះមហាក្សត្រិយ៍ភោជៈប្ដេជ្ញាក្នុងព្រះរាជហឫទ័យ ថានឹងយាងទៅគង់លើបល្ល័ង្កទិព្យនោះ ដើម្បីនឹងទ្រង់ធ្វើមុទ្ទាភិសេក ។ ពេលដែលទ្រង់យាងទៅដល់ រូបទេពនិម្មិតទី ៩ ក៏ក្រាបបង្គំទូលថា “ឱ! ព្រះមហាក្សត្រិយ៍ភោជៈ, សូមទ្រង់ព្រះសណ្ដាប់, ស្ដេចអង្គណាមួយមានគុណសម្បត្តិស្មើនឹងព្រះបាទវិក្រមាទិត្យ; ស្ដេចអង្គនោះទើបអាចគង់លើបល្ល័ង្កទិព្យនេះបាន” ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់ទេវវាចា របស់រូបទេពនិម្មិតទី ៩ ហើយក៏ទ្រង់សួរថា “តើគុណសម្បត្តិព្រះបាទវិក្រមាទិត្យ នោះយ៉ាងណាខ្លះ?” ។

រូបទេពនិម្មិតនោះក៏ថ្លែងថា “សូមទ្រង់ព្រះសណ្ដាប់, ព្រះបាទវិក្រមាទិត្យ ទ្រង់សោយរាជសម្បត្តិនៅនគរអវន្តី ។

មានយោគីម្នាក់មកដល់ទីក្រុងនោះ ហើយចូលទៅអង្គុយកណ្ដាលព្រះរាជឧទ្យាន ។ យោគីនោះបេះផឹងសព្វគ្មានសល់អ្វី, វាចារបស់

លោកក៏មានអានុភាពអស្ចារ្យ, លោកបានរួចផុតពីកណ្ដាប់ដៃនៃតណ្ហា, ដែលជាប់ចំពាក់នឹងកាមាទិកិលេសទាំងឡាយ ។ យោគីនោះ បើលោកពោលឬបង្គាប់ទៅលើអ្នកណា បានដូចសេចក្ដីប្រាថ្នា ។ ព្រះមហារាជទ្រង់បាន ជ្រាបសព្វគ្រប់នូវអានុភាពនៃយោគីនោះ ដោយមតិមហាជន, ទ្រង់ត្រាស់បង្គាប់ឲ្យបណ្ឌិតក្នុងក្រុមព្រះរាជទីប្រឹក្សា អញ្ជើញទៅហៅយោគីនោះឲ្យចូលមកគាល់ព្រះអង្គ ។ ពួកបណ្ឌិតក៏នាំព្រះរាជឱង្ការទៅជំរាបយោគីៗ មិនព្រមមកហើយពោលតបមកវិញថា "មនុស្សដែលគ្មានកិលេសតណ្ហា ទុកស្ត្រីដែលមានរូបឆោមលោមពណ៌ស្រស់ជាងគេជាស្មៅមួយសរសៃ, ចំណែកអ្នកដែលគ្មានបាបអកុសល ទុកយមៈ (ព្រះយមរាជ) ដូចជាស្មៅមួយសរសៃ, ឯអ្នកដែលគ្មានលោភទុកស្ដេចនឹងរាជសម្បត្តិដូចជាស្មៅមួយសរសៃដែរ" ។

ពួកបណ្ឌិតវិលត្រឡប់ទៅក្រាបបង្គំទូលមហារាជ តាមពាក្យដែលយោគីនេះពោល ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់ចប់សព្វគ្រប់ ក៏មានព្រះបន្ទូលថា "យោគីនេះពោលពាក្យពិតមែន, មានមនុស្សមកសូមព្រះអង្គ, ចូលគាល់ជិតព្រះអង្គ, នេះគឺយើងបានចាត់ឲ្យទៅអញ្ជើញយោគីនោះមកតែគាត់មិនមក, យើងសម្រេចថា យោគីនេះពោលពាក្យពិតប្រាកដមែន" ។

ដល់ទ្រង់ព្រះតម្រិះរួចស្រេច ទ្រង់ស្ដេចយាងទៅកាន់សំណាក់យោគីនោះដោយព្រះអង្គឯង ។ យោគីកាលបានឃើញបុគ្គលមានគ្រឿងសំលៀកបំពាក់ជាស្ដេចពេញយសហើយ ទុកជាបុគ្គលដ៏ប្រសើរ,

មានចិត្តសោមនស្សពន់ពេក ហើយក៏ថ្វាយចំពោះព្រះនរបតីនូវផ្លែឈើនៃទេវនិម្មិតមួយ ហើយក្រាបទូលថា "អ្នកណាបានបរិភោគផ្លែឈើនេះ អ្នកនោះលែងឈឺ, ចាស់, ស្លាប់ហើយ" ។

មហារាជទ្រង់ទទួលយកផ្លែឈើនោះហើយ ក៏វិលត្រឡប់មកកាន់ព្រះរាជនិវេសនដ្ឋានវិញ ។ តែស្តេចយាងទៅតាមផ្លូវទ្រង់ជួបប្រទះនឹងបុគ្គលឈឺម្នាក់, ដោយទ្រង់អាណិតអាសូរដល់បុគ្គលនោះ ទ្រង់ក៏ព្រះរាជទាននូវផ្លែឈើនោះទៅអ្នកដែលមានជម្ងឺនោះ ។

រូបទេពនិម្មិតទី ៩ ក្រាបបង្គំទូលព្រះបាទភោជៈថា "បើទ្រង់មានគុណធម៌បែបនេះ ទ្រង់អាចគង់លើបល្ល័ង្កទិព្យនេះបាន" ។

ព្រះបាទភោជៈទ្រង់ឈ្វេងយល់សព្វគ្រប់ថា ទ្រង់មិនមានគុណធម៌បែបនេះឡើយ, ទ្រង់ក៏បែរព្រះប្រឹស្ថ (ខ្នង) យាងចេញទៅ ។

* * *

## និទាននៃរូបទេពនិម្មិតទី ១០

មានកាលមួយថ្ងៃ, ព្រះបាទភោជៈទ្រង់ស្តេចយាងចូលទៅជិតបល្ល័ង្កទិព្យ ដើម្បីនឹងធ្វើពិធីរាជាភិសេក ។

រូបទេពនិម្មិតទី ១០ ក៏ស្រែច ហើយក្រាបបង្គំទូលព្រះមហាក្សត្រិយ៍ភោជៈថា "បពិត្រព្រះបាទភោជៈ ទ្រង់មិនមានសមត្ថភាពនឹងគង់លើបល្ល័ង្កទិព្យនេះបានទេ, មានតែមហារាជមួយអង្គទ្រង់ព្រះនាមព្រះបាទវិក្រមាទិត្យ ទើបទ្រង់គង់បាន" ។

ព្រះបាទភោជៈទ្រង់មានព្រះបន្ទូលសួររូបទេពនិម្មិតថា "អ្នកណាជាមហាកវិក្រមាទិត្យ? ។ រូបទេពនិម្មិតទី ១០ ដល់បានស្ដាប់នូវបន្ទូលព្រះបាទភោជៈសព្វគ្រប់ហើយ ទើបមានទេវវាចាថា "សូមទ្រង់ព្រះសណ្ដាប់ ទូលបង្គំនឹងថ្វាយទ្រង់នូវគុណសម្បត្តិនៃព្រះបាទវិក្រមា-ទិត្យ ដូចតទៅនេះ ៖

មានមួយថ្ងៃ ព្រះបាទវិក្រមាទិត្យជាស្ដេចចក្រពត្តិ ទ្រង់បានគ្រងព្រះសុពណ៌បាទុកាពិសិដ្ឋ ហើយហោះទៅលើអាកាស ដើម្បីនឹងទ្រង់ធ្វើព្រះរាជទស្សនាការនូវផែនប្រថពីទាំងមូល ព្រមទាំងភូមិភាគផ្សេងៗ ។ នៅទីកន្លែងមួយ, ទ្រង់បានទតទៅឃើញក្នុងបាតគុហាភ្នំមួយជ្រៅ នូវរុក្ខ-ជាតិមួយដើមល្អស្រស់បំព្រងប្លែក ដែលទ្រង់មិនធ្លាប់បានឃើញសោះ ។ ទ្រង់ក៏ស្ដេចយាងចូលទៅជិតរុក្ខជាតិនោះ ជាទីនៅនៃបក្សាប្លែកហៅថា "ទីឃាយុបក្សា" (Longue-Vie, ចិរជីវ Cirajiva) ; ហ្វូងបក្សាជាបរិវារនៃចិរជីវៈ ក៏បាននាំគ្នាទៅរកអាហារជាច្រើនកន្លែង ហើយវិលត្រឡប់មកកាន់រុក្ខជាតិនោះវិញ, ហើយហ្វូងបក្សានោះក៏ពោលប្រស្រ័យគ្នាទៅវិញទៅមក ។

ក្នុងពេលនោះ, មានបក្សាមួយពោលថា "ថ្ងៃនេះខ្ញុំមានទុក្ខជាទម្ងន់" ។ ហ្វូងបក្សាឯទៀតក៏សួរទៅបក្សានោះថា "តើអ្នកមានទុក្ខដោយហេតុអ្វី?" ។ បក្សានោះក៏ពោលតបមកវិញថា: "ចូរអ្នកស្ដាប់ខ្ញុំឲ្យច្បាស់លាស់ហើយចាំទុកកុំភ្លេច អំពីហេតុនៃទុក្ខរបស់ខ្ញុំ: នៅកណ្ដាលសាគរមានកោះមួយ ; ព្រះមហាក្សត្រិយ៍សោយរាជ្យនៅ

កោះនោះជាជាតិយក្ស (កសស:) ប្រជារាស្ត្រជាមនុស្សជាតិ ៗ មាន មួយថ្ងៃ កសស:នោះមានបំណងចង់បរិភោគមនុស្សជាតិនោះទាំងអស់ ៗ ពួកប្រជារាស្ត្រភ័យតក់ស្លុតជាខ្លាំង ប្រជុំគ្នាហើយពោលទៅកាន់កសស: (អារក្ស) ថា "ព្រះអង្គជាស្តេចរបស់យើងទាំងអស់គ្នា ហើយទ្រង់ចង់សោយប្រជារាស្ត្ររបស់ព្រះអង្គ មិនសមសោះ ៗ ទូលបង្គំទាំងអស់គ្នា សូមថ្វាយក្នុងមួយថ្ងៃមនុស្សម្នាក់ តាមវេនជាលំដាប់តទៅ" ៗ

តាំងពីនោះមក កសស:ត្រូវបរិភោគមនុស្សម្នាក់ក្នុងមួយថ្ងៃ ហើយមានចិត្តសោមនស្សពន់ពេក, លោកមិនបានធ្វើបាបអ្នកឯទៀតសោះឡើយ ៗ ខ្ញុំនឹងទៅលេងកំសាន្តនៅប្រទេសនោះក្នុងថ្ងៃនេះ ៗ គឺថ្ងៃនេះហើយដែលត្រូវវេនខាងកល្យាណមិត្តរបស់ខ្ញុំម្នាក់ ប្រគល់មនុស្សម្នាក់ឲ្យជាចំណីដល់កសស: ប្រហែលជាត្រូវលើបុត្រគាត់ដែលត្រូវយកទៅឲ្យកសស:បរិភោគ" ៗ ព្រោះហេតុនេះ ដូចបានជាខ្ញុំកើតទុក្ខពន់ប្រមាណក្នុងថ្ងៃនេះ ៗ

ព្រះបាទវិក្រមាទិត្យ ទ្រង់គង់នៅទៀបគល់រុក្ខជាតិ, ទ្រង់ព្រះសណ្តាប់នូវពចនៃបក្សានោះសព្វគ្រប់, ទ្រង់ហោះទៅលើអាកាសដោយស្បែកព្រះសុពណ៌បាទពិសិដ្ឋ យាងទៅកាន់ប្រទេសនោះដែលកសស:សោយរាជ្យ ៗ បុត្រានៃកល្យាណមិត្របក្សា ដែលត្រូវវេនខ្លួនជាចំណីនៃកសស: មានសេចក្តីភ័យតក់ស្លុតនឹងសេចក្តីស្លាប់ពន់ពេក, អង្គុយនៅត្រង់កន្លែងដែលកសស:បរិភោគអាហារ ៗ

ព្រះបាទវិក្រមាទិត្យ ទ្រង់យាងទៅដល់ទីនោះមានព្រះបន្ទូលថា

"នែកូន, កូនឯងទៅផ្ទះចុះ, ខ្ញុំមកជំនួសអ្នកឯងហើយ ខ្ញុំបូជារូបជីវិតខ្ញុំចំពោះរាសសៈក្នុងពេលនេះ" ។ កូនក្មេងនោះតបថា: លោកជាអ្នកមានគុណធម៌យ៉ាងនេះ ដែលជាឱកាសឲ្យខ្ញុំស្គាល់លោកក្នុងពេលនេះ, "តើលោកជាអ្វី?" ។

ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលថា: "អ្នកឯងមិនចាំស្គាល់ខ្ញុំទេ" ។ កូនក្មេងនោះដល់ព្រះរាជឱង្ការព្រះបាទវិក្រមាទិត្យ មានចិត្តសប្បាយរីករាយពន់ពេក, ហើយក៏វិលត្រឡប់ទៅកាន់គេហ-ដ្ឋានខ្លួនវិញ ។ ព្រះបាទវិក្រមាទិត្យ ទ្រង់ឥតមានខ្លាចអ្វីសោះឡើយ, មានព្រះភក្ត្រញញឹម គង់នៅក្នុងបន្ទប់ដែលរាសសៈធ្លាប់បរិភោគ ។ ដល់ពេលបរិភោគ រាសសៈចូលទៅក្នុងទីនោះ ហើយបានឃើញអគ្គ-បុគ្គលក៏ពោលថា "ឧបុគ្គល! ពេលស្លាប់ដល់ហើយ, ម្តេចក៏អ្នកឯងមិនខ្លាច, មិនតក់ស្លុត, ហើយអ្នកឯងញញឹម, តើអ្នកឯងជាអ្នកណាដែលធ្វើឲ្យខ្ញុំស្គាល់ក្នុងពេលនេះ?" ។ ព្រះបាទវិក្រមាទិត្យ ទ្រង់មានព្រះបន្ទូលថា: "មិនចាំបាច់ស្គាល់ខ្ញុំទេ, ចូរអ្នកបរិភោគខ្ញុំចុះ" ។

រាសសៈ សប្បាយចិត្តណាស់ពោលថា: "ឧបុគ្គលវិសេសអើយ, អ្នកឯងមានគុណធម៌ជ្រៅយ៉ាងក្រៃលែង, ខ្ញុំសប្បាយចិត្តនឹងអ្នកពន់ពេក ។ ចូរអ្នកសូមអ្វីចំពោះខ្ញុំ, អ្វីដែលអ្នកមានចិត្តបំណងចង់បានចំពោះវត្ថុដែលស្ថិតនៅក្នុងរដ្ឋខ្ញុំ" ។ ព្រះមហាក្សត្រិយ៍មានព្រះបន្ទូលថា "បើអ្នកឯងសប្បាយចិត្តនឹងខ្ញុំ, ចូរអ្នកលែងធ្វើបាបប្រជារាស្ត្រនៅទីនេះតាំងពីថ្ងៃនេះតទៅ" ។

ពសសៈ ក៏យល់ព្រមតាមព្រះអង្គ ។ ព្រះមហាក្សត្រិយ៍ទ្រង់ស្តេចហោះទៅតាមអាកាសដោយព្រះសុពណ៌បាទពិសិដ្ឋ, វិលត្រឡប់ទៅកាន់ព្រះរាជធានីវិញ, ហើយតាំងពីថ្ងៃនោះមក, ពសសៈមិនដែលធ្វើបាបប្រជារាស្ត្រសោះឡើយ ។

ដល់ក្រាបបង្គំទូលនូវរឿងនេះចប់សព្វគ្រប់, រូបទេពនិម្មិតទី ១០ ក៏ក្រាបបង្គំទូលតទៅទៀត ចំពោះព្រះបាទភោជៈថា : “បើទ្រង់មានសមត្ថភាព បានជួយស្រោចស្រង់អ្នកដទៃបែបនេះ ទ្រង់ទើបអាចគង់លើបល្ល័ង្កទិព្យនេះបាន ” ។ ព្រះបាទភោជៈ កាលទ្រង់ព្រះសណ្តាប់នូវនិទាននៃរូបទេពនិម្មិតហើយ ក៏លះបង់នូវពិធីបុណ្យមុទ្ធាភិសេកក្នុងពេលនោះ ។

*

* *

(មានត)

មើលអ្វីប្រពៃជាងការមើលទាំងពួង? មើលសៀវភៅធម៌
មើលទស្សនាវដ្តីពុទ្ធសាសនា មើលព្រះពុទ្ធបដិមាករទើប
ប្រពៃព្រោះអាចនាំឲ្យកើតសេចក្តីត្រជាក់ត្រជុំចិត្តជានិច្ច ។

## កំណត់ជីវប្រវត្តិការណ៍

# ពិធីសម្ពោធបើកសាលាបាលីរង
# នៅវត្តព្រះព្រហ្មរ័ត្ន ខេត្តសៀមរាប

ព្រះគ្រូបាសាទរង្សីអនុគណ កែ-អឿន (វីរិយបញ្ញោ)

រៀបរៀង

---

កាលពីថ្ងៃអង្គារ ៤ រោចខែវិសាខ ឆ្នាំមមែសប្តស័ក ព.ស. ២៤៩៨ គឺថ្ងៃទី ១០ ខែឧសភា គ.ស. ១៩៥៥, នៅវត្តព្រះព្រហ្មរ័ត្ន មានធ្វើពិធីសម្ពោធបើកសាលាបាលីរង ៗ ក្នុងពិធីនេះមានទស្សនីយភាពល្អអស្ចារ្យ ដូចមានវិធានការតទៅនេះ ៖

នៅក្លោងទ្វារធំមុខវត្ត មានដោតទង់ជាតិទង់សាសនាធំៗ, នៅខាងមុខសាលាបាលី មានបាំមួយខ្នង បណ្ដោយ ៦ ម៉ែត្រ ទទឹង ៤ ម៉ែត្រ, សសរបាំនីមួយៗ វិចិត្របនាស្រោបដោយស្លឹករុក្ខជាតិស្រស់ៗ, នៅដម្បូលបាំប្រក់ដោយសំពត់ពណ៌ឆ្នូត និងចងប្រហាក់ដោយស្លឹករុក្ខជាតិស្រស់ ព្រមទាំងទង់ជាតិទង់សាសនាតូចៗជាច្រើន, នៅជុំវិញបាំកាយសំពត់វែបមានសណ្ឋានជាទង់ជាតិសំយុងចុះមក, ខាងក្នុងបាំ ក្រាលកន្ទេលក្រហមមានរៀបកៅអីជាជួរៗ និងកៅអីពិសេសមួយក្រាលព្រំពីក្រោម ជាព្រះទីនាំងសម្រាប់សម្ដេចព្រះឧបយុវរាជគង់ និងមានតុ ១ ក្រាលកម្រាលដ៏ស្អាតដាក់កល់ដបផ្កា, បាំនេះសម្រាប់ទទួលបដិសណ្ឋារៈសម្ដេចព្រះឧបយុវរាជ និងឥស្សរជនគ្រប់ដំណែងក្នុងខេត្ត ៗ

នៅយ៉ សាលាបាលី មានធ្វើស៊ុំរបនាដោយស្លឹកទន្ទ្រីងបងទង់ជាតិ ទង់សាសនាធំៗនៅតាមស៊ុំនោះ, កណ្ដាលស៊ុំបងខ្សែប្រូវធ្វើដោយក្រដាសពណ៌ជា ៣ ខ្សែ បងប្រទាក់គ្នាមានសណ្ឋានជាទង់ជាតិ ៗ ខ្ទុងខាងក្នុងសាលាបាលីតាំងពីរថ្នាក់ មានរៀបតុសម្រាប់សិស្សអង្គុយរៀន នឹងតុសម្រាប់គ្រូ ក្ដារខៀនបញ្ឈរធំ ៗ នៅវេលាម៉ោង ៩ ព្រឹក ព្រះសង្ឃជាង ១០០ អង្គ មានព្រះតេជព្រះគុណព្រះសុមង្គលសិលាចារ្យមេគណនឹងព្រះគ្រូអនុគណជាប្រធាន ព្រមទាំងពុទ្ធបរិស័ទជាច្រើនមករៀបជាសត្រៀបត្រា រង់ចាំទទួលបដិសណ្ឋារកិច្ចសម្ដេចព្រះឧបយុវរាជ នឹងឥស្សរជន ៗ វេលាម៉ោង ៩,៣០ នាទី ក្រុមតូរ្យតន្ត្រីកងខេមរកូម៉ិន្ទ នឹងក្រុមកងរក្សាខែត្រទៅរង់ចាំធ្វើគារវកិច្ច ចំពោះសម្ដេច ៗ វេលាម៉ោង ១០ សម្ដេចនឹងឥស្សរជន យាងនឹងអញ្ជើញទៅដល់ ក្រុមតូរ្យតន្ត្រីប្រគំបទភ្លេងនគររាជថ្វាយ, ក្រុមកងរក្សាខែត្រធ្វើគារវកិច្ចតាមប្រពៃណី, អាចារ្យវត្តប៉ាំងកូស់ថ្វាយ, ចប់បទភ្លេងនគររាជហើយ សម្ដេចទ្រង់យាងត្រួតពលរួចទ្រង់យាងចូលទៅក្នុងបាក់ថ្វាយបង្គំព្រះសង្ឃ ហើយគង់ប្រថាប់នៅក្នុងព្រះទីនាំងកៅអី, បន្ទាប់ពីនោះមក ព្រះគ្រូអនុគណ កែ-អៀន ថ្លែងសុន្ទរកថាបំពងសំឡេងដោយឧគ្ឃោសនសព្ទប្រមានសេចក្ដីតទៅនេះ៖

## សុន្ទរកថា

សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ មានព្រះតេជព្រះគុណព្រះសុមង្គលសិលាចារ្យមេគណ ជាប្រធាន !

សូមថ្វាយព្រះពរសម្ដេច ព្រះឧបយុវរាជ !

សូមចំរើនពរ អស់លោកជាឥស្សរជនទាំងឡាយ !

អាត្មាភាពមានសេចក្ដីត្រេកអរដ៏ពន្លឹក និងមានអំណរព្រះគុណដ៏ក្រៃលែងចំពោះសម្ដេច និងលោកជាឥស្សរជនទាំងឡាយ ដែលបានស្ដេចយាងនិងអញ្ជើញមក ជាព្រះរាជាធិបតី សិរីមង្គលក្នុងពិធីបុណ្យសម្ពោធបើកសាលាបាលីថ្មីនេះ ។

អាត្មាភាព សូមថ្លែងកិច្ចការសិក្សានៃព្រះពុទ្ធសាសនាក្នុងវត្តព្រះព្រហ្មរ័តន៍នេះ ដោយសង្ខេបដូចតទៅនេះ ៖

វត្តព្រះព្រហ្មរ័តន៍នេះ កាលពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៥០ បានបើករៀនធម្មវិន័យ ដោយបានសេចក្ដីអនុញ្ញាតជាបណ្ដោះអាសន្នអំពីក្រសួងសម្ដេចព្រះសង្ឃនាយកនិងក្រសួងធម្មការ ដោយការប្រែស្រ័យទាក់ទងជាមួយនឹងព្រះតេជព្រះគុណ ព្រះវ័នរតន៍ មេគណវត្តពោធិវាលខេត្តបាត់ដំបង ព្រោះខេត្តបាត់ដំបងបានបង្កើតការរៀនធម្មវិន័យមកជាយូរឆ្នាំហើយ ។ បន្ទាប់ពីនោះមក ព្រះប្រិយមហាក្សត្រ ទ្រង់មានព្រះរាជានុញ្ញាតនូវព្រះរាជក្រឹត្យលេខ ២១៤ ន.ស. ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ១៩៥០ ថា នឹងបង្កើតឲ្យមានសាលាធម្មវិន័យគ្រប់វត្តក្នុងព្រះរាជាណាចក្រ, វត្តព្រះព្រហ្មរ័តន៍នេះ បានបើករៀនធម្មវិន័យតាំងពីឆ្នាំ ១៩៥០ នោះមកដល់ឆ្នាំ ១៩៥៥ អស់រយៈកាល ៥ ឆ្នាំមកហើយ, លទ្ធផលនៃសិស្សដែលបានចូលមកសិក្សា ហើយបានប្រឡងជាប់វិញ្ញាបនបត្រ រួមទាំង ៣ ថ្នាក់ គឺថ្នាក់ ត្រី ទោ ឯក ទាំងសិស្សសាមញ្ញនិងសិស្សវិសាមញ្ញ មានចំនួនជាង ៥០០ រូប ។ ក្នុងឆ្នាំ ១៩៥៥ នេះ

គណៈកម្មការវត្តបានពិភាក្សាគ្នាថា វត្តយើងនេះ គួរនឹងសុំតាំងជាសាលាបាលីរងឡើង, ព្រោះសាលាបាលីអ្នកឧបាសិកា ប្រម នៅផ្សារសៀមរាប ព្រមទាំងបុត្រធីតា មានសទ្ធាជ្រះថ្លាកសាងសម្រេចឡើងហើយ, ការពិភាក្សាក៏មូលមតិជាឯកច្ឆន្ទបានសម្រេចដូចវត្តបំណង ។

ក្នុងថ្ងៃនេះ វត្តព្រះព្រហ្មរ័តន៍ ពេញជាមានកិត្តិគាប់ប្រសើរលើសលន់ ព្រោះបានទាន់រយៈកាលសម្តេចព្រះឧបយុវរាជ ទ្រង់យាងមកបំពេញព្រះរាជករណីយកិច្ចក្នុងខេត្តសៀមរាបនេះ ហើយទ្រង់ទៀតព្រះបរមរាជវរោកាស ទ្រង់យាងមកជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធបើកសាលាបាលីនេះ ។

អាត្មាភាពគ្រប់អង្គ មានសេចក្តីត្រេកអរនឹងព្រះគុណនេះយ៉ាងក្រៃពេក ទឹងរកវត្ថុអ្វីក្នុងពិភពលោកមកប្រៀបផ្ទឹមថ្លែងថ្លឹងពុំបាន ។

ក្នុងកាលជាអវសាននៃសុន្ទរកថានេះ អាត្មាភាព សូមសំបូងសំរួងដល់គុណព្រះរតនត្រ័យថ្លៃវិសេស និងទេវតាទាំង ១ ហ្មឺនលោកធាតុ សូមជួយអភិបាលរក្សាសម្តេច ព្រមទាំងព្រះរាជវង្សានុវង្ស និងឥស្សរជនទាំងឡាយ ឲ្យបានប្រកបដោយសុខភាព និងវឌ្ឍនភាព ទាំងមានព្រះជន្មាយុយឺនយូរអង្វែង ដើម្បីបីស្ហយមាតុភូមិឲ្យអណ្តែតត្រសែតទៅកាន់វឌ្ឍនធម៌ជាតិយោភាព និងបំពេញព្រះរាជកិត្តិយសចំពោះទង់ជាតិដែលមានប្រាសាទនគរវត្តជាជ័យនិមិត្តរូប ជានិរន្តរតរៀងទៅកុំបីឃ្លាត ។

លុះចប់សុន្ទរកថាៈហើយ លោកនាយកក្រុមព្រះនគរបាល ម៉ក់-ប៊ិក លើកជើងពានដម្កល់កន្ត្រៃទៅថ្វាយសម្តេច ។ ទ្រង់កាន់យកកន្ត្រៃ យាង

ទៅកាត់ខ្សែបូរជានិមិត្តរូបនៃពិធីបើកសាលាបាលី, កាលខ្សែបូរដាច់ទៅ សងខាងស៊ុំហើយ ព្រះសង្ឃស្វាធ្យាយធម៌ជយន្តោ លុះចប់ហើយ សម្តេចនឹងឥស្សរជនទ្រង់យាងនឹងអញ្ជើញចូលទស្សនាក្នុងថ្នាក់រៀនទាំងពីរថ្នាក់ រួចទ្រង់សន្ទនានឹងព្រះជាមេគណ អនុគណ · ចៅអធិការ តាមកាលដ៏សមគួរ ហើយថ្វាយបង្គំលាព្រះសង្ឃទ្រង់យាងទៅកាន់ព្រះរាជ·ដំណាក់វិញដោយសួស្តិភាព ។ កិច្ចប៉ុណ្ណេះ សន្មតថាចប់ពិធីបុណ្យសម្ពោធបើកសាលាបាលី ។

### មនុស្សបីពួក ទុកវត្ថុបីជាស្មៅ

មនុស្សគ្មានកិលេសតណ្ហា ទុកស្រីរូបល្អឆើតជាស្មៅ,
មនុស្សគ្មានធ្វើបាបអកុសល ទុកព្រះយមរាជជាស្មៅ,
មនុស្សគ្មានលោភ ទុករាជសម្បត្តិជាស្មៅ ។

បល្លង្កទិព្យនិទានទី ៩